៤៧	ความผิดฐานอนาจาร បទល្មើសប្រព្រឹត្តិអនាចារ	Indecent assault (n.) Sexually indecent act (n.)	ជាបទល្មើសព្រហ្មទណ្ឌដែលជនប្រព្រឹត្តិប្រព្រឹត្តិឲ្យខូចកិត្តិយសជាសាធារណៈ ដោយអាក្រាតឬបង្ហាញរាងកាយ ឬប្រព្រឹត្តិអំពើលាមកផ្សេងៗ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១៣៦៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទគថ្លង់ភាសាថៃផ្នែកច្បាប់, សមាគមជនពិការគថ្លង់ប្រចាំប្រទេសថៃ, ទំព័រ ២០៨ ២. ការិយាល័យសាលយុត្តិធម៌	
៤៨	ความผิดลหุโทษ បទល្មើសលហុ	Minor offence (n.) Petty offence (n.)	បទល្មើសដែលត្រូវជាប់ពន្ធនាគារមិនលើសពីមួយខែ ឬពិន័យជាប្រាក់មិនលើសពីមួយម៉ឺនបាត ឬទាំងជាប់ពន្ធនាគារទាំងពិន័យជាប្រាក់	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ១០២ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				៥៤២ ២. វាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌ ទំព័រ ៣២	
៤៩	ความผิดอันยอมความได้ បទល្មើបន្សំ	Compoundable offence (n.)	ជាបទល្មើសដែលប៉ះពាល់ដល់ជនរងគ្រោះជាលក្ខណៈបុគ្គល និងមានច្បាប់ចែងថាជាបទល្មើសបន្សំ ដូចជា បទល្មើសប្រមាថបុគ្គលទូទៅ បទល្មើសកេងប្រវ័ញ្ចម្ចាស់បំណុល បទល្មើសកិបកេង។ វិធានក្តីព្រហ្មទណ្ឌចំពោះបទល្មើសបន្សំ រដ្ឋត្រូវចូលរួមដោះស្រាយដោយស្វ័យប្រវត្តិពុំបានឡើយ លើកលែងតែជនរងគ្រោះឬបុគ្គលដែលពាក់ព័ន្ធតាមដែលច្បាប់បានចែងចេញមុខប្តឹង ដោយត្រូវប្តឹងក្នុងរយៈពេលបីខែគិតចាប់ពីថ្ងៃដែលដឹងរឿងល្មើសនិងស្គាល់ជនល្មើស (បណ្តុំច្បាប់ព្រហ្មទណ្ឌ ៩៦) និងបណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ៣៥, ៣៦, ៣៩ (២) និង ១២១ ដែលទាក់ទងនឹងការដកពាក្យបណ្តឹង ឬស្រុះស្រួលគ្នាតាមច្បាប់។	១. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វី កិត្តិ មីនៈកន្ទិដ្ឋ, មាត្រា ៩៦ ២. បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ៣៥ ៣៦ ៣៩(២) និង ១២១ ៣. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៤ (ច្បាប់វិសោធនកម្ម) ទំព័រ ១២៧-១២៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៤២	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍សព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥០	ความผิดอาญาแผ่นดิน បទល្មើសសាធារណៈ:	Public offence (n.)	ជាបទល្មើសដែលប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព ឬសណ្តាប់ធ្នាប់របស់រដ្ឋឬសង្គម ដោយរួមបទល្មើសសាធារណៈមិនអាចលើកលែងទោសបាននិងអាជ្ញាធរត្រូវចាត់វិធានការទោះបីជាពុំមានអ្នកប្តឹងឬផ្តាំលទោស	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៤ (ច្បាប់វិសោធនកម្ម) ទំព័រ ១២៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៤៣	
៥១	ความผิดอุกฉกรรจ์ បទឧក្រិដ្ឋ	Felony (n.) Indictable offence (n.)	បទល្មើសឧក្រិដ្ឋ គឺ ការបង្កហេតុឧក្រិដ្ឋដែលបង្កជាការភ័យខ្លាចចំពោះប្រជាជនដែលបានចែងកំណត់ទោសជនល្មើសឧក្រិដ្ឋធ្ងន់ធ្ងរជាងបទល្មើសប្រភេទផ្សេងៗ ជាបទល្មើសដែលប្រជាជនទូទៅដឹងឬជ្រាប។ ការប្រព្រឹត្តិអំពើហិង្សាផ្សេងៗ ដែលបណ្តាលមកពីមូលហេតុខុសគ្នារវាងស្ត្រី បុរសដែលប៉ះពាល់ឬអាចប៉ះពាល់ជាគ្រោះថ្នាក់ឬខូចខាតខាងផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តចំពោះស្ត្រី	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៤ (ច្បាប់វិសោធនកម្ម) ទំព័រ ៦០៩ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៤៣	
៥២	คอกพยาน អាសនៈសាក្សី	Witness-box (n.)	អាសនៈសម្រាប់ឈរដែលធ្វើសម្រាប់សាក្សីចូលទៅនិយាយឬថ្លែងសេចក្តីចំពោះមុខតុលាការមានលក្ខណៈជារូបបួនជ្រុងស្រដៀងទ្រុងសត្វ	វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីការិយាល័យសាលយុត្តិធម៌	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥៣	ค่าปรับ ថ្លៃពិន័យ	Fine (n.)	ទោសព្រហ្មទណ្ឌមួយករណី ដែលជនប្រព្រឹត្តិត្រូវទទួលពិន័យតាមចំនួនដែលតុលាការកំណត់ឬតាមដែលអ្នកមានអំណាចប្រៀបធៀបបានប្រៀបធៀប។ ម៉្យាងក្នុងរឿងក្តីដែលមានទោសពិន័យស្ថានទម្ងន់តែមួយប្រសិនបើជនប្រព្រឹត្តិយល់ព្រមបង់ថ្លៃពិន័យក្នុងអត្រាខ្ពស់សម្រាប់បទល្មើសនោះដល់ភ្នាក់ងារអាជ្ញាធរមុនពេលតុលាការពិចារណាក្តីគឺជាការស្រេចក្តី។	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៤ (ច្បាប់វិសោធនកម្ម) ទំព័រ ១៣៧, ៣៤០-៣៤១ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៥៥	
៥៤	ข้อกล่าวหา បទចោទប្រកាន់	Accusation (n.) Allegation (n.)	ការចោទ, ការចោទប្រកាន់, ការចោទប្រកាន់ថាបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ឬការចោទប្រកាន់ដែលពាក់ព័ន្ធនឹងការដណ្តើមសិទ្ធិ ឬតួនាទីរបស់បុគ្គលក្នុងរឿងក្តីរដ្ឋប្បវេណី	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨១, ១៧៩ <u>វាក្យសព្ទភាសាអង់គ្លេស</u> វាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌ នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៣	
៥៥	คำฟ้อง បណ្តឹង	Complaint (n.)	១. នីតិវិធីពិចារណាក្តីណាដែលដើមបណ្តឹងបានប្តឹងទៅតុលាការជាផ្ទាល់មាត់ឬធ្វើលិខិតបណ្តឹង មិនថាជាការប្តឹងទៅសាលាដំបូង ឬសាលាឧទ្ធរណ៍ មិនថាជាការប្តឹងក្នុងពេលដែលចាប់ផ្តើមក្តីដោយពាក្យបណ្តឹងឬប្តឹងនៅពេលក្រោយដោយប្តឹងបន្ថែមឬកែប្រែ ឬប្តឹងទាស់ឬដោយជ្រែកចូលទៅក្នុងរឿងក្តីមិនថាដោយស្ម័គ្រចិត្ត ឬត្រូវបង្គាប់បញ្ជា ឬដោយមានបណ្តឹងឲ្យ	១. បណ្តុំច្បាប់វិធីពិចារណាក្តីរដ្ឋប្បវេណី (វិសោធនកម្ម) ព.ស. ២៥៥៩ មាត្រា ១ (៣) ២. ព្រះរាជក្រឹត្យបង្កើតសាលគ្រប់គ្រងនិងវិធីពិចារណាក្តីគ្រប់គ្រង ព.ស. ២៥៤២ មាត្រា ៣ ៣. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៤ (ច្បាប់	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ពិចារណាជាថ្មី ២. ការប្តឹងទៅតុលាការមិនថាជាការប្តឹងទៅសាលដំបូងឬតុលាការកំពូល មិនថាជាការប្តឹងក្នុងពេលដែលចាប់ផ្តើមក្តីដោយពាក្យបណ្តឹង ឬប្តឹងនៅពេលក្រោយដោយប្តឹងបន្ថែមឬកែប្រែ ឬប្តឹងទាស់ឬដោយជ្រែកចូលទៅក្នុងរឿងក្តីមិនថាដោយដោយស្ម័គ្រចិត្ត ឬត្រូវបង្គាប់បញ្ជា ឬដោយមានបណ្តឹងឲ្យពិចារណាក្តីជាថ្មី	វិសោធនកម្ម) ទំព័រ ១៤៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៦២	
៥៦	គាំ‌ฟ้อง (คดีแพ่ง) បណ្តឹង (រឿងក្តីរដ្ឋប្បវេណី)	Plaint (n.)	នីតិវិធីពិចារណាក្តីណាដែលដើមបណ្តឹងបានប្តឹងទៅតុលាការជាផ្ទាល់មាត់ឬធ្វើលិខិតបណ្តឹង មិនថាជាការប្តឹងទៅសាលាដំបូង ឬសាលាឧទ្ធរណ៍ មិនថាជាការប្តឹងក្នុងពេលដែលចាប់ផ្តើមក្តីដោយពាក្យបណ្តឹងឬប្តឹងនៅពេលក្រោយដោយប្តឹងបន្ថែមឬកែប្រែ ឬប្តឹងទាស់ឬដោយជ្រែកចូលទៅក្នុងរឿងក្តីមិនថាដោយស្ម័គ្រចិត្ត ឬត្រូវបង្គាប់បញ្ជា ឬដោយមានបណ្តឹងឲ្យពិចារណាជាថ្មី	បណ្តុំច្បាប់វិធីពិចារណាក្តីរដ្ឋប្បវេណី (វិសោធនកម្ម) ព.ស. ២៥៥៩ មាត្រា ១ (៣) <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៦២	
៥៧	គាំ‌ฟ้อง (คดีอาญา) បណ្តឹង (រឿងក្តីព្រហ្មទណ្ឌ)	Charge (n.)	នីតិវិធីពិចារណាក្តីណាដែលដើមបណ្តឹងបានប្តឹងទៅតុលាការមិនថាជាការប្តឹងទៅសាលាដំបូង ឬសាលាឧទ្ធរណ៍ ដែលក្នុងរឿងក្តីព្រហ្មទណ្ឌភ្នាក់ងារអយ្យការត្រូវអធិប្បាយពាក្យបណ្តឹងឲ្យសព្វជ្រុងជ្រោយតាមបណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌមាត្រា ១៥៨ ដើមបណ្តឹងត្រូវធ្វើជាលិខិត និងមាន៖ (១) ឈ្មោះតុលាការនិងកាលបរិច្ឆេទ	១. វាក្យសព្ទអធិប្បាយពីការិយាល័យអយ្យការកំពូល ២. បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ១៥៨	

ឯកសារ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			(២) ក្តីរវាងអ្នកណាដើមបណ្តឹងអ្នកណាចុងចោទ និងសណ្ឋានបទល្មើស (៣) តំណែងភ្នាក់ងារអយ្យការអ្នកជាដើមបណ្តឹង បើប្រជាជនជាដើមបណ្តឹងត្រូវដាក់នាម នាមត្រកូល អាយុ អាសយដ្ឋាន សញ្ជាតិនិងវត្តុបំណង (៤) នាម នាមត្រកូល អាសយដ្ឋាន សញ្ជាតិនិងវត្តុបំណងរបស់ចុងចោទ (៥) ការប្រព្រឹត្តិទាំងឡាយណាដែលអះអាងថាចុងចោទបានប្រព្រឹត្តិទង្វើនិងសេចក្តីលម្អិតដែលពាក់ព័ន្ធនឹងពេលវេលានិងទីកន្លែងដែលការប្រព្រឹត្តិនោះបានកើតឡើង ព្រមទាំងបុគ្គលឬវត្តុដែលពាក់ព័ន្ធដោយអាចយកជាការបានដែលចុងចោទយល់បណ្តឹងបានច្បាស់ក្នុងរឿងក្តីប្រមាថមើលងាយ ពាក្យសម្តី លិខិត រូបភាពឬគំនូរឬវត្តុផ្សេងដែលពាក់ព័ន្ធនឹងការប្រមាថមើលងាយ ត្រូវលើកយកមកបង្ហាញដោយសព្ទគ្រប់ឬភ្ជាប់ជូនជាមួយពាក្យបណ្តឹង (៦) យោងមាត្រាក្នុងច្បាប់ដែលបានចែងស្តីអំពីការប្រព្រឹត្តិនោះជាបទល្មើស (៧) ហត្ថលេខាឈ្មោះដើមបណ្តឹង អ្នករៀបរៀង អ្នកសរសេរឬតំណាងដើមបណ្តឹង	<u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនិងសំនួនច្បាប់ ទំព័រ ៤៦៤, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥៨	គាំពាំងដ้วยวาจา បណ្តឹងផ្ទាល់មាត់	Oral pleading (n.)	នីតិវិធីពិចារណាក្តីណាដែលដើមបណ្តឹងបានប្តឹងទៅតុលាការតាមព្រះរាជក្រឹត្យស្តីអំពីការបង្កើតតុលាការថ្នាក់ឃុំ ដែលអាចពិចារណាក្តីព្រហ្មទណ្ឌក្នុងតុលាការថ្នាក់ឃុំ ព.ស. ២៥៥៩ មាត្រា ១៩ ក្នុងរឿងក្តីព្រហ្មទណ្ឌដែលស្ថិតក្នុងអំណាចតុលាការថ្នាក់ឃុំ ដែលអាចពិចារណាកាត់ក្តីបាន ជនរងគ្រោះឬភ្នាក់ងារអយ្យការអាចប្តឹងដោយវាចាឬជាពាក្យបណ្តឹងក៏បានតែបើចុងចោទស្នើសុំឬតុលាការ យល់សមគួរ អាចចេញបញ្ជាឲ្យប្តឹងជាលាយលក្ខណ៍អក្សរក៏បាន។ ការប្តឹងដោយវាចានេះ តម្រូវឲ្យដើមបណ្តឹងជម្រាបទៅតុលាការនូវឈ្មោះរឿងក្តី ឈ្មោះដើមបណ្តឹង អាសយដ្ឋាន និងសញ្ជាតិរបស់ ចុងចោទ សណ្ឋានបទល្មើសដែលអះអាងថាចុងចោទបានប្រព្រឹត្តិបទល្មើស និងសេចក្តីលម្អិតទាក់ទងនឹងពេលវេលា ទីកន្លែង និងផ្សេងៗ ដែលពាក់ព័ន្ធសមស្របល្មមអាចឲ្យចុងចោទយល់ពីបទចោទបានច្បាស់និងមាត្រាក្នុងច្បាប់ដែលចែងថា ការប្រព្រឹត្តិនោះជាបទល្មើស។ ចុងចោទអាចជម្រាបដោយវាចាឬធ្វើជាលិខិតក៏បាន។ ក្នុងករណីដែលប្តឹងឬជម្រាបដោយវាចា តម្រូវឲ្យតុលាការធ្វើកំណត់ហេតុជាភស្តុតាង និងឲ្យភាគីទំនាស់ចុះហត្ថលេខា។ ការផ្តល់ជាសក្ខីកម្មរបស់សាក្សី តម្រូវឲ្យតុលាការធ្វើកំណត់	វាក្យសព្ទអធិប្បាយពីការិយាល័យអយ្យការកំពូល <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីការិយាល័យអយ្យការកំពូល	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ត្រាខ្លឹមសារសំខាន់ដោយសង្ខេប និងឲ្យសាក្សីចុះហត្ថលេខា។		
៥៩	គំាសั่งเด็ดขาด ไม่ฟ้องคดี សេចក្តីបង្គាប់ដាច់ខាត មិនដាក់ពាក្យបណ្តឹង	A final non – prosecution order (n.)	បទបញ្ជាដែលជាចុងបញ្ចប់ក្នុងការពិចារណាបង្គាប់ក្តីក្នុងករណីដែលភ្នាក់ងារអយ្យការមានយោបល់ចេញសេចក្តីបង្គាប់មិនដាក់ពាក្យបណ្តឹង ដែលករណីខ្លះអយ្យការកំពូលជាអ្នកកំណត់ដោយដាច់ខាត តាមបណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌមាត្រា ១៤៦ ត្រូវចែងសេចក្តីបង្គាប់ដាច់ខាតមិនដាក់ពាក្យបណ្តឹង ឲ្យជនជាប់ចោទនិងដើមបណ្តឹងជ្រាប។ បើជនជាប់ចោទត្រូវឃាត់ខ្លួនឬជាប់ឃុំឃាំង ត្រូវរៀបចំដោះលែងឬសុំឲ្យតុលាការដោះលែង អាស្រ័យលើករណី។ ពេលភ្នាក់ងារអយ្យការចេញសេចក្តីបង្គាប់ដាច់ខាតមិនដាក់ពាក្យបណ្តឹងហើយ ជនរងគ្រោះ ជនជាប់ចោទ ឬអ្នកមានចំណែកផលឬខូចខាតមានសិទ្ធិតវ៉ាចំពោះភ្នាក់ងារអយ្យការដើម្បីសុំព័ត៌មានសរុបស្តីអំពីសាក្សីភស្តុតាងព្រមជាមួយយោបល់របស់ភ្នាក់ងារស៊ើបសួរនិងភ្នាក់ងារអយ្យការក្នុងការបញ្ជាក្តី។ ប្រការទាំងអស់នេះ ស្ថិតនៅក្នុងកំណត់អាយុ ការប្តឹង។	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ១៤៦ វាក្យសព្ទភាសាអង់គ្លេស វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ១២៥, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	
៦០	คำสั่งฟ้อง ដីកាអយ្យការក្នុងការដំណើរការក្តី	A prosecution order (n.)	បទបញ្ជាក្នុងការពិចារណាបង្គាប់ក្តីរបស់ភ្នាក់ងារអយ្យការដោយយោងតាមបណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌមាត្រា ១៤៣	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល,	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ពេលបានទទួលយោបល់និងសំណើពីភ្នាក់ងារស៊ើបសួរ ដូចដែលបានចែកក្នុងមាត្រាមុន តម្រូវឲ្យភ្នាក់ងារអយ្យការអនុវត្តដូចខាងក្រោមនេះ៖ (១) ក្នុងករណីដែលយល់ឃើញថាគួរចេញសេចក្តីបង្គាប់មិនដាក់ពាក្យបណ្តឹង ត្រូវចេញបទបញ្ជាសេចក្តីបង្គាប់មិនដាក់ពាក្យបណ្តឹង តែប្រសិនបើមិនយល់ស្របត្រូវចេញសេចក្តីបង្គាប់ឲ្យដាក់ពាក្យបណ្តឹងនិងជម្រាបឲ្យភ្នាក់ងារស៊ើបសួរបញ្ជូនជនសង្ស័យមកដើម្បីប្តឹងបន្ត។ (២) ក្នុងករណីយល់ឃើញថាគួរប្តឹង ត្រូវចេញសេចក្តីបង្គាប់ឲ្យដាក់ពាក្យបណ្តឹងនិងប្តឹងជនសង្ស័យទៅតុលាការ។ បើមិនយល់ស្រប ត្រូវចេញសេចក្តីបង្គាប់មិនដាក់ពាក្យបណ្តឹង។	មាត្រា ១៤៣ និងឧបសម្ព័ន្ធ វាក្យសព្ទភាសាអង់គ្លេស វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ១២៥, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	
៦១	คำสั่งไม่ฟ้อง ដីកាអយ្យការក្នុងការមិនដំណើរការក្តី	A non-prosecution order (n.)	បទបញ្ជាក្នុងការពិចារណាបង្គាប់ក្តីរបស់ភ្នាក់ងារអយ្យការដោយយោងតាមបណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ១៤៣ ពេលបានទទួលយោបល់និងសំណើពីភ្នាក់ងារស៊ើបសួរ ដូចដែលបានចែកក្នុងមាត្រាមុន តម្រូវឲ្យភ្នាក់ងារអយ្យការអនុវត្តដូចខាងក្រោមនេះ៖ (១) ក្នុងករណីដែលយល់ឃើញថាគួរចេញសេចក្តីបង្គាប់មិនដាក់ពាក្យបណ្តឹង ត្រូវចេញបទបញ្ជាសេចក្តីបង្គាប់មិនដាក់ពាក្យបណ្តឹង តែប្រសិនបើមិនយល់ស្របត្រូវចេញសេចក្តី	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ១៤៣ វាក្យសព្ទភាសាអង់គ្លេស វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ១២៥, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			បង្គាប់ឲ្យដាក់ពាក្យបណ្តឹងនិងជម្រាបឲ្យភ្នាក់ងារស៊ើបសួរបញ្ជូនជនសង្ស័យមកដើម្បីប្តឹងបន្ត។ (២) ក្នុងករណីយល់ឃើញថាគួរប្តឹង ត្រូវចេញសេចក្តីបង្គាប់ឲ្យដាក់ពាក្យបណ្តឹងនិងប្តឹងជនសង្ស័យទៅតុលាការ។ បើមិនយល់ស្រប ត្រូវចេញសេចក្តីបង្គាប់មិនដាក់ពាក្យបណ្តឹង។		
៦២	คำสารภาพ / การสารภาพ ចម្លើយសារភាព / ការសារភាព	Confession (n.) Guilty plea (n.)	ក្នុងដំណាក់កាលនៃការពិចារណាក្តី បើចុងចោទផ្តល់ចម្លើយសារភាពតាមបណ្តឹង តុលាការអាចពិចារណាក្តីដោយមិនស៊ើបរកសាក្សីឬភស្តុតាងជាបន្តទៀតក៏បាន លើកលែងតែក្តីដែលមានបទចោទនៃបទល្មើសដែលចុងចោទឆ្លើយសារភាពនោះត្រូវបានច្បាប់ចែងកំណត់អត្រាទោសយ៉ាងតិចឲ្យជាប់គុកចាប់ពីប្រាំឆ្នាំឡើងទៅឬស្ថានទម្ងន់ទោសធ្ងន់ជាងនោះ តុលាការត្រូវស្តាប់សាក្សីដើមបណ្តឹងរហូតទាល់តែអាចពិចារណាបានថាចុងចោទបានប្រព្រឹត្តិខុសពិតមែន។ ក្នុងក្តីដែលមានចុងចោទច្រើននាក់ និងចុងចោទខ្លះឆ្លើយសារភាព ពេលតុលាការយល់ឃើញថាសមស្រប តុលាការអាចចេញដីកាសម្រាប់ចុងចោទដែលបដិសេធដើម្បីឲ្យដើមបណ្តឹងប្តឹងចុងចោទដែលបដិសេធនោះជារឿងក្តីថ្មីក្នុងរយៈពេលដែលតុលាការកំណត់ក៏បាន។	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ១៧៦ វាក្យសព្ទភាសាអង់គ្លេស ១. វាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងារតុលាការជទណ្ឌ ទំព័រ ៣៣ ២. ទទួលសណ្តាប់យោបល់ ៤ ភាគ	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៦៣	คำให้การจำเลย អំណះអំណាងការតវ៉ា	Plea (vt.)	(១) ពាក្យសម្តីឬសារដែលអ្នកជាប់បណ្តឹងជាចុងចោទ មិនទទួលតែក៏មិនបដិសេធឬដោះសារបទចោទនៃរឿងក្តីដែលជាប់បណ្តឹងក្នុងក្តីព្រហ្មទណ្ឌ (២) "អំណះអំណាងការតវ៉ា" សំដៅលើ នីតិវិធីពិចារណាក្តីណាមួយដែលគូវិវាទភាគីណាមួយលើកអំណះអំណាងតវ៉ាជាការដោះសារបទចោទ តាមដែលបានចែងក្នុងបណ្តុំច្បាប់នេះ ក្រៅពីសេចក្តីថ្លែងការបើចុងចោទព្រមទទួលតាមបទចោទរបស់ដើមបណ្តឹងហៅថាចុងចោទទទួលស្គាល់ តែបើចុងចោទមិនព្រមទទួលហៅថាអំណះអំណាងការតវ៉ា។	១. វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ ២. បណ្តុំច្បាប់វិធីពិចារណាក្តីរដ្ឋប្បវេណី (វិសោធនកម្ម) ព.ស. ២៥៥៩ មាត្រា ១ (៥) <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីការិយាល័យអយ្យការកំពូល	
៦៤	คำให้การปฏิเสธ បដិសេធបទចោទប្រកាន់	To plead not guilty (v.) To refute the charge (v.)	មិនមាននិយមន័យនៃពាក្យបដិសេធបទចោទប្រកាន់ដោយផ្ទាល់ក្នុងច្បាប់។ នីតិវិធីពិចារណាក្តីព្រហ្មទណ្ឌចែងកំណត់ឲ្យជាសិទ្ធិនៃជនជាប់ចោទ / ចុងចោទក្នុងការឆ្លើយសារភាព / មិនឆ្លើយសារភាពក៏បាន។ ក្នុងករណីដែលជនជាប់ចោទឆ្លើយសារភាពអាចយកចម្លើយសារភាពទៅប្រើជាភស្តុតាងក្នុងការពិចារណាក្តីបាន (ក្នុងដំណាក់កាលស៊ើបសួរ) និង (ក្នុងដំណាក់កាលពិចារណាក្តី) តុលាការអាចសួរចុងចោទថាចង់ឆ្លើយសារភាព ចង់តវ៉ាឬយ៉ាងណា។ បើចុងចោទមិនព្រមឆ្លើយសារភាពតម្រូវឲ្យតុលាការធ្វើកំណត់ហេតុទុកដើម្បីដំណើរការពិចារណាក្តីបន្តទៀត។	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ១៣៥/៤ (១) និងមាត្រា ១៧២	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៦៥	จับกุม ចាប់ខ្លួន	Arrest (v.)	ឃាត់ខ្លួនទុកមិនឲ្យគេចខ្លួន ដូចជា ចាប់ខ្លួនជនល្មើស, ឃាត់ខ្លួនទុកដោយអាជ្ញាធរមានសមត្ថកិច្ចតាមច្បាប់	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៣១៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ២២	
៦៦	เจ้าหน้าที่ ป.ป.ท. អាជ្ញាធរប្រឆាំអំពើពុករលួយ	Public sector Anti - Corruption Commission officers (n.)	អ្នកដែលអង្គភាពប្រឆាំងអំពើពុករលួយតែតាំងចេញពីមន្ត្រីរាជការស៊ីវិល ឬមន្ត្រីរាជការឲ្យអនុវត្តតាមព្រះរាជក្រឹត្យ	ព្រះរាជក្រឹត្យវិធានរបស់ផ្នែកគ្រប់គ្រងក្នុងការការពារនិងប្រឆាំងអំពើពុករលួយ ព.ស. ២៥៥១ និងដែលបានវិសោធនកម្ម (ច្បាប់ទី ២) ព.ស. ២៥៥៩ មាត្រា ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> EXECUTIVE MEASURES IN ANTI-CORRPTION ACT, B.E. (2008) 2551	
៦៧	เจ้าหน้าที่ของรัฐ អាជ្ញាធររដ្ឋ	State official (n.)	អ្នកកាន់តំណែងផ្នែកនយោបាយ មន្ត្រីរាជការឬ អាជ្ញាធរតំបន់ដែលមានតំណែង ឬប្រាក់ខែប្រចាំ ភ្នាក់ងារឬបុគ្គលអ្នកអនុវត្តការងារក្នុងរដ្ឋាករស្វយ័ត ឬក្រុមការងាររបស់រដ្ឋ ថ្នាក់ដឹកនាំតំបន់និងសមាជិកសភាតំបន់ដែលពុំមែនជាអ្នកកាន់តំណែងផ្នែកនយោបាយ អាជ្ញាធរច្បាប់គ្រប់គ្រងតំបន់ និងសំដៅលើគណៈកម្មការ អនុគណៈកម្មការ មន្ត្រីជាប់កិច្ចសន្យារាជការរដ្ឋា	ព្រះរាជក្រឹត្យអមរដ្ឋធម្មនុញ្ញស្តីអំពីការការពារនិងប្រឆាំងអំពើពុករលួយ ព.ស. ២៥៤២ (មាត្រា ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីការិយាល័យ ប៉.ប៉.ជ.	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍សព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ការស្វែយ័ត ឬក្រុមការងាររបស់រដ្ឋ និងឯកជន ឬគណៈបុគ្គលដែលប្រើអំណាចឬបានទទួលសិទ្ធិឲ្យប្រើអំណាចផ្នែកការគ្រប់គ្រងរបស់រដ្ឋក្នុងការដំណើរការយ៉ាងណាមួយតាមច្បាប់ មិនថាជាការចាត់តាំងឡើងក្នុងរចនាសម្ព័ន្ធរាជការរដ្ឋាការស្វែយ័ត ឬកិច្ចការផ្សេងៗ របស់រដ្ឋ		
៦៨	เจ้าหน้าที่คดีพิเศษ អាជ្ញាធររឿងក្តីពិសេស	Special Case Officer (n.)	អ្នកដែលបានទទួលការតែងតាំងឲ្យធ្វើជាជំនួយការភ្នាក់ងារស៊ើបសួររឿងក្តីពិសេសក្នុងការស៊ើបសួរនិងស៊ើបអង្កេតរឿងក្តីពិសេសតាមដែលកំណត់ក្នុងព្រះរាជក្រឹត្យស្តីអំពីការស៊ើបអង្កេតរឿងក្តីពិសេស	ព្រះរាជក្រឹត្យការស៊ើបអង្កេតរឿងក្តីពិសេស មាត្រា ៣, ១៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> បញ្ជីរាយនាមតំណែងតាមព្រះរាជក្រឹត្យការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ព.ស. ២៥៥១ (ថៃ-អង់គ្លេស) តាមបណ្តាញមុខងារ ប្រភេទ និងលំដាប់តំណែង (គេហទំព័រក្រសួងហិរញ្ញវត្ថុ)	
៦៩	แจ้งความ ជូនដំណឹង	Notify (v.) File / Lodge a compliant (v.)	ប្រាប់ឲ្យដឹងសេចក្តី, ប្រាប់ហេតុទៅអាជ្ញាធរមានសមត្ថកិច្ច	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៣៤០ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ២២៣ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៧០	ซักถามพยาน ការសាកសួរសាក្សី	Examination of witnesses (n.)	សួរនិងដេញដោលឲ្យឆ្លើយ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៣៩៧ <u>វាក្យសព្ទភាសាអង់គ្លេស</u> វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ១៥៧, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	
៧១	ดูหมิ่น មាក់ងាយ /ប្រមាថ	Abuse (v.) Insult (v.)	បង្ហាញអាកប្បកិរិយា វាចា ឬសំណេរ ក្នុងន័យមើលងាយថាមានឋានៈតូចទាបឬមិនល្អពិត មិនឲ្យកែពិត ជាដើម	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៤៤១ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៩៥	
៧២	ตัวการ ជនបង្ក	Principal (n.) Principal in the first degree (n.)	១. ក្នុងករណីមានកំហុសណាមួយកើតឡើងដោយការប្រព្រឹត្តិរបស់បុគ្គលចាប់ពីពីរនាក់ឡើងទៅ អ្នកដែលបានចូលរួមប្រព្រឹត្តិបទល្មើសជាមួយគ្នានោះជាជនបង្ក ត្រូវទទួលទោសតាមដែលច្បាប់កំណត់សម្រាប់បទល្មើសនោះ។ ២. ជនបង្កហេតុ, ក្នុងរឿងក្តីព្រហ្មទណ្ឌសំដៅលើ បុគ្គលចាប់ពី ២ នាក់ឡើងទៅដែលរួមគ្នាប្រព្រឹត្តិបទល្មើស។	១. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៨៣ ២. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៤៨៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ២៦២	
៧៣	ตัวการร่วม ជនសមគំនិត	Co-principals (n.) Principal in the second degree (n.)	អ្នកដែលមានការរួមចំណែកក្នុងការប្រព្រឹត្តិបទល្មើស។ តាមបណ្តុំច្បាប់ព្រហ្មទណ្ឌ មាត្រា ៨៣ ក្នុងករណីបទល្មើសណាកើតឡើងដោយការប្រព្រឹត្តិរបស់បុគ្គលចាប់ពីពីរនាក់ឡើងទៅ អ្នកដែលបានចូលរួមការប្រព្រឹត្តិបទល្មើសជាមួយគ្នានោះជាជនសមគំនិត ត្រូវទទួលទោសតាមដែលច្បាប់កំណត់សម្រាប់បទល្មើសនោះ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៨៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់ រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦០៥	
៧៤	ติดตาม តាមដាន	To accompany (v.) To follow (v.) To keep track (v.)	(១) ទៅតាម, មកតាម (២) ស្វែងរកបន្ថែម, មើលឬស្តាប់បន្ថែមលើដំណើរប្រែប្រួលជាបន្តបន្ទាប់ ដូចជា តាមដានព័ត៌មាន (៣) តាមរក ដូចជា នគរបាលតាមដានជនល្មើស	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៥០០ <u>វាក្យសព្ទភាសាអង់គ្លេស</u> វចនានុក្រមថៃ-អង់គ្លេស ដោយ វង្ស វណ្ណធនពិជេដ្ឋ ទំព័រ ៣១៦	
៧៥	ไต่สวนข้อเท็จจริง ស៊ើបរកអង្គហេតុ	Fact inquiry (v.)	ស្វែងរក ប្រមែប្រមូល និងប្រតិបត្តិការផ្សេងៗ ដើម្បីឲ្យបានមកនូវអង្គហេតុនិងភស្តុតាងឬសាក្សី ក្នុងការដឹងព័ត៌មានលម្អិតនិងពិសោធទាក់ទងនឹងអំពើពុករលួយក្នុងកិច្ចការរដ្ឋរបស់អាជ្ញាធររបស់រដ្ឋ	ព្រះរាជក្រឹត្យវិធានរបស់ផ្នែកគ្រប់គ្រងក្នុងការការពារនិងប្រឆាំងអំពើពុករលួយ ព.ស. ២៥៥១ និងដែលបានវិសោធនកម្ម (ច្បាប់ទី ២) ព.ស. ២៥៥៩ មាត្រា ៣	

ឧបភាគ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				<u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីការិយាល័យ ប៉.ប៉.ជ.	
៧៦	ทนายขอแรง មេធាវីស្ម័គ្រចិត្ត	Public defender (n.) Pro bono lawyer (n.)	មេធាវីដែលតុលាការផ្តល់ជូនដើម្បីការពារចុងចោទក្នុងរឿងក្តីព្រហ្មទណ្ឌ ដោយចុងចោទមិនចាំបាច់ត្រូវបង់ថ្លៃចំណាយសម្រាប់មេធាវី ក្នុងករណីដែលចុងចោទពុំមានមេធាវីនិងត្រូវការមេធាវីដើម្បីតស៊ូក្តី។	វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦១២ ២. បំណកប្រែពីការិយាល័យសាលយុត្តិធម៌	
៧៧	ทายาทโดยธรรม ទាយាទស្នងមរតក	Statutory heir (n.) Heir at law (n.) Legal heir (n.)	ទាយាទដែលមានសិទ្ធិតាមច្បាប់ក្នុងរឿងមរតកអ្នកស្លាប់ ដូចជា សហព័ន្ធដែលមានជីវិតរស់នៅ អ្នកបន្តត្រកូល មាតាបិតា បងប្អូនបង្កើត បងប្អូនបង្កើតរួមបិតាឬមាតាជាមួយ តា យា អ៊ំ ប្រុស អ៊ំស្រី ពូ មីង តាមលំដាប់និងចំណែកមរតកដែលច្បាប់បានកំណត់	១. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៥៦៦ ២. បណ្តុំច្បាប់រដ្ឋប្បវេណីនិងពាណិជ្ជកម្ម មាត្រា ១៦២៩ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦១៨	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
๗๘	ทำการป้องกันโดยชอบด้วยกฎหมาย ការគាំពារតាមផ្លូវច្បាប់	Act in the lawful defense (n.)	លក្ខណៈបទល្មើសព្រហ្មទណ្ឌរបស់ជនប្រព្រឹត្តិដែលចាំបាច់ត្រូវធ្វើអ្វីមួយដើម្បីការពារសិទ្ធិរបស់ខ្លួន ឬរបស់អ្នកដទៃ ឲ្យផុតពីគ្រោះថ្នាក់ដែលកើតឡើងដោយសារការប្រទូសរាយដែលខុសច្បាប់ និងជាគ្រោះថ្នាក់ដែលជិតនឹងមកដល់ បើបានប្រព្រឹត្តិនោះសមស្របតាមហេតុការណ៍ដែលបានកើតឡើង ការប្រព្រឹត្តិនោះត្រូវការការគាំពារតាមផ្លូវច្បាប់។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៦៨ វាក្យសព្ទភាសាអង់គ្លេស វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ២៤៣, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	
๗๙	ทุจริตต่อหน้าที่ បទល្មើសពុករលួយក្នុងមុខតំណែងតួនាទី	Corruption in duty (n.)	ការអនុវត្តឬមិនអនុវត្តយ៉ាងណាមួយក្នុងព្រឹត្តិការណ៍ដែលអាចធ្វើឲ្យអ្នកដទៃជឿថាមានមុខតំណែងតួនាទីទាំងដែលខ្លួនពុំបានមានមុខតំណែងតួនាទីនោះ ឬប្រើអំណាចក្នុងតំណែង ឬតួនាទីទាំងនោះ ដើម្បីស្វែងរកផលប្រយោជន៍ដែលពុំគួរបានដោយសុចរិតសម្រាប់ខ្លួនឯងឬអ្នកដទៃ	ព្រះរាជក្រឹត្យអមរដ្ឋធម្មនុញ្ញស្តីអំពីការការពារនិងប្រឆាំងអំពើពុករលួយ មាត្រា ៤ វាក្យសព្ទភាសាអង់គ្លេស EXECUTIVE MEASURES IN ANTI-CORRPTION ACT, B.E. (2008) 2551	
๘๐	โทษทางอาญา ទោសព្រហ្មទណ្ឌ	Criminal Penalty (n.)	ទោសសម្រាប់ដាក់ជនប្រព្រឹត្តិបទល្មើស មានដូចខាងក្រោម៖ (១) ប្រហារជីវិត (២) ជាប់ពន្ធនាគារ (៣) ឃុំខ្លួន (៤) ជាកពិន័យ	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ១៨ វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពីការិយាល័យនគរបាលជាតិ	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			(៥) រឹបអូសទ្រព្យសម្បត្តិ		
៨១	นิติบุคคล នីតិបុគ្គល	Juristic person (n.) Legal person (n.)	បុគ្គលដែលតែងតាំងឡើងដោយច្បាប់ឬតាមច្បាប់ ត្រូវបានផ្តាច់ចេញពីបុគ្គលធម្មតា ដោយមានសិទ្ធិនិងតួនាទីដូចគ្នានឹងបុគ្គលធម្មតា លើកលែងតែសិទ្ធិនិងតួនាទីដែលតាមសភាពទើបតែមានឬទើបតែបានចំពោះនៃបុគ្គលធម្មតាប៉ុណ្ណោះ ដូចជា ក្រសួង អាជ្ញាធរជាតិ នាយកដ្ឋាន ក្រុមហ៊ុនឯកជន សមាគមន៍ មូលនិធិ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៦៣៤ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ១៧២	
៨២	บัลลังก์ អាសនៈ	Bench (n.)	ទីអង្គុយរបស់តុលាការពេលពិចារណាក្តីក្នុងសាលសវនាការ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៦៦៥ វាក្យសព្ទភាសាអង់គ្លេស ការិយាល័យសាលយុត្តិធម៌	
៨៣	ใบสั่ง ដីកាបង្គាប់	Ticket (n.)	លិខិតបង្គាប់ឲ្យអនុវត្តតាមដែលកំណត់ទុក	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៦៩០ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣៣៤	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍សព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៨៤	ประนีประนอมยอมความ សម្របសម្រួលក្តី	Compromise (v.)	សម្របសម្រួលក្តី គឺ កិច្ចព្រមព្រៀងដែលគូទំនាស់ទាំងពីរភាគីរំងាប់វិវាទណាមួយដែលកំពុងមាន ឬនឹងកើតមានឡើងឲ្យស្រេចដោយភាគីនីមួយៗ យល់ព្រមសម្បទានឲ្យគ្នាទៅវិញទៅមក។	បណ្តុំច្បាប់រដ្ឋប្បវេណីនិងពាណិជ្ជកម្ម (វិសោធនកម្ម) ព.ស. ២៥៥៩ មាត្រា ៨៥០ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៥១	
៨៥	ประมวลกฎหมายวิธีพิจารณาความอาญา បណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌ	Criminal Procedure Code (n.)	បទបញ្ញត្តិដែលចងបណ្តុំជាប្រព័ន្ធនិងបានទទួលការប្រកាសឲ្យប្រើជាច្បាប់សម្រាប់ក្តីព្រហ្មទណ្ឌក្នុងទម្រង់ច្បាប់ដែលបានចែង	វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៥១	
៨៦	ประมวลกฎหมายอาญា បណ្តុំច្បាប់ព្រហ្មទណ្ឌ	Criminal Code (n.)	បទបញ្ញត្តិដែលចងបណ្តុំជាប្រព័ន្ធនិងបានទទួលការប្រកាសឲ្យប្រើជាច្បាប់សម្រាប់ក្តីព្រហ្មទណ្ឌក្នុងទម្រង់ច្បាប់សារបញ្ញត្តិពោលគឺជាបទបញ្ញត្តិស្តីអំពីបទល្មើសនិងទោសព្រហ្មទណ្ឌ	គោលការណ៍ច្បាប់ព្រហ្មទណ្ឌ បោះពុម្ពលើកទី ៥ (វិសោធនកម្ម) ព.ស. ២៥៥១, សាស្ត្រាចារ្យ ស្វែង បុណ្យឆ្លើមវិភាស, ទំព័រ ១៣ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៥១	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍សព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៨៧	ประมาทเลินเล่อ ធ្វេសប្រហែស	Negligent (adj.) Negligence (n.)	ទង្វើដែលប្រាសចាកការប្រុងប្រយ័ត្ន ឬបោះបង់នូវអ្វីដែលគួរធ្វើ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៧១០ <u>វាក្យសព្ទភាសាអង់គ្លេស</u> វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ២៤០, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	
៨៨	ปล้นทรัพย์ អំពើប្លន់	Gang robbery (n.)	បទល្មើសព្រហ្មទណ្ឌដែលជនប្រព្រឹត្តិបានរួមគ្នាឆក់យកទ្រព្យសម្បត្តិចាប់ពី ៣ នាក់ឡើងទៅ	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា ទំព័រ ៣៤៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ២៤២, សាស្ត្រាចារ្យ ធង វិទ័យវឌ្ឍន៍	
៨៩	ผู้ไกล่เกลี่ย អ្នកសម្របសម្រួល	Mediator (n.)	អាជ្ញាកណ្តាលដែលគូវិវាទស្រុះស្រួលគ្នាឲ្យជួយក្នុងការផ្តល់យោបល់រកដំណោះស្រាយឲ្យគូវិវាទអាចស្រុះស្រួលគ្នាលើបញ្ហាវិវាទ បើជាការសម្របសម្រួលក្តីក្នុងតុលាការហៅថា "អ្នកសម្របសម្រួល" ដោយអាចជាបុគ្គលខាងក្រៅ ឬក្នុងតុលាការ ឬតុលាការ	វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៦០	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៩០	ผู้ใช้ អ្នកប្រើ	Employing person (n.)	๑. ជនណាបង្កឲ្យជនដទៃប្រព្រឹត្តិបទល្មើស មិនថាជាការប្រើការបញ្ជា ការគំរាម ការជួល ការសាបព្រោះឬញុះញង់ជួយ ឬដោយវិធីផ្សេង ជននោះជាអ្នកប្រើឲ្យប្រព្រឹត្តិបទល្មើស។ ๒. ជនបង្កដែលឲ្យជនដទៃប្រព្រឹត្តិបទល្មើសមិនថាដោយការប្រើ ការបញ្ជា ការគំរាម ការជួល ការសាបព្រោះឬញុះញង់ជួយ ឬដោយវិធីផ្សេង	๑. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ๒๕๖๑, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីនៈកន្ទិដ្ឋ, មាត្រា ៨៥ ๒. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ๔ (វិសោធនកម្ម), ទំព័រ ๓๖๕ <u>វាក្យសព្ទភាសាអង់គ្លេស</u> វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ๒๕๓	
៩១	ผู้ต้องหา ជនជាប់ចោទ	Alleged offender (n.) Suspect (n.)	បុគ្គលដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តិបទល្មើសតែនៅពុំទាន់ត្រូវបានប្តឹងទៅតុលាការ	๑. បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ๒๕๖๑, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ๒ (๒) ๒. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ๔ (វិសោធនកម្ម), ទំព័រ ๓๖๙ <u>វាក្យសព្ទភាសាអង់គ្លេស</u> ๑. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ๘, ទំព័រ	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				៦៦៥ ២. ទទួលសណ្តាប់យោបល់ ៤ ភាគ	
៩២	ผู้ถูกกล่าวหา ចុងចោទ	Alleged (n.) Culprit (n.) Alleged offender (n.)	បុគ្គលដែលត្រូវបានចោទពីបទល្មើសព្រហ្មទណ្ឌ បទល្មើសវិន័យឬសីលធម៌ ឬការប្រព្រឹត្តិល្មើសច្បាប់ផ្សេង	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. បំណកប្រែពីការិយាល័យ ប៉.ប៉.ជ. ២. ទទួលសណ្តាប់យោបល់ ៤ ភាគ	
៩៣	ผู้สนับสนุน អ្នកជួយ	Secondary party (n.) Accessory (n.)	បុគ្គលណាប្រព្រឹត្តិដោយប្រការណាមួយ ដែលជាការជួយឬផ្តល់ភាពងាយស្រួលក្នុងការដែលជនដទៃប្រព្រឹត្តិល្មើសមុនឬខណៈប្រព្រឹត្តិល្មើស ទោះបីជាជនល្មើសពុំបានដឹងអំពីការជួយឬការផ្តល់ភាពងាយស្រួលនោះក៏ដោយ អ្នកនោះជាអ្នកជួយការប្រព្រឹត្តិបទល្មើស ត្រូវផ្តន្ទាទោសចំនួនពីរភាគបីនៃទោសដែលបានកំណត់ចំពោះបទល្មើសដែលជួយនោះ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីនៈកន្ទិដ្ឋ, មាត្រា ៨៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៧៣ ២. ទទួលសណ្តាប់យោបល់ ៤ ភាគ	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៩៤	ผู้สนับสนุนตัวการก่อนเกิดเหตุ បុគ្គលអ្នកជួយជនបង្កហេតុ	An accessory before the fact (n.)	បុគ្គលណាប្រព្រឹត្តិដោយប្រការណាមួយ ដែលជាការជួយឬផ្តល់ភាពងាយស្រួលក្នុងការដែលជនដទៃប្រព្រឹត្តិល្មើសមុនឬខណៈប្រព្រឹត្តិល្មើស ទោះបីជាជនល្មើសពុំបានដឹងអំពីការជួយឬការផ្តល់ភាពងាយស្រួលនោះក៏ដោយ អ្នកនោះជាអ្នកជួយការប្រព្រឹត្តិបទល្មើស។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីនៈកន្ទិដ្ឋ, មាត្រា ៨៦ វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពីការិយាល័យអយ្យការកំពូល	
៩៥	ผู้สมคบ ជនសមគំនិត	Accomplice (n.)	បើបុគ្គលចាប់ពីពីរនាក់ឡើងទៅសមគំនិតគ្នា ដើម្បីប្រព្រឹត្តិបទល្មើស គេថាជនទាំងនោះជនសមគំនិត។	ច្បាប់លក្ខណៈព្រហ្មទណ្ឌ រ.ស. ១២៧ ម.៦ (៨) វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់ រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៧	
៩៦	ผู้เสียหาย ជនរងគ្រោះ	Injured person (n.) Victim (n.)	"ជនរងគ្រោះ" សំដៅលើបុគ្គលដែលបានរងការខូចខាតដោយសារការប្រព្រឹត្តិបទល្មើសណាមួយ រួមទាំងបុគ្គលដទៃដែលមានអំណាចចាត់ចែងជំនួសបាន ដូចដែលបានចែងក្នុងមាត្រា ៤, ៥ និង ៦ បុគ្គលទាំងនោះចាត់ចែងជំនួសជនរងគ្រោះបាន៖ (១) អ្នកតំណាងដោយសុចរិតឬអ្នកអាណាព្យាបាល ចំពោះតែក្នុងបទល្មើសដែលបានប្រព្រឹត្តិចំពោះអនីតិជន ឬជនងាយរងគ្រោះដែលស្ថិតក្រោមអាណាព្យាបាល	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ២ (២), ៥, ៦ វាក្យសព្ទភាសាអង់គ្លេស ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់ រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ១៥៨	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			(២) ជនជាបុព្វការី អ្នកបន្តវង្សត្រកូល ស្វាមីឬភរិយា ចំពោះតែបទល្មើស ដែលជនរងគ្រោះត្រូវគ្រោះថ្នាក់ដល់អាយុជីវិត ឬរងរបួសរហូតពុំអាចចាត់ចែងដោយខ្លួនឯងបាន (៣) អ្នកគ្រប់គ្រងឬអ្នកតំណាងផ្សេងនៃនីតិបុគ្គល ចំពោះបទល្មើសដែលប្រព្រឹត្តិចំពោះនីតិបុគ្គលប៉ុណ្ណោះ ក្នុងក្តីព្រហ្មទណ្ឌដែលជនរងគ្រោះជាអនីតិជនពុំមានអ្នកតំណាងដោយសុចរិត ឬជាវិកលចរិតជនឬជនបាត់បង់សមត្ថភាពពុំមានអាណាព្យាបាល ឬដែលអ្នកតំណាងដោយសុចរិតឬអ្នកអាណាព្យាបាលមិនអាចធ្វើតាមតួនាទីដោយហេតុណាមួយរួមទាំងមានផលប្រយោជន៍ទាស់ជាមួយអនីតិជនឬជនបាត់បង់សមត្ថភាពទាំងនោះ ញាតិរបស់អ្នកនោះ ឬអ្នកមានប្រយោជន៍ពាក់ព័ន្ធអាចប្តឹងទៅតុលាការ សុំឲ្យតែងតាំងខ្លួនជាអ្នកតំណាងដោយចំពោះលើរឿងក្តីនោះបាន។ ពេលបានស៊ើបសួរហើយតម្រូវឲ្យតុលាការតែងតាំងអ្នកប្តឹងទាមទារឬបុគ្គលផ្សេងដែលយល់ព្រមតាមដែលយល់ថាសមគួរជាអ្នកតំណាងចំពោះក្តី ពេលពុំមានបុគ្គលណាជាតំណាងតម្រូវឲ្យតុលាការតែងតាំងភ្នាក់ងារផ្នែកគ្រប់គ្រងជាអ្នកតំណាង។	២. ទទួលសណ្តាប់យោបល់ ៥ ភាគ	
៩៧	พนักงานสอบสวน ភ្នាក់ងារស៊ើបសួរ	Inquiry official (n.)	ភ្នាក់ងារដែលច្បាប់ផ្តល់អំណាចនិងតួនាទីធ្វើការស៊ើបសួរ	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រា	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍សព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				ចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ២ (៦) <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ១៥៨	
៩៨	พนักงานสอบสวนคดีพิเศษ ភ្នាក់ងារស៊ើបអង្កេតរឿងក្តីពិសេស	Special Case inquiry Official (n.)	ប្រធាននាយកដ្ឋានស៊ើបអង្កេតរឿងក្តីពិសេស អនុប្រធាននាយកដ្ឋានស៊ើបអង្កេតរឿងក្តីពិសេស និងអ្នកដែលបានទទួលការតែងតាំងឲ្យមានអំណាចនិងតួនាទីក្នុងការស៊ើបអង្កេតនិងស៊ើបសួររឿងក្តីពិសេស	ព្រះរាជក្រឹត្យស្តីអំពីការស៊ើបអង្កេតរឿងក្តីពិសេស ព.ស. ២៥៤៧ មាត្រា ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> បញ្ជីរាយនាមតំណែងតាមព្រះរាជក្រឹត្យការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ព.ស. ២៥៥១ (ថៃ-អង់គ្លេស) តាមបណ្តាញមុខងារ ប្រភេទ និងលំដាប់តំណែង (គេហទំព័រក្រសួងហិរញ្ញវត្ថុ)	
៩៩	พยาน ភស្តុតាងសាក្សី	Evidence (n.)	១. សាក្សីជាបុគ្គលដែលនឹងមកផ្តល់ឬបានផ្តល់ព័តិមានចំពោះភ្នាក់ងារអ្នកមានអំណាចស៊ើបសួរក្តីព្រហ្មទណ្ឌ ភ្នាក់ងារអ្នកមានអំណាចប្តឹងក្តីព្រហ្មទណ្ឌឬតុលាការក្នុងការដំណើរក្តីព្រហ្មទណ្ឌ រួមទាំងអ្នកជំនាញការពិសេស តែពុំផ្តល់អត្ថន័យរួមដល់ចុងចោទដែលអះអាងខ្លួនថាជាសាក្សី	១. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ទំព័រ ២២៦ ២. ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងសាក្សីក្នុងរឿងក្តីព្រហ្មទណ្ឌ ព.ស. ២៥៤៦ មាត្រា ៣ ៣. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨០៥	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍សព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			២. ភស្តុតាងឬឧបករណ៍ពិសោធរកការពិត អ្នកដែលដឹងហេតុការណ៍ឬការពិតដែលប្រើជាភស្តុតាងអាចពិសោធបាន	<u>វាក្យសព្ទភាសាអង់គ្លេស</u> ទទួលសណ្តាប់យោបល់ ៤ ភាគ	
១០០	พยานบุคคล សាក្សី	Witness (n.)	បុគ្គលដែលដឹងការពិតដែលពាក់ព័ន្ធនឹងរឿងក្តីមិនថាដឹងដោយវិធីណាដែលអាចជាសាក្សីផ្ទាល់ភ្នែក ឬសាក្សីនិយាយប្រាប់ក៏បាន	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨០៥ <u>វាក្យសព្ទភាសាអង់គ្លេស</u> ទទួលសណ្តាប់យោបល់ ៤ ភាគ	
១០១	พยานวัตถุ ភស្តុតាង	Material Evidence (n.) Tangible evidence (n.) Instrument of evidence (n.)	វត្ថុដែលជាសំអាង	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨០៥ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៧៩	
១០២	พยานหลักฐาน សាក្សីភស្តុតាង	Evidence (n.)	ក្នុងរឿងក្តីរដ្ឋប្បវេណីសំដៅលើ វត្ថុដែលអាចនាំយកមកប្រើក្នុងការវិនិច្ឆ័យរកការពិត។ ក្នុងរឿងក្តីព្រហ្មទណ្ឌសំដៅលើ វត្ថុដែលអាចពិសោធបានថាចុងចោទឬជនជាប់ចោទមានកំហុសឬបរិសុទ្ធ។	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨០៥ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				៦៧៩	
១០៣	พยานเอกสาร ភស្តុតាងឯកសារ	Documentary evidence (n.)	ឯកសារដែលជាសំអាង	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨០៥ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៨១	
១០៤	พยายามกระทำความผิด ការព្យាយាមប្រព្រឹត្តិបទល្មើស	Attempt (n.)	ប្រព្រឹត្តិបទល្មើសតែប្រព្រឹត្តិទៅមិទាន់ចប់ ឬប្រព្រឹត្តិចប់ហើយតែការប្រព្រឹត្តិនោះពុំទទួលបានផល ជននោះព្យាយាមប្រព្រឹត្តិបទល្មើស	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៨០ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៨១	
១០៥	ระเบิดแสวงเครื่อง គ្រាប់បែកថ្នៃ	Improvised explosive device (n.)	ជាទម្រង់នៃការផលិតគ្រាប់បែក ដោយការនាំយកនូវវត្ថុដែលមានជាទូទៅ ដែលងាយស្រួលរក យកមកកែច្នៃជាគ្រាប់បែក មិនថាជាការយកវត្ថុគ្រឿងផ្ទុះខាងយោធាខាងស៊ីវិល សារធាតុបន្សុំផ្ទៃកគីមី និងយកឧបករណ៍ផ្សេងៗ មកផ្គុំគ្នាបង្កើតជាគ្រាប់បែកថ្នៃ មានទម្រង់ច្រើនសណ្ឋាន មិនថានៅនឹងថ្កល់	សៀវភៅណែនាំស្តីអំពីការការពារវត្ថុតាងសម្រាប់ប្រជាជន ក្រុមការងារកម្ទេចអាវុធនិងគ្រឿងផ្ទុះអណោទ័យ នាយកដ្ឋានសព្វាវុធទាហានជើងគោក ទំព័រ ៦	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			អាចរចនាបាន ស្មុគស្មាញ គ្រោះថ្នាក់ ពិបាកដោះ ដែលជាការរចនាឡើងអាស្រ័យលើវត្ថុបំណងនៃការប្រើប្រាស់ និងភាពប៉ិនប្រសប់របស់អ្នកច្នៃគ្រាប់បែក អាចដាក់តាមខ្លួន លាក់កំបាំងបានងាយស្រួល ងាយស្រួលបំបែកជាបំណែក ងាយបម្លាស់ទី ពិបាកត្រួតពិនិត្យរកឃើញ ដើមទុនក្នុងការផលិតទាប មានកម្លាំងផ្ទុះខ្ពស់ជាងការបង្កវិនាសកម្មប្រភេទផ្សេងៗ	<u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីការិយាល័យនគរបាលជាតិ	
១០៦	ริบทรัพย์ ការរឹបអូសទ្រព្យសម្បត្តិ	Confiscate / Forfeit (n.)	រឹបអូសទ្រព្យសម្បត្តិមកជាធ្វើជាសម្បត្តិរដ្ឋ ដូចជា ត្រូវរឹបអូសទ្រព្យសម្បត្តិដោយអំណាចដីកាបង្គាប់របស់តុលាការ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១០០៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> ទទួលសណ្តាប់ធ្នាប់ល់ ៤ ភាគ	
១០៧	ละเมิด អំពើអនីត្យានុកូល	Tort (n.)	ជនណាមានបំណងឬប្រមាថមាក់ងាយចំពោះបុគ្គលផ្សេងដោយខុសច្បាប់ ធ្វើឲ្យគេទទួលរងផលប៉ះពាល់ដល់អាយុជីវិតក្តី រូបរាងកាយក្តី សេរីភាពក្តី ទ្រព្យសម្បត្តិឬសិទ្ធិណាមួយក្តី គេថាអ្នកនោះប្រព្រឹត្តិអំពើអនីត្យានុកូល ចាំបាច់ត្រូវសងសំណងប៉ះប៉ូវលើផលប៉ះពាល់នោះ។	បណ្តុំច្បាប់រដ្ឋប្បវេណីនិងពាណិជ្ជកម្ម (វិសោធនកម្ម) ព.ស. ២៥៥៩ មាត្រា ៤២០ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣៣៦	
១០៨	ลักทรัพย์ អំពើចោរកម្ម	Take by stealth (n.)	១. ជាបទល្មើសព្រហ្មទណ្ឌ ដែលអ្នកប្រព្រឹត្តិយកទ្រព្យសម្បត្តិរបស់អ្នកដទៃឬដែលអ្នកដទៃជាម្ចាស់រួមជាមួយទៅដោយ	១. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១០៤៨	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ទុច្ចរិត ២. ជនណាយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬអ្នកដែលជាម្ចាស់ទ្រព្យសម្បត្តិរួមជាមួយទៅដោយទុច្ចរិត ជននោះប្រព្រឹត្តិល្មើសច្បាប់ស្តីអំពីចោរកម្ម	២. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីនៈកន្ទិដ្ឋ, មាត្រា ៣៣៤ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៧២៣	
១០៩	วิ่งราวทรัพย์ ឆក់	Snatching (v.)	១. ជាបទល្មើសព្រហ្មទណ្ឌដែលជនប្រព្រឹត្តិលួចទ្រព្យសម្បត្តិដោយកញ្ឆក់យកពីក្នុងដៃឬចំពោះមុខ ២. ជនណាលួចទ្រព្យដោយកញ្ឆក់យកពីក្នុងដៃឬចំពោះមុខ ជននោះប្រព្រឹត្តិល្មើសច្បាប់ស្តីអំពីការឆក់យកទ្រព្យសម្បត្តិ។ ប្រសិនបើការលួចទ្រព្យសម្បត្តិដោយការឆក់ជាហេតុបង្ក ឲ្យជនដទៃគ្រោះថ្នាក់ដល់រាងកាយឬផ្លូវចិត្ត ជនប្រព្រឹត្តិត្រូវទទួលទោសជាប់គុកចាប់ពីពីរឆ្នាំដល់ប្រាំពីរឆ្នាំ និងពិន័យចាប់ពីបួនម៉ឺនបាតដល់មួយសែនបួនម៉ឺនបាត។ ប្រសិនបើការលួចទ្រព្យសម្បត្តិដោយការឆក់ជាហេតុបង្ក ឲ្យជនដទៃគ្រោះថ្នាក់ធ្ងន់ធ្ងរ ជនប្រព្រឹត្តិត្រូវទទួលទោសជាប់គុកពីបីឆ្នាំដល់ដប់ឆ្នាំ និងពិន័យចាប់ពីប្រាំមួយម៉ឺនបាតដល់ពីរសែនបាត។	១. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១១១៦ ២. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីនៈកន្ទិដ្ឋ, មាត្រា ៣៣៦ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣១៣	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ប្រសិនបើការលួចទ្រព្យសម្បត្តិដោយការឆក់ជាហេតុបង្ក ឲ្យជនដទៃគ្រោះថ្នាក់ដល់ស្លាប់ ជនប្រព្រឹត្តិត្រូវទទួលទោសជាប់គុកចាប់ពីប្រាំឆ្នាំដល់ដប់ឆ្នាំ និងពិន័យចាប់ពីមួយសែនបាតដល់បីសែនបាត។		
១១០	ศพ សាកសព	Corpse (n.) Cadever (n.) Dead body (n.)	ខ្មោច, រាងកាយដែលស្លាប់ទៅហើយ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១១៣៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥១, ៧៨ ២. វាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌ ទំព័រ ៣៨	
១១១	สัญญาสัมปทาน កិច្ចសន្យាសម្បទាន	Concession contract (n.)	កិច្ចសន្យា គឺ ការព្រមព្រៀងរវាងបុគ្គល ២ ភាគីឬច្រើនភាគី ដើម្បីបង្កើតនីតិកម្មឡើង។ សម្បទាន គឺ ការអនុញ្ញាតដែលរដ្ឋផ្តល់ឲ្យឯកជនដើម្បីរៀបចំសេវាសាធារណៈឬរៀបចំធ្វើប្រយោជន៍ឬស្វែងរកផលប្រយោជន៍ពីធនធានជាតិក្នុងរយៈពេលនិងតាមលក្ខខណ្ឌដែលរដ្ឋកំណត់ ដូចជា សម្បទានសេវាថយន្តក្រុង សម្បទានដីធ្លី។	វាក្យសព្ទអធិប្បាយពីការិយាល័យ ប៉.ប៉.ជ. <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៧	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
១១២	สินบน សំណូក	Bribe (n.)	១. ទ្រព្យសម្បត្តិឬផលប្រយោជន៍ដទៃណាដែលផ្តល់ឲ្យដល់បុគ្គលដើម្បីទិញទឹកចិត្តឲ្យអ្នកនោះឲ្យប្រព្រឹត្តិឬពុំប្រព្រឹត្តិយ៉ាងណាមួយ មិនថាកិច្ចការនោះសុចរិតឬទុច្ចរិតតាមតួនាទី (មើលបណ្តុំព្រះរាជក្រឹត្យស្តីអំពីបទល្មើសព្រហ្មទណ្ឌមាត្រា ១៤៣) ២. ប្រាក់ដែលបង់ឲ្យអ្នកប្រចាំការ (ព្រះរាជក្រឹត្យស្តីអំពីការផ្តល់គុណបំណាច់ការបង្ក្រាបជនល្មើស ព.ស. ២៤៨៩ មាត្រា ៥) ៣. ទ្រព្យសម្បត្តិឬរបស់របរដែលនឹងផ្តល់ឲ្យជាការសងគុណឬតមស្នងអ្នកដែលនឹងជួយឲ្យសម្រេចតាមបំណង ៤. ទ្រព្យសម្បត្តិឬផលប្រយោជន៍ផ្សេងណាដែលផ្តល់ឲ្យដល់បុគ្គលដើម្បីទិញទឹកចិត្តឲ្យជននោះប្រព្រឹត្តិឬពុំប្រព្រឹត្តិយ៉ាងណាមួយក្នុងតំណែងមិនថាការនោះសុចរិតឬទុច្ចរិតតាមតួនាទី	១. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ៥៧០ ២. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១២៣៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣៨	
១១៣	สิ้นสงสัย អស់សង្ស័យ	Beyoud reasonable doubt (adj.)	គោលការណ៍មូលដ្ឋានសម្រាប់តុលាការក្នុងការប្រើដើម្បីថ្លឹងថ្លែងសាក្សីនិងភស្តុតាងទាំងពួង ដោយមិនពិចារណាទោសរហូតទាល់តែច្បាស់ក្នុងចិត្តថាមានការប្រព្រឹត្តិបទល្មើសពិតនិងចុងចោទជាអ្នកប្រព្រឹត្តិបទល្មើសនោះ និងប្រសិនបើមានការសង្ស័យតាមហេតុផលថាចុងចោទបានប្រព្រឹត្តិបទល្មើសឬអត់តម្រូវឲ្យលើកប្រយោជន៍នៃការសង្ស័យនោះដល់ចុងចោទ។	វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីការិយាល័យសាលយុត្តិធម៌	
១១៤	หมายค้น ដីកាស្វែងរក	Search warrant (n.) Warrant of search (n.)	ដីកាដែលបង្គាប់ឲ្យអាជ្ញាធរត្រួតពិនិត្យនិងស្វែងរក ដើម្បីរឹបអូសវត្ថុតាងឬឃាត់ខ្លួនបុគ្គលដែលមានដីការចាប់ខ្លួន ឬដើម្បី	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១៣០៣	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ជួយបុគ្គលដែលត្រូវបានអូសទាញឬឃុំខ្លួនដោយខុសច្បាប់	<u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៧៧២	
១១៥	หมายจับ ដីកាចាប់ខ្លួន	Warrant of arrest (n.) Arrest warrant (n.)	លិខិតបង្គាប់ដែលតុលាការបង្គាប់ឲ្យអាជ្ញាធរចាប់ខ្លួនជនជាប់ចោទឬចុងចោទ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១៣០៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស អង់-គ្លេសថៃ ទំព័រ ៧៧៥ ២. វាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌ ទំព័រ ៣៥	
១១៦	หมายเรียก ដីកាកោះហៅ	Summons (n.) Summons warrant (n.)	១. លិខិតបង្គាប់ការរបស់ភ្នាក់ងារឬតុលាការកោះហៅបុគ្គលមកជួបឬប្រព្រឹត្តិយ៉ាងណាមួយ ២. លិខិតបញ្ជា បញ្ជាឲ្យបុគ្គលដែលត្រូវសម្គាល់ទុកក្នុងដីកានោះមកជួបអ្នកចេញដីកាកោះហៅដើម្បី៖ (១) ធ្វើការស៊ើបសួរ-អាចកោះហៅជនជាប់ចោទ, សាក្សី (២) សាកសួរមូលហេតុនៃបណ្តឹង-អាចកោះហៅសាក្សី, អ្នកមានឯកសារគ្រប់គ្រង	១. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១៣០៣ ២. វាក្យសព្ទអធិប្បាយច្បាប់ស្តីអំពីការពិចារណាក្តីព្រហ្មទណ្ឌ ១ សមស្របក្នុងការសិក្សាកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ប្រឡងជំនួយការអយ្យការ និងជំនួយការតុលាការ ទំព័រ ៣១១	

ឧបសម្ព័ន្ធ ១ ខាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			(៣) ការពិចារណាក្តី (៤) ដើម្បីកិច្ចការផ្សេងណាតាមបទបញ្ញត្តិនៃបណ្តុំច្បាប់នេះ	<u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៧៧៣ ២. វាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌ ទំព័រ ៣៥	
១១៧	หมิ่นประมาท ប្រមាថមាក់ងាយ	Defame (v.)	១. ជនណាទម្លាក់កំហុសជនដទៃចំពោះបុគ្គលទីបីដោយប្រការដែលអាចនឹងធ្វើឲ្យជនដទៃនោះខូចកេរ្តិ៍ឈ្មោះ ត្រូវបានគេប្រមាថមាក់ងាយ ឬត្រូវបានគេស្អប់ ជននោះប្រព្រឹត្តិបទល្មើសស្តីអំពីការប្រមាថមាក់ងាយ។ ២. ជាបទល្មើសព្រហ្មទណ្ឌ ដែលជនប្រព្រឹត្តិទម្លាក់កំហុសជនដទៃចំពោះបុគ្គលទីបីដោយប្រការដែលអាចនឹងធ្វើឲ្យបុគ្គលដទៃនោះខូចកេរ្តិ៍ឈ្មោះ ត្រូវបានគេប្រមាថមាក់ងាយ ឬត្រូវបានគេស្អប់	១. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣២៦ ២. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១៣០៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៨៧	
១១៨	ห้องพิจารณาคดี បន្ទប់សវនាការ	Court-room (n.)	បន្ទប់ដែលប្រើសម្រាប់ការពិចារណាក្តីនៃតុលាការ	វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៩០	
១១៩	ห้องเวรชี้ បន្ទប់បម្រុង	Arraignment room (n.)	បន្ទប់ពិចារណាក្តីដែលតុលាការអាចត្រៀមទុកសម្រាប់ពិចារណាក្នុងដំណាក់កាលដំបូងនៃរឿងក្តីពេលចូលដល់នីតិវិធីរបស់តុលាការ ដូចជាណាត់ធ្វើតេស្តឆ្លើយសំណួររបស់ចុងចោទ ឬករណីមានការឃាត់ខ្លួនជនជាប់ចោទ។	វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពីការិយាល័យសាលយុត្តិធម៌	
១២០	เหตุบรรเทาโทษ ហេតុបន្ទុរបន្តយទោស	Extenuationg circumstance (n.) Mitigating circumstance (n.)	១. ហេតុបន្ទុរបន្តយទោស សំដៅលើ ជនប្រព្រឹត្តិបទល្មើសជាជនលួងខ្លៅ ខ្សោយបញ្ញាក្នុងកម្រិតធ្ងន់ធ្ងរ មានគុណសម្បត្តិពីមុនមក ដឹងកំហុសនិងខិតខំកាត់បន្តយផលអាក្រក់នៃកំហុសនោះ ដល់នូវទោសចំពោះភ្នាក់ងារឬផ្តល់នូវការយល់ដឹងដល់តុលាការដែលជាប្រយោជន៍នៃការពិចារណាក្តីឬហេតុផ្សេងដែលតុលាការយល់ឃើញថាមានលក្ខណៈប្រហាក់ប្រហែលគ្នា ២. ហេតុផ្សេងៗ ដែលច្បាប់កំណត់ឲ្យតុលាការមានអំណាចបន្ទុរបន្តយទោសដល់ជនប្រព្រឹត្តិល្មើស ដូចជា សេចក្តីលួងខ្លៅ ខ្សោយបញ្ញាក្នុងកម្រិតធ្ងន់ធ្ងរ មានគុណសម្បត្តិពីមុនមក ផ្តល់ការយល់ដឹងដល់តុលាការដែលជាប្រយោជន៍នៃការពិចារណាក្តី	១. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៧៨ ប្រការ ២ ២. រចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១៣៤៣ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់ រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៧៨១	

ឧបសម្ព័ន្ធ ១ ឧទាហរណ៍ពាក្យសព្ទក្នុងដំណាក់កាលស៊ើបសួរ (១២២ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
១២១	องค์ประกอบของความผิด ធាតុផ្សំនៃបទល្មើស	Elements of the offence (n.)	១. គោលការណ៍សំខាន់ក្នុងការពិចារណាក្តីព្រហ្មទណ្ឌតាមរយៈបណ្តុំច្បាប់ព្រហ្មទណ្ឌ មាត្រា ៥៩ បុគ្គលត្រូវទទួលទោសព្រហ្មទណ្ឌលុះត្រាតែបានប្រព្រឹត្តិដោយចេតនា លើកលែងតែការប្រព្រឹត្តិដោយធ្វេសប្រហែស។ ក្នុងករណីដែលច្បាប់ចែងត្រូវទទួលទោសពេលបានប្រព្រឹត្តិដោយធ្វេសប្រហែសឬលើកលែងតែក្នុងករណីដែលច្បាប់កំណត់ដោយចែងច្បាស់លាស់តម្រូវឲ្យទទួលទោសទោះបីជាការប្រព្រឹត្តិដោយអចេតនា។ ការប្រព្រឹត្តដោយចេតនា សំដៅលើការប្រព្រឹត្តិដោយដឹងនូវទង្វើក្នុងការប្រព្រឹត្តិនិងក្នុងពេលដូចគ្នាដែរជនប្រព្រឹត្តិមានបំណងចង់បានផលប្រយោជន៍ ឬសម្លឹងឃើញផលប្រយោជន៍នៃការប្រព្រឹត្តិនោះ។ បើជនប្រព្រឹត្តិពុំបានដឹងការពិតដែលជាធាតុផ្សំនៃបទល្មើស ពុំអាចចាត់ទុកថាជនប្រព្រឹត្តិមានបំណងចង់បានផលប្រយោជន៍ ឬសម្លឹងឃើញផលប្រយោជន៍នៃការប្រព្រឹត្តិនោះឡើយ។ ការប្រព្រឹត្តិដោយធ្វេសប្រហែស សំដៅលើការប្រព្រឹត្តិបទល្មើសដោយអចេតនាតែប្រព្រឹត្តិដោយប្រាសចាកការប្រុងប្រយ័ត្នដែលបុគ្គលនៅក្នុងស្ថានភាពដូច្នេះអាស្រ័យលើវិស័យឬព្រឹត្តិការណ៍ និងជនប្រព្រឹត្តិអាចប្រើបម្រុងប្រយ័ត្នដូចដែល	១. វាក្យសព្ទអធិប្បាយពីការិយាល័យសាលយុត្តិធម៌ ២. សៀវភៅវាក្យសព្ទអធិប្បាយច្បាប់ព្រហ្មទណ្ឌ ភាគ ១ បទបញ្ញត្តិទូទៅ បោះពុម្ពលើកទី ១០ (វិសោធនកម្ម), សាស្ត្រាចារ្យ កិត្តិខ្ជរ វចនៈសុវត្តិ, ទំព័រ ១៥៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសសម្រាប់មេធាវី បោះពុម្ពលើកទី ៥ (វិសោធនកម្ម), សាស្ត្រាចារ្យ ដួងដេន នាគសីហរាជ, ទំព័រ ៣០១	

២	การควบคุมตัวแบบไม่เข้มงวด ការឃាត់ខ្លួនបែបមិនតឹងរ៉ឹង	Non-Intensive custody (n.)	ប្រើសម្រាប់អប់រំជនដែលចូលមកទទួលការស្តារនីតិសម្បទាដែលជាអ្នកញៀនគ្រឿងញៀននិងមានប្រវត្តិពាក់ព័ន្ធនិងគ្រឿងញៀនធ្ងន់ធ្ងរ កម្មវិធីដែលប្រើក្នុងការអប់រំ គឺ FAST MODEK រយៈពេលក្នុងការអប់រំ ៤ ខែ ក្រុមការងារអប់រំ គឺ កងទ័ពជើងគោក កងទ័ពជើងទឹក នាយកដ្ឋានកិច្ចគ្រប់គ្រង នាយកដ្ឋានកិច្ចការពេទ្យ នាយកដ្ឋានកិច្ចការសុខភាពផ្លូវចិត្ត និងមជ្ឈមណ្ឌលកម្លាំងជាតិប្រឆាំគ្រឿងញៀននន្ទបុរី	នីតិវិធីគណៈកម្មការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនស្តីអំពីការធ្វើតេស្ត ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការឃាត់ខ្លួន និងការអនុវត្តចំពោះអ្នកមកធ្វើតេស្តនិងអ្នកចូលមកទទួលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៦ ប្រការ ២១ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៤៤	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៣	ការควบคุม និងสอดส่อง ការត្រួតពិនិត្យ	Supervision (n.)	ជានីតិវិធីការតាមដាន មើលថែ និងផ្តល់ការប្រឹក្សានិងជួយដល់ជនប្រព្រឹត្តិបទល្មើសដែលស្ថិតនៅក្នុងកំលុងពេលស្តារនីតិសម្បទាក្នុងមជ្ឈមណ្ឌលអប់រំកែប្រែក្រោមលក្ខខណ្ឌការគ្រប់គ្រងការប្រព្រឹត្តិ ដើម្បីជួយឲ្យជនប្រព្រឹត្តិបទល្មើសទាំងអស់នោះ អាចកែប្រែអត្តចរិតនិងសម្របខ្លួនអាចរស់នៅរួមជាមួយអ្នកផ្សេងក្នុងសង្គមបានដោយប្រក្រតី រហូតមិនត្រលប់ទៅប្រព្រឹត្តិខុសដដែលទៀត ដោយមានភ្នាក់ងារគ្រប់គ្រងការប្រព្រឹត្តិជាអ្នកនៅចាំគ្រប់គ្រងតាមដានសួរសុខទុក្ខដើម្បីផ្តល់ការប្រឹក្សាណែនាំ ដាស់តឿន ជួយក្នុងការរស់នៅ សម្របខ្លួនអត្តចរិត និស្ស័យ ការប្រព្រឹត្តិ ការសិក្សា កិច្ចការក្រៅអាជីព រួមទាំងកិច្ចការផ្សេងៗ ទៀត ការអប់រំកែប្រែតាមសភាពបញ្ហានិងតម្រូវការជាលក្ខណៈបុគ្គល ដោយអាស្រ័យវិធីសាស្ត្រផ្សេងៗ ដូចជា ការផ្តល់ប្រឹក្សាយោបល់ ការព្យាបាលអាការជំងឺក្នុងវាងកាយនិងចិត្ត ការផ្តល់ចំណេះដឹង ការហ្វឹកអាជីព ការសម្របសកម្មភាពនិងការប្រព្រឹត្តិ រួមទាំងការជួយសង្គ្រោះក្នុងទម្រង់ផ្សេងៗ	សៀវភៅណែនាំការងារនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិសម្រាប់បម្រើប្រជាជន ទំព័រទី ៧ វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
៤	การคุมประพฤติ ការគ្រប់គ្រងការប្រព្រឹត្តិ	Probation (n.)	ការស្រាវជ្រាវស៊ើបសួរនិងត្រួតពិនិត្យ និងការគ្រប់គ្រងការប្រព្រឹត្តិអ្នកត្រូវបានគ្រប់គ្រងការប្រព្រឹត្តិឲ្យអនុវត្តតាមលក្ខខណ្ឌដែលកំណត់ទុកតាមសេចក្តីបង្គាប់របស់តុលាការ ឬភ្នាក់ងារមានសមត្ថកិច្ចរួមទាំងការប្រើវិធានដោះស្រាយស្តារនីតិសម្បទាអ្នកប្រព្រឹត្តិទោសព្រហ្មទណ្ឌសណ្ឋានមួយ ដែលឲ្យនាំខ្លួនអ្នកជាប់ទោសទៅដាក់ឃុំក្នុងពន្ធនាគារ	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ៤ វាក្យសព្ទភាសាអង់គ្លេស PROATION ACT, B.E. 2016 (2559) Section 5	

ឧបសម្ព័ន្ធ ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥	การจำคุก ការជាប់ពន្ធនាគារអស់មួយជីវិត	Imprisonment (n.) Incarceration (n.)	ការត្រូវផ្តន្ទាទោសជាប់គុកអស់មួយជីវិតរបស់អ្នកទោស	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ១៧៩ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងារាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៥	
៦	การจำคุกตลอดชีวิต ការជាប់គុកពេញមួយជីវិត	Life Imprisonment (n.)	ការត្រូវដាក់ទោសពេញមួយជីវិតអ្នកទោស	សៀវភៅវាក្យសព្ទគថ្លង់ភាសាថៃផ្នែកច្បាប់, សមាគមជនពិការគថ្លង់ប្រចាំប្រទេសថៃ, ទំព័រ ២១១ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងារាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៥	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៧	การจำแนก ចែកថ្នាក់	To sort out (v.) To separate (v.) To distribute (v.)	១. ការចែកថ្នាក់តាមនីតិវិធីរបស់នាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ គឺ ការវាយតម្លៃអ្នកដែលត្រូវបានស៊ើបសួរនិងត្រួតពិនិត្យ អ្នកត្រូវបានគេគ្រប់គ្រងការប្រព្រឹត្តិឬបុគ្គលដែលតុលាការ ឬភ្នាក់ងារមានសមត្ថកិច្ចចេញសេចក្តីបង្គាប់ដោយពិចារណាដល់ទ្វហានិភ័យឬទំនោរនៃប្រព្រឹត្តិខុសដដែលម្តងទៀត និងសភាពបញ្ហា ភាពចាំបាច់ និងតម្រូវការរបស់ជនប្រព្រឹត្តិបទល្មើសម្នាក់ៗ ដើម្បីប្រើជាទិន្នន័យក្នុងការកំណត់វិធានអនុវត្តដែលសមស្រប។ ២. នីតិវិធីនាយកដ្ឋានរាជទណ្ឌប្រើពាក្យថា ការចែកថ្នាក់លក្ខណៈជនត្រូវជាប់ឃុំឃាំង គឺ នីតិវិធីក្នុងការអនុវត្តចំពោះជនត្រូវជាប់ឃុំឃាំងជាលក្ខណៈបុគ្គលចាប់ផ្តើមពីដំណាក់កាលដំបូងដែលទទួលជនត្រូវជាប់ឃុំឃាំងចូលទៅក្នុងពន្ធនាគារ រហូតដល់ពេលទទួលបានការដោះលែង រួចទោសដោយការសិក្សាវិភាគប្រវត្តិសាវតារបុគ្គលិកលក្ខណៈនិងសភាពទូទៅរបស់ជនត្រូវជាប់ឃុំឃាំង រួមទាំងប្រវត្តិការប្រព្រឹត្តិបទល្មើសនិងមូលហេតុនៃការប្រព្រឹត្តិបទល្មើស ដើម្បីឲ្យអាចកំណត់ផែនការគ្រប់គ្រង ដោះស្រាយ បំបាត់ ស្តារនីតិសម្បទានិងអភិវឌ្ឍអត្តចរិតជនត្រូវឃុំឃាំង និងការត្រៀមទុកមុនការដោះលែង ដែលមានដូចជា ការចែកថ្នាក់អ្នកត្រូវជាប់ឃុំឃាំងដំណាក់កាលមូលដ្ឋាន ការបែងចែកលក្ខណៈដើម្បីអភិវឌ្ឍអត្តចរិត និងការបែងចែកលក្ខណៈដើម្បីការត្រៀមទុកមុនការដោះលែង	១. នីតិវិធីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិស្តីអំពីគោលការណ៍ នីតិវិធី និងលក្ខខណ្ឌការចាត់ក្រុមអ្នកត្រូវស៊ើបសួរនិងត្រួតពិនិត្យ អ្នកដែលត្រូវបានគ្រប់គ្រងការប្រព្រឹត្តិនិងបុគ្គលដែលតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចចេញបញ្ជា ព.ស. ២៥៦០ ប្រការ ៣ ២. នីតិវិធីក្រសួងយុត្តិធម៌ស្តីអំពីគោលការណ៍និងនីតិវិធីការបែងចែកជនត្រូវជាប់ឃុំឃាំងនិងមន្ទីរឃុំឃាំង ការពន្យាឬកាត់បន្ថយកម្រិតទោសដាច់ខាត ការកាត់បន្ថយថ្ងៃត្រូវជាប់គុកនិកការសម្រាលទោស ព.ស. ២៥៥៩ ប្រការ ៥, ៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. វចនានុក្រមថៃ-អង់គ្លេស ដោយ វង្ស វណ្ណពិជដ្ឋ ទំព័រ ១៨៦ ២. កំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	

ឧបសម្ព័ន្ធ ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៨	ការដំណើរការដើម្បីស្តារយុត្តិធម៌ប្រភេទសំណងប៉ះប៉ូវ การดำเนินการเพื่อสร้างความยุติธรรมเชิงสมานฉันท์ การดำเนินการเพื่อสร้างความยุติธรรมเชิงสมานฉันท์	Procedure for restorative justice (n.)	ជាដំណើរការដែលផ្តោតសំខាន់លើការកាត់បន្ថយគុណវិបត្តិឬការរំងាប់ក្តីដែលកើតឡើងដោយសារការប្រព្រឹត្តិបទល្មើសដោយការប៉ះប៉ូវការខូចខាតដល់ជនរងគ្រោះនិងសហគមន៍ ការបង្កើតការត្ទាក់រលឹកនិងទំនួលខុសត្រូវលើការប្រព្រឹត្តិរបស់ខ្លួន និងការឲ្យជនរងគ្រោះ ជនត្រូវគេស៊ើបសួរនិងត្រួតពិនិត្យជនដែលត្រូវគេគ្រប់គ្រងការប្រព្រឹត្តិ និងសមាជិកសហគមន៍ដែលបានទទួលរងផលប៉ះពាល់ពីឧក្រិដ្ឋកម្មបានសហការគ្នារកដំណោះស្រាយបញ្ហា	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ៣៦ ប្រការ ២ វាក្យសព្ទភាសាអង់គ្លេស 9. PROATION ACT, B.E. 2559 (2016) Chapter V ២. កំណកប្រៃពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
៩	ការពិនិត្យព្យាបាល การดูแลรักษาพยาบาล การพิจารณาทางการแพทย์	Medical service (n.) Medical care (n.)	ការពិនិត្យសុខភាពនិងការព្យាបាល ដោយជាទូទៅការពិនិត្យព្យាបាលគឺជាវិធានការការពារការឈឺថ្កាត់ ដូចជា ការធ្វើការវិនិច្ឆ័យនិងការវាស់ស្ទង់ ដែលពាក់ព័ន្ធនឹងបញ្ហាសុខភាព ដូចជា ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ។ ចំណែកការព្យាបាលសំដៅលើ ទម្រង់នៃការថែរក្សាសុខភាពដែលស្ថិតនៅក្នុងដំណាក់កាលនៃការសន្និដ្ឋាននិងការវិនិច្ឆ័យរបស់ពេទ្យ ជាប្រការដែលត្រូវធ្វើក្រោយការកើតអាការឈឺថ្កាត់។ ការថែរក្សាសុខភាពនិងការព្យាបាល ត្រូវបានបែងចែកចេញជា បឋមព្យាបាលសង្គ្រោះបន្ទាន់ និងការព្យាបាលពិសេស។ បឋមព្យាបាល គឺ ការព្យាបាលដំណាក់កាលមូលដ្ឋាននៃការព្យាបាលដទៃ និងតែងតែចំណុះឲ្យមណ្ឌលសុខភាពឬគ្លីនិក។ ការសង្គ្រោះបន្ទាន់ ជាការព្យាបាលអាការជំងឺឬរបួសដែលកើតឡើងដោយបន្ទាន់ ឬកើតហេតុការណ៍ធ្ងន់ធ្ងរ។ ការព្យាបាលពិសេស ជាការព្យាបាលដែលរៀបចំឡើងក្នុងមន្ទីរពេទ្យ និងជា	គេហទំព័រមន្ទីរពេទ្យសូឡេហ្វទិអឺប្រទេសស៊ុយអែត វាក្យសព្ទភាសាអង់គ្លេស គេហទំព័រមន្ទីរពេទ្យសូឡេហ្វទិអឺប្រទេសស៊ុយអែត	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ឧទាហរណ៍)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ការព្យាបាលក្នុងករណីដែលកើតជំងឺធ្ងន់ធ្ងរ ឬមានអាការធ្ងន់ដែលតម្រូវឲ្យបញ្ជូនមកមន្ទីរពេទ្យ ឬគ្លីនិកដែលនៅក្បែរ។		
๑๐	การตรวจพิสูจน์ ការធ្វើតេស្ត	Examination (n.)	ការស្វែងរកទិន្នន័យតាមរយៈការកត់ត្រាប្រព្រឹត្តិកម្មក្នុងការប្រព្រឹត្តិបទល្មើសរួមទាំងសភាពជាទូទៅនៃអ្នកជំងឺ រួមទាំងការត្រួតពិនិត្យសុខភាពរាងកាយនិងសុខភាពផ្លូវចិត្ត ការធ្វើតេស្តរកសារធាតុញៀនក្នុងបន្ទប់ពិសោធន៍ឬការធ្វើអ្វីផ្សេងៗ ដើម្បីទទួលបានទិន្នន័យមកសរុបនិងវិនិច្ឆ័យថាអ្នកមកធ្វើតេស្តជាអ្នកសេពឬញៀនគ្រឿងញៀនឬអត់។	នីតិវិធីគណៈកម្មការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនស្តីអំពីការធ្វើតេស្ត ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការឃាត់ខ្លួន និងការអនុវត្តចំពោះអ្នកមកធ្វើតេស្តនិងអ្នកចូលមកទទួលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ๒๕๔๖ ប្រការ ๓ <u>វាក្យសព្ទភាសាអង់គ្លេស</u> REHABILTATION OF NARCOTIC ADDICT ACT, B.E. 2545 (2002) Section 9 ប្រការ 4	
๑๑	การเตรียมความพร้อมก่อนปล่อย ការត្រៀមមុនពេលដោះលែង	Pre-release (n.) Pre-release preparation (n.)	ការរៀបចំត្រៀមសម្រាប់អ្នកទោសមុនពេលត្រូវដោះលែង ជាការរៀបចំវគ្គសិក្សាអប់រំជូនដល់អ្នកទោសដែលជិតរួចទោសឲ្យចេញទៅរស់នៅក្នុងសង្គមខាងក្រៅ ជាទម្រង់នៃវិធានការត្រៀមទុកមុនការដោះលែង ជាការចែកថ្នាក់អ្នកទោសដើម្បីផ្តល់ការប្រឹក្សាណែនាំ ដើម្បីការសាងទំនុកចិត្ត រួមទាំងជាវិធានឲ្យអ្នកទោសសម្រេចចិត្តជ្រើសរើសវិធីនៃការរស់នៅក្រោយពេលដោះលែង ដើម្បីអាចជួយឲ្យអ្នកទោសអាចសម្របខ្លួនក្នុងការរស់នៅជាមួយគ្រួសារ សហគមន៍និងសង្គម	ការសិក្សាស្រាវជ្រាវឯករាជ្យ ប្រធានបទ "ការត្រៀមខ្លួនមុនការដោះលែង សម្រាប់ជនជាប់ឃុំឃាំងដែលមានការប្រព្រឹត្តិខុសផ្នូរនៃមន្ទីរឃុំឃាំងពិសេសក្រុងបាងកក" ដោយ លោក ធនាភ័ទ្រ វាងអភ័យ	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ឧទាហរណ៍)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			បានយ៉ាងសមស្រប តែដោយសារស្ថានភាពសង្គមមានការប្រែប្រួលគ្រប់ពេលវេលា និងសង្គមពុំបានទទួលស្គាល់ជនរួចទោសធ្វើឲ្យជនរួចទោសកើតអារម្មណ៍ស្មុគស្មាញ តែលគោលឯកា ពុំមានអ្នកប្រឹក្សា ត្រូវគេបោះបង់ អាចធ្វើឲ្យជនរួចទោសត្រលប់ទៅប្រព្រឹត្តិបទល្មើសម្តងទៀត។		
១២	การทำงานบริการสังคมหรือสาธารณประโยชน์ ការធ្វើការបម្រើសង្គមឬប្រយោជន៍សាធារណៈ:	Community service or Public Service (n.)	ការងារឬកិច្ចការដែលកំណត់ឲ្យអ្នកត្រូវគេគ្រប់គ្រងការប្រព្រឹត្តិធ្វើជូនសង្គម សហគមន៍ ឬស្ថាប័នសាធារណៈ: ដោយពុំបានទទួលថ្លៃឈ្នួល និងការងារ ឬកិច្ចការដែលបាននិយាយមកនេះត្រូវពុំមែនជាការងារឬកិច្ចការដែលស្វែងរកផលកម្រៃឲ្យដល់ជនណាឬក្រុមការងារណាមួយឡើយ។	នីតិវិធីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិស្តីអំពីគោលការណ៍ នីតិវិធី និងលក្ខខណ្ឌក្នុងការធ្វើការបម្រើសង្គម ឬសាធារណប្រយោជន៍ ព.ស. ២៥៦០ ប្រការ ៣ វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
១៣	การทำงานบริการสังคมแทนการชำระค่าปรับ ការធ្វើការបម្រើសង្គមជំនួសថ្លៃពិន័យ	Community service in place of paying a fine (n.)	ជម្រើសរបស់ជនល្មើសដែលត្រូវសាលក្រមដាក់ទោសពិន័យតែពុំមានប្រាក់បង់ថ្លៃពិន័យតម្រូវឲ្យធ្វើការបម្រើសង្គមជំនួសថ្លៃពិន័យជូនដល់សង្គម សហគមន៍ ឬស្ថាប័នសាធារណៈដែលពុំស្វែងរកប្រាក់កម្រៃ ដោយកំណត់អត្រាកាត់កងមួយថ្ងៃ ៥០០ បាត	http://www.probation.go.th/contentmenu.php?id=249	
១៤	การผิดเงื่อนไข / ละเมิดเงื่อนไข ការល្មើសលក្ខខណ្ឌ	Violation of probation condition (n.)	មាត្រា ៥៧ ពេលក្តីបង្ហាញចំពោះតុលាការឬក្តីបង្ហាញតាមរយៈការថ្លែងរបស់ភ្នាក់ងារអយ្យការឬភ្នាក់ងារមានសមត្ថកិច្ចថាជនល្មើសពុំអនុវត្តតាមលក្ខខណ្ឌដូចដែលសាលក្រមកំណត់តាមមាត្រា ៥៦ តុលាការអាចដាស់តឿនជនល្មើសឬអាច	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីនៈកន្ទិដ្ឋ, មាត្រា ៥៦, ៥៧	

ឧបសម្ព័ន្ធ ៣ ឧទាហរណ៍ពាក្យសព្ទក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			កំណត់ការដាក់នូវទោសដែលនៅពុំទាន់បានកំណត់ឬដាក់ទោសនូវទោសដែលមានក៏បាន។	<u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
១៥	ការฟื้นฟูสมรรถภาพผู้ติดยาเสพติด ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន	Rehabilitation (n.)	ការប្រព្រឹត្តិទាំងឡាយណាដែលជាការព្យាបាលជនញៀនគ្រឿងញៀននិងស្តារសភាពសុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់អ្នកញៀនគ្រឿងញៀន រួមទាំងការស្តារសភាពសុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់អ្នកញៀនគ្រឿងញៀនឲ្យត្រលប់មករកសភាពប្រក្រតី ដោយមិនបង្កគុណវិបត្តិដល់អ្នកញៀនគ្រឿងញៀន	ព្រះរាជក្រឹត្យស្តីអំពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៥ មាត្រា ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> REHABILTATION OF NARCOTIC ADDICT ACT, B.E. 2545 (2002) Section 4	
១៦	การลดวันต้องโทษจำคุก ការកាត់បន្ថយថ្ងៃត្រូវជាប់ពន្ធនាគារ	Good Conduct allowances (n.)	ការកាត់បន្ថយថ្ងៃត្រូវជាប់ពន្ធនាគារមាន ២ ករណី គឺ ការកាត់បន្ថយថ្ងៃត្រូវជាប់ពន្ធនាគារតាមកម្រិតនៃអ្នកទោស និងការកាត់បន្ថយថ្ងៃត្រូវជាប់ពន្ធនាគារតាមរយៈពេលដែលចេញទៅបម្រើកិច្ចការសាធារណៈ។ ប្រការទាំងអស់នេះ ខាងពន្ធនាគារត្រូវរួមបញ្ចូលថ្ងៃកាត់បន្ថយទោសបន្សំរបស់អ្នកទោសម្នាក់ ៗ ដើម្បីស្នើឲ្យគណៈកម្មការពិចារណា និងធ្វើសំណើទៅអ្នកមានអំណាចអនុម័តដោះលែងពេលថ្ងៃកាត់បន្ថយទោសដែលបន្សំស្មើនឹងទោសដែលនៅសល់។	សៀវភៅណែនាំស្តីអំពីការប្រព្រឹត្តិក្នុងមន្ទីរឃុំឃាំង <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៦	
១៧	การสงเคราะห์ សុខមាលភាព	Welfare (n.)	ការជ្រោមជ្រែងនិងការជួយឲ្យទទួលនូវអ្វីដែលចំបាច់ក្នុងការស្តារនីតិសម្បទា ការផ្តល់ចំណេះដឹងសិក្សាអប់រំ បំណិនជីវិត ការប្រកបមុខរបរ រួមទាំងការជ្រោមជ្រែងនិងការជួយក្នុងផ្នែកផ្សេង ៗ ដែលចាំបាច់ចំពោះការរស់នៅតាមសមគួរ	នីតិវិធីក្រសួងយុត្តិធម៌ស្តីអំពីការសំយោគ ព.ស. ២៥៦០ ប្រការ ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u>	

ឧបសម្ព័ន្ធ ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				PROBATION ACT, B.E. 2559 (2016) Section 6	
១៨	การสืบเสาะและพินิจ ការស៊ើបសួរនិងវិនិច្ឆ័យ	Investigation (n.)	ការស្វែងរកការពិតនិងព័ត៌មានលម្អិតពាក់ព័ន្ធនឹងការស៊ើបសួរនិងវិនិច្ឆ័យដើម្បីប្រមូលព័ត៌មានពិត រៀបចំរបាយការណ៍ និងស្នើសំណើរយោបល់អមការពិចារណាក្តីរបស់តុលាការ ឬភ្នាក់ងារមានសមត្ថកិច្ច	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> PROBATION ACT, B.E. 2559 (2016) Section 4	
១៩	ขังเดี่ยว ការឃុំឲ្យនៅតែម្នាក់ឯង	Solitary Confinement (n.)	ការឃុំឲ្យនៅតែម្នាក់ឯងមិនលើសរយៈពេលមួយខែ ជាការដាក់ទោសសណ្ឋានមួយ ពេលអ្នកទោសប្រព្រឹត្តិខុសវិន័យពន្ធនាគារ	មាត្រា ៦៩ (៦) នៃព្រះរាជក្រឹត្យស្តីអំពីរាជទណ្ឌ ព.ស. ២៥៦០ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៧	
២០	คณะกรรมการคุมประพฤติ គណៈកម្មការគ្រប់គ្រងការប្រព្រឹត្តិ	Probation Committee (n.)	គណៈកម្មការតែងតាំងឡើងតាមព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មានអំណាចនិងតួនាទីដូចខាងក្រោម៖ (១) កំណត់គោលនយោបាយនិងទិសដៅក្នុងការគ្រប់គ្រងការងារស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ដើម្បីឲ្យសមស្របនឹង	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ១០ <u>វាក្យសព្ទភាសាអង់គ្លេស</u> 1. NARCOTIC ADDICT ACT, B.E. 2559	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ឧទាហរណ៍)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ភារកិច្ចផ្នែកការគ្រប់គ្រងការប្រព្រឹត្តិ រួមទាំងពិចារណាផ្តល់យោបល់លើបញ្ហាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការប្រព្រឹត្តិតាមដែលគណៈរដ្ឋមន្ត្រីស្នើឲ្យពិចារណា។ (២) ផ្តល់យោបល់និងប្រឹក្សាជូនរដ្ឋមន្ត្រីក្នុងការចេញច្បាប់ក្រសួង វិធាន និងប្រកាសតាមព្រះរាជក្រឹត្យនេះ រួមទាំងផ្តល់យោបល់ជូនអធិបតីក្នុងការចេញវិធានតាមព្រះរាជក្រឹត្យនេះ។ (៣) ផ្តល់ការប្រឹក្សាយោបល់ និងសំណើជូននាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ រួមទាំងផ្នែករាជការ ក្រុមការងាររបស់រដ្ឋ និងអង្គការផ្សេង ។ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការដំណើរការគ្រប់គ្រងការប្រព្រឹត្តិ។ (៤) កំណត់មាត្រាដ្ឋានការដំណើរការផ្សេង ។ របស់ភ្នាក់ងារគ្រប់គ្រងការប្រព្រឹត្តិឲ្យស្របតាមព្រះរាជក្រឹត្យនេះ រួមទាំងផ្តល់យោបល់អនុម័តកម្មវិធីសិក្សាអប់រំភ្នាក់ងារគ្រប់គ្រងការប្រព្រឹត្តិ។ (៥) ប្រតិបត្តិការផ្សេងណាតាមដែលច្បាប់កំណត់ឲ្យស្ថិតនៅក្រោមអំណាចតួនាទីរបស់គណៈកម្មការ ឬតាមដែលរដ្ឋមន្ត្រីប្រគល់ជូន	(2016) Section 4 (The Probation Commission) ២. បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ឧទាហរណ៍)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
២១	คณะกรรมการฟื้นฟูสมรรถภาพผู้ติดยาเสพติด គណៈកម្មការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន	The committee on Rehabilitation of Narcotic Addict (n.)	គណៈកម្មការតែងតាំងឡើងតាមព្រះរាជក្រឹត្យស្តីអំពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៥ (១) ធ្វើសំណើទៅរដ្ឋមន្ត្រីពាក់ព័ន្ធនឹងការចេញច្បាប់ក្រសួងតាមព្រះរាជក្រឹត្យនេះ (២) ធ្វើសំណើទៅរដ្ឋមន្ត្រីក្នុងការប្រកាសស្តីអំពីមជ្ឈមណ្ឌលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមមាត្រា ១៤ និងមាត្រា ១៦ (៣) តែងតាំងនិងដកអនុគណៈកម្មការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (៤) រៀបចំគោលការណ៍និងនីតិវិធីការពិចារណារបស់គណៈកម្មការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមមាត្រា ១៣ (៥) ស្នើយោបល់ចំពោះរដ្ឋមន្ត្រីក្នុងការកំណត់ទីតាំងដើម្បីធ្វើតេស្តការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនឬការឃុំខ្លួន (៦) រៀបចំគោលការណ៍និងនីតិវិធីការធ្វើតេស្តការស្តារនីតិសម្បទាឬការញៀនគ្រឿងញៀន ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននិងបញ្ជូនខ្លួនទៅទទួលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនទៅឲ្យភ្នាក់ងារស៊ើបសួរឬភ្នាក់ងារអយ្យការ (៧) រៀបចំគោលការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការប្តូរទីកន្លែងជនជាប់ចោទក្នុងកំលុងពេលការធ្វើតេស្តឬការស្តារនីតិ	រាជក្រឹត្យស្តីអំពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៥ មាត្រា ៧ វាក្យសព្ទភាសាអង់គ្លេស REHABILTATION OF NARCOTIC ADDICT ACT, B.E. 2545 (2002) Section 4	

ជំពូក ៣ ឃាក្យសព្ទក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			សម្បទាអ្នកញៀនគ្រឿងញៀន (៨) រៀបចំគោលការណ៍ នីតិវិធី និងលក្ខខណ្ឌក្នុងការពិចារណាអនុញ្ញាតឲ្យដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន (៩) រៀបចំគោលការណ៍និងលក្ខខណ្ឌក្នុងការត្រួតពិនិត្យនិងតាមដានលទ្ធផលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់អ្នកបានទទួលអនុញ្ញាតឲ្យដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន (១០) ពិចារណាវិនិច្ឆ័យឧទ្ធរណ៍លើការវិនិច្ឆ័យឬបទបញ្ជារបស់អនុគណៈកម្មការការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមមាត្រា ៣៨ (១១) រៀបចំវិធានពាក់ព័ន្ធនឹងការសួរសុខទុក្ខនិងការទាក់ទងអ្នកចូលមកទទួលការធ្វើតេស្តឬអ្នកទទួលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនក្នុងកំលុងពេលនៃការធ្វើតេស្តឬការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (១២) រៀបចំគោលការណ៍ក្នុងការកាត់បន្ថយនិងពង្រីករយៈពេលនៃការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន (១៣) រៀបចំគោលការណ៍និងនីតិវិធីការរាយការណ៍លទ្ធផលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជូនចំពោះគណៈកម្មការ និងនីតិវិធីការរាយការណ៍លទ្ធការធ្វើតេស្ត រួមទាំងលទ្ធផលនៃការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនជូនចំពោះ		

ឧបសម្ព័ន្ធ ៣ ឧទាហរណ៍នៃវាក្យសព្ទក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ភ្នាក់ងារស៊ើបសួរឬភ្នាក់ងារអយ្យការ (១៤) រៀបចំគោលការណ៍ក្នុងការពិចារណាដាក់ទោសជនល្មើសឬជនមិនប្រតិបត្តិតាមវិធាន លក្ខខណ្ឌ និងបទបញ្ជាតាមមាត្រា ៣២ (១៥) រៀបចំវិធានផ្សេង ៗ ទៀតដោយអនុវត្តតាមព្រះរាជក្រឹត្យនេះ។ (១៦) ពិចារណារឿងផ្សេង ៗ តាមដែលរដ្ឋមន្ត្រីប្រគល់ជូននិងប្រតិបត្តិការផ្សេងណាដែលច្បាប់កំណត់ឲ្យប្រើអំណាចនិងតួនាទីរបស់គណៈកម្មការ។		
២២	គណៈកម្មការរាជទណ្ឌ คณะกรรมการราชทัณฑ์ คณะกรรมการราชทัณฑ์	Corrections Committee (n.)	គណៈកម្មការតែងតាំងឡើងតាមព្រះរាជក្រឹត្យស្តីអំពីការងារាជទណ្ឌ ព.ស. ២៥៦០ មានអំណាចនិងតួនាទីដូចខាងក្រោមនេះ៖ (១) កំណត់គោលនយោបាយនិងទិសដៅក្នុងការគ្រប់គ្រងការងារាជទណ្ឌដើម្បីឲ្យសមស្របនឹងកិច្ចការផ្នែកការងារាជទណ្ឌយ៉ាងមានប្រសិទ្ធភាព រួមទាំង ពិចារណាផ្តល់យោបល់ពាក់ព័ន្ធនឹងការគ្រប់គ្រងការងារាជទណ្ឌតាមដែលគណៈរដ្ឋមន្ត្រីស្នើឲ្យពិចារណា (២) ផ្តល់យោបល់ប្រឹក្សាដល់រដ្ឋមន្ត្រីក្នុងការចេញច្បាប់ វិធាននិងប្រកាសតាមព្រះរាជក្រឹត្យនេះ រួមទាំងផ្តល់យោបល់ជូនអធិបតីក្នុងការរៀបចំវិធាននាយកដ្ឋានរាជទណ្ឌ	ព្រះរាជក្រឹត្យស្តីអំពីរាជទណ្ឌ ព.ស. ២៥៦០ មាត្រា ១២ วาក្យសព្ទภาสาអង់គ្លេส Corrections Act, B.E. 2560	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ឧទាហរណ៍)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			(៣) ផ្តល់យោបល់យល់ស្របការអនុម័តច្បាប់ក្រសួង វិធាន ឬការប្រកាសតាមដែលកំណត់ក្នុងព្រះរាជក្រឹត្យនេះ (៤) កំណត់ឬស្នើនីតិវិធី យុទ្ធសាស្ត្រ និងវិធានការក្នុងការកែសម្រួលនិងអភិវឌ្ឍកិច្ចការការគ្រប់គ្រងការងាររាជទណ្ឌឬដំណើរការតាមផ្នែកការគ្រប់គ្រងការងាររាជទណ្ឌឲ្យប្រព្រឹត្តិទៅយ៉ាងមានប្រសិទ្ធភាពនិងលទ្ធផលល្អ រួមទាំងវិធានការក្នុងការអភិវឌ្ឍព្រឹត្តិនិស្ស័យជនជាប់ឃុំឃាំងឲ្យក្លាយជាមនុស្សល្អត្រៀមទុកមុនពេលដោះលែងជនជាប់ឃុំឃាំង និងការគ្រប់គ្រងជួយសង្គ្រោះជនជាប់ឃុំឃាំងក្រោយពេលដោះលែងដើម្បីកុំឲ្យត្រលប់ទៅប្រព្រឹត្តិបទល្មើសដដែល និងផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រី ក្រុមការងាររបស់រដ្ឋ ឬអង្គការដែលពាក់ព័ន្ធនឹងការអភិវឌ្ឍព្រឹត្តិនិស្ស័យជនត្រូវជាប់ឃុំឃាំងនិងការគ្រប់គ្រងជួយសង្គ្រោះជនជាប់ឃុំឃាំងក្រោយពេលដោះលែងដើម្បីពិចារណា (៥) កំណត់មាត្រាដ្ឋានការដំណើរការក្នុងផ្នែកផ្សេង ៗ របស់ពន្ធនាគារឲ្យស្របតាមព្រះរាជក្រឹត្យនេះ (៦) ប្រតិបត្តិការផ្សេងទៀតតាមដែលកំណត់ក្នុងព្រះរាជក្រឹត្យនេះឬច្បាប់ផ្សេង។		
២៣	คำพิพากษาอันถึงที่สุด សាលក្រមសម្រេច	Final judgement (n.)	រឿងក្តីដែលសាលាដំបូងឬសាលាឧទ្ធរណ៍ចេញសាលក្រមឬសេចក្តីសម្រេចហើយគូវិវាទពុំអាចប្តឹងឧទ្ធរណ៍ឬតុលាការកំពូលទៀតបានតាមច្បាប់ឬរឿងក្តីដែលគូវិវាទមានសិទ្ធិប្តឹង	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ១៤៣	

ឧបសម្ព័ន្ធ ៣ វាក្យសព្ទក្នុងដំណើរការកាត់ក្តីដល់ទីបញ្ចប់ (៥៥ វាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ឧទ្ធរណ៍ឬសាលាកំពូលបាន តែគូវិវាទពុំបានប្រើសិទ្ធិប្តឹងឧទ្ធរណ៍ឬតុលាការកំពូលក្នុងរយៈពេលដែលច្បាប់កំណត់ ឬរឿងក្តីដែលតុលាការកំពូលចេញសាលក្រមឬសេចក្តី សម្រេច។	<u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៤	
២៤	เครื่องพันธนาการ សម្ភារពន្ធនាគារ	Instruments of restraint (n.)	សម្ភារពន្ធនាគារដែលត្រូវប្រើចំពោះជនត្រូវជាប់ឃុំឃាំងមាន ៥ ប្រភេទ គឺ៖ (១) ខ្សែចំណង (២) ខ្នោះដៃ (៣) ខ្នោះជើង (៤) ខ្នោះដោះនិងខ្នោះជើង (៥) ច្រវាក់	ច្បាប់ក្រសួងមហាផ្ទៃចែងតាមខ្លឹមសារក្នុងមាត្រា ៥៨ នៃព្រះរាជក្រឹត្យស្តីអំពីរាជទណ្ឌ ព.ស. ២៤៧៩ ប្រការ ២៥ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៦	
២៥	เงื่อนไขเพื่อคุมความประพฤติ លក្ខខណ្ឌដើម្បីគ្រប់គ្រងការប្រព្រឹត្តិ	Probation conditions (n.)	ជនណាប្រព្រឹត្តិបទល្មើសដែលមានទោសជាប់ពន្ធនាគារឬពិន័យ ក្នុងរឿងក្តីនោះ តុលាការត្រូវដាក់ទោសជាប់ពន្ធនាគារមិនលើសពីប្រាំឆ្នាំមិនថាមានទោសពិន័យរួមជាមួយឬអត់ក្តីឬដាក់ទោសជាពិន័យ ប្រសិនបើជននោះ៖ (១) ពុំធ្លាប់ទទួលទោសជាប់ពន្ធនាគារពីមុនមក ឬ (២) ធ្លាប់ទទួលទោសជាប់ពន្ធនាគារពីមុនមកតែជាទោសនៃ	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៥៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយ	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ឧទាហរណ៍)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			បទល្មើសដែលបានប្រព្រឹត្តិដោយការធ្វេសប្រហែស ឬបទល្មើសទោសសហុ ឬជាទោសជាប់ពន្ធនាគារមិនលើសប្រាំមួយខែ ឬ (៣) ធ្លាប់ទទួលទោសជាប់ពន្ធនាគារពីមុនមកតែជុតទោសជាប់ពន្ធនាគារហើយលើពីប្រាំឆ្នាំ ហើយមកប្រព្រឹត្តិបទល្មើសជាថ្មីទៀត ដោយបទល្មើសលើកក្រោយជាបទល្មើសដែលបានប្រព្រឹត្តិដោយការធ្វេសប្រហែស ឬបទល្មើសទោសសហុ និងពេលតុលាការវិនិច្ឆ័យអំពីអាយុ ប្រវត្តិ ការប្រព្រឹត្តិ សតិបញ្ញា កម្រិតវប្បធម៌ សុខភាពផ្លូវកាយ សុខភាពផ្លូវចិត្ត អត្តចរិត អាជីព ឬការដឹងកំហុស និងព្យាយាមកាត់បន្ថយគុណវិបត្តិដែលកើតឡើង ឬហេតុផលផ្សេងដែលគួរប្រោសប្រណីតុលាការអាចកាត់សេចក្តីថាជននោះមានទោសតែត្រូវផ្សារទោសឬកំណត់ទោសតែរងចាំការដាក់ទោស មិនថាជាទោសជាប់ពន្ធនាគារឬពិន័យបែបណាមួយឬទាំងពីរបែប ដើម្បីផ្តល់ឱកាសកសាងខ្លួនក្នុងរយៈពេលដែលតុលាការបានកំណត់តែមិនត្រូវឲ្យលើសពីប្រាំឆ្នាំគិតចាប់ពីថ្ងៃដែលចេញសាលក្រម ដោយត្រូវកំណត់លក្ខខណ្ឌដើម្បីគ្រប់គ្រងការប្រព្រឹត្តិរបស់ជននោះផងឬអត់ក៏បាន។ លក្ខខណ្ឌដើម្បីគ្រប់គ្រងការប្រព្រឹត្តិរបស់ជនល្មើសតាមប្រការមួយ តុលាការអាចកំណត់មួយករណីឬច្រើនករណីតាមភាពសមស្របនៃករណីបាន ដូចខាងក្រោមនេះ៖ (១) តម្រូវឲ្យបង្ហាញមុនចំពោះភ្នាក់ងារមានសមត្ថកិច្ចដែល	ការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៦៥	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការពារក្តីដល់ចឹមប្លង់ (៥៥ ឧទាហរណ៍)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			តុលាការកំណត់ជាបណ្តោះអាសន្ន ដើម្បីភ្នាក់ងារមានសមត្ថកិច្ចបានសាកសួរ ណែនាំ ជួយ ឬដាស់តឿនតាមដែលយល់ឃើញថាសមស្របចំពោះការប្រព្រឹត្តិនិងការប្រកបមុខរបរ ឬរៀបចំឲ្យធ្វើសកម្មភាពបម្រើសង្គមឬប្រយោជន៍សាធារណៈ: (២) តម្រូវឲ្យហ្វឹកហាត់ឬធ្វើការងារដែលជាកាតព្វកិច្ច (៣) តម្រូវឲ្យចៀសវាងការសេពគប់ឬការប្រព្រឹត្តិណាដែលអាចនាំទៅរកការប្រព្រឹត្តិបទល្មើសក្នុងករណីដូចគ្នាទៀត (៤) តម្រូវឲ្យកែសម្រួលការពិនិត្យព្យាបាលឬការស្តារនីតិសម្បទាដែលផ្តល់គុណវិបត្តិដល់សុខភាពផ្លូវកាយឬសុខភាពផ្លូវចិត្ត ឬការឈឺថ្កាត់ផ្សេង ។ នៅក្នុងមណ្ឌលនិងតាមរយៈពេលដែលតុលាការកំណត់ (៥) តម្រូវឲ្យទទួលការសិក្សាអប់រំនៅក្នុងមណ្ឌលនិងតាមរយៈពេលដែលតុលាការកំណត់ (៦) ហាមចេញក្រៅកន្លែងរស់នៅ ឬហាមចូលក្នុងកន្លែងណាមួយក្នុងកំលុងពេលដែលតុលាការកំណត់ ដោយត្រូវប្រើឧបករណ៍អេឡិចត្រូនិចឬឧបករណ៍ផ្សេង ។ ណាដែលអាចត្រួតពិនិត្យឬកំណត់ការធ្វើដំណើរជាមួយផងក៏បាន (៧) តម្រូវឲ្យសងឬប៉ះប៉ូវថ្លៃខូចខាតដោយវិធីផ្សេងដល់ជនរងគ្រោះតាមដែលជនល្មើសនិងជនរងគ្រោះស្រុះស្រួលគ្នា (៨) តម្រូវឲ្យកែសម្រួល ស្តារ ឬសងប៉ះប៉ូវថ្លៃខូចខាតដែលកើត		

ជំពូក ៣ ឧបសគ្គក្នុងដំណើរការការពារក្តីដល់ដីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ចំពោះធនធានធម្មជាតិ ឬបរិស្ថាន ឬសងថ្លៃខូចខាតដើម្បីកិច្ចការខាងលើ (៩) តម្រូវឲ្យជាប់ពិន័យដោយកំណត់ចំនួនទឹកប្រាក់តាមដែលតុលាការយល់ឃើញសមស្របថានឹងមិនបង្កអន្តរាយ ឬគ្រោះថ្នាក់ដល់បុគ្គលផ្សេងឬទ្រព្យសម្បត្តិ (១០) លក្ខខណ្ឌផ្សេង ៗ តាមដែលតុលាការយល់ឃើញសមស្របក្នុងការកំណត់ដើម្បីដោះស្រាយ ស្តារ ឬការពារមិនឲ្យជនល្មើសប្រព្រឹត្តិឬមានឱកាសប្រព្រឹត្តិបទល្មើសទៀត ឬលក្ខខណ្ឌក្នុងការសងប៉ះប៉ូវជនរងគ្រោះតាមការយល់ថាសមស្រប។ លក្ខខណ្ឌតាមដែលតុលាការបានកំណត់តាមសេចក្តីក្នុងប្រការពីរនោះ ប្រសិនបើក្រោយមកប្រាកដចំពោះតុលាការតាមសំណើរបស់ជនល្មើស អ្នកតំណាងដោយស្មុចរិតរបស់ជននោះ អ្នកជាអាណាព្យាបាលរបស់ជននោះ ភ្នាក់ងារអយ្យការឬភ្នាក់ងារមានសមត្ថកិច្ចថាព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការប្រព្រឹត្តិរបស់ជនល្មើសបានផ្លាស់ប្តូរ ពេលតុលាការយល់ឃើញថាសមស្របតុលាការអាចកែសម្រួលបន្ថែមឬដកករណីណាមួយចោលក៏បាន ឬអាចកំណត់លក្ខខណ្ឌនៃករណីណាដែលនិយាយក្នុងប្រការពីរដែលតុលាការពុំទាន់បានកំណត់បន្ថែមទៀតក៏បាន ឬបើមានការប្រព្រឹត្តិល្មើសទណ្ឌបទត្រូវយកបទបញ្ញត្តិមាត្រា ៤៧ មកអនុវត្តដោយអនុលោម។		

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
២៦	ចេតនា (จงใจ) ចេតនា (มานบំណង)	Intent (Deliberately) (v.)	១. ប្រព្រឹត្តិដោយដឹងខ្លួនក្នុងការដែលប្រព្រឹត្តិនិងក្នុងពេលជាមួយគ្នាជនប្រព្រឹត្តិមានបំណងចង់បានផលប្រយោជន៍ ឬសន្លឹងឃើញផលប្រយោជន៍នៃការប្រព្រឹត្តិនោះ និងផ្តល់និយមន័យរួមដល់ការផ្តល់ផលប្រយោជន៍ណាមួយដែលកើតឡើងដោយការមិនធ្វើដើម្បីការពារផលប្រយោជន៍នោះ។ ២. ការប្រព្រឹត្តិដោយមានចេតនាឬតាំងចិត្តក្នុងការប្រព្រឹត្តិទង្វើទាំងនោះ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៥៩ ប្រការពីរ និងប្រការប្រាំ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់ រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៧៩	
២៧	เจ้าพนักงานเรือนจำ មន្ត្រីពន្ធនាគារ	Prison official (n.)	អ្នកដែលមានគុណសម្បត្តិតាមដែលរដ្ឋមន្ត្រីប្រកាសកំណត់និងអធិបតីបានតែងតាំង ដើម្បីប្រតិបត្តិការតាមព្រះរាជក្រឹត្យនេះ	រាជក្រឹតស្តីអំពីរាជទណ្ឌ ព.ស. ២៥៦០ មាត្រា ៤ វាក្យសព្ទភាសាអង់គ្លេស Corrections Act, B.E. 2560	
២៨	แดน ដែនកំណត់	Wing (n.)	បរិវេណ ឬផ្ទៃមួយភាគក្នុងពន្ធនាគារដែលកំណត់ជាផ្នែកៗ	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៤៤៧ វាក្យសព្ទភាសាអង់គ្លេស ឧក្រិដ្ឋកម្មវិទ្យា	
២៩	ทะเบียนประวัติผู้ต้องขัง បញ្ជីប្រវត្តិអ្នកទោស	Prisoner Record (n.)	ក្នុងថ្ងៃដែលទទួលអ្នកទោសចូលមកថ្មីក្នុងពន្ធនាគារ តម្រូវឲ្យមន្ត្រីពន្ធនាគាររៀបចំចុះបញ្ជីប្រវត្តិអ្នកទោស ដោយយ៉ាង	រាជក្រឹត្យស្តីអំពីរាជទណ្ឌ ព.ស. ២៥៦០ វាក្យសព្ទភាសាអង់គ្លេស	

ឧបសម្ព័ន្ធ ៣ វាក្យសព្ទក្នុងដំណើរការការកាត់ក្តីជាភាសាអង់គ្លេស (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ហោចណាស់ត្រូវមានព័ត៌មានលម្អិតទាក់ទងនឹងរឿងដូចខាងក្រោម៖ (១) នាមនិងនាមត្រកូលអ្នកទោស លេខអត្តសញ្ញាណប័ណ្ណ ឬឯកសារបង្ហាញខ្លួនរបស់អ្នកទោសតាមដែលមាន (២) បទចោទឬសណ្ឋានបទល្មើសដែលជននោះប្រព្រឹត្តិ (៣) ង្កិតក្រយៅដៃឬកំណត់លក្ខណៈពិសេសរបស់បុគ្គល ឬគុណវិបត្តិរូបរាង (៤) សភាពនៃរូបរាងកាយឬផ្លូវចិត្ត ចំណេះដឹងនិងសមត្ថភាព (៥) ព័ត៌មានលម្អិតផ្សេងៗ តាមដែលកំណត់ក្នុងនីតិវិធីរបស់នាយកដ្ឋានរាជទណ្ឌ។	សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៥៦	
៣០	ทั้งจำทั้งปรับ ទាំងជាប់ពន្ធនាគារទាំងពិន័យ	Punishment of imprisonment and fine (n.)	មានទោសទាំងជាប់ពន្ធនាគារនិងទាំងពិន័យជាទឹកប្រាក់	សៀវភៅវាក្យសព្ទគន្លង់ភាសាថៃផ្នែកច្បាប់, សមាគមជនពិការគន្លង់ប្រចាំប្រទេសថៃ, ទំព័រ ២១៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទគន្លង់ភាសាថៃផ្នែកច្បាប់, សមាគមជនពិការគន្លង់ប្រចាំប្រទេសថៃ, ទំព័រ ២១៨	
៣១	โทษประหารชีวิต ទោសប្រហារជីវិត	Death penalty (n.) Capital punishment (n.)	ទោសព្រហ្មទណ្ឌកម្រិតខ្ពស់បំផុតដែលដាក់ចំពោះជនល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ វិធីប្រហារជីវិតតាមបណ្តុំច្បាប់ព្រហ្មទណ្ឌ គឺការធ្វើឲ្យស្លាប់ដោយវិធីចាក់ថ្នាំឬសារធាតុពុល ដែលបញ្ញត្តិ	១. បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ	

ឧបសម្ព័ន្ធ ៣ ឧទាហរណ៍ក្នុងដំណើរការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ក្នុងបណ្តុំច្បាប់ព្រហ្មទណ្ឌ មាត្រា ១៩ ថា ជនណាជាប់ទោសប្រហារជីវិត តម្រូវឲ្យដំណើរការដោយវិធីចាក់ថ្នាំឬសារធាតុពុលឲ្យស្លាប់។	បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ១៩ ២. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា ទំព័រ ៣៥០ <u>វាក្យសព្ទភាសាអង់គ្លេស</u> ទទួលសណ្តាប់យោបល់ ៤ ភាគ	
៣២	ទោមបរ័ប ទោសពិន័យ	Punishment of fine (n.)	ទោសព្រហ្មទណ្ឌសណ្ឋានមួយ ដែលជនល្មើសត្រូវសងប្រាក់តាមចំនួនដែលតុលាការកំណត់ឬតាមដែលអ្នកមានអំណាចប្រៀបធៀបបានប្រៀបធៀប។ ម៉្យាង ក្នុងរឿងក្តីដែលមានទោសពិន័យសណ្ឋានតែមួយ បើជនប្រព្រឹត្តិយល់ព្រមបង់ថ្លៃពិន័យក្នុងអត្រាខ្ពស់សម្រាប់បទល្មើសនោះដល់ភ្នាក់ងារតុលាការមុនតុលាការពិចារណាក្តី រឿងក្តីនោះត្រូវបានបញ្ចាប់ (ប៉.អ. មាត្រា ១៨ និង ២៨ និង ប.វិ.អ. មាត្រា ៣៧)។	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ៣៥០-៣៥១ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៥	
៣៣	នักโทษ អ្នកទោស	Prisoner (n.) Inmate (n.)	១. បុគ្គលដែលត្រូវដាក់ទោសចាប់ពីទោសជាប់ពន្ធនាគារឡើងទៅ ២. បុគ្គលដែលត្រូវដំណើរការក្តីនិងត្រូវតុលាការចេញសាលក្រមដាក់ទោសជាប់ពន្ធនាគារ	១. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ២៨៦ ២. សៀវភៅវាក្យសព្ទគន្លងភាសាថៃផ្នែកច្បាប់, សមាគមជនពិការគន្លងប្រចាំប្រទេសថៃ, ទំព័រ ៧៨	

ជំពូក ៣ ឧាក្យសព្ទក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				<u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៣០ ២. Corrections Act B.E. 2560 (English Version) ទំព័រ 3	
៣៤	นักโทษเด็ดขาด ជនត្រូវបានកាត់ទោស	Convicted prisoner (n.)	បុគ្គលដែលត្រូវជាប់ឃុំឃាំងតាមសាលក្រមក្រោយពេលកាត់ក្តីសម្រេច និងមានន័យរួមលើបុគ្គលដែលត្រូវជាប់ឃុំឃាំងតាមសេចក្តីបង្គាប់ដែលត្រឹមត្រូវដោយច្បាប់តម្រូវឲ្យជាប់ទោស	រាជក្រឹត្យស្តីអំពីរាជទណ្ឌ ព.ស. ២៥៦០ <u>វាក្យសព្ទភាសាអង់គ្លេស</u> Corrections Act B.E. 2560 (English Version) ទំព័រ 3	
៣៥	บวกโทษที่รอไว้ បូកទោសដែលនៅសល់	To add to a suspended sentence (v.)	(ពុំមាននិយមន័យនៃការបូកទោសដែលនៅសល់ មានតែករណីដែលតុលាការចេញបណ្តាបូកទោសដែលនៅសល់) ពេលរឿងក្តីប្រាកដចំពោះមុខតុលាការ ឬរឿងក្តីប្រាកដតាមការថ្លែងរបស់ដើមបណ្តឹងឬភ្នាក់ងារមានសមត្ថកិច្ចថា ក្នុងពេលដែលសាលក្រមកំណត់តាមមាត្រា ៥៦ ជនដែលត្រូវតុលាការកាត់ក្តីថាបានប្រព្រឹត្តិបទល្មើសដែលពុំមែនជាបទល្មើសដែលបានធ្វើដោយការធ្វេសប្រហែសឬបទល្មើសទោសលហុ និងតុលាការកាត់សេចក្តីឲ្យជាប់ពន្ធនាគារចំពោះបទល្មើសនេះ តម្រូវឲ្យតុលាការដែលកាត់ក្តីក្រោយ កំណត់ទោសដែលនៅសល់ដែលបានកំណត់ទុកក្នុងរឿងក្តីមុន បូកបញ្ចូលជាមួយទៅក្នុងរឿងក្តីបន្ទាប់។	បណ្តុំច្បាប់ព្រហ្មទណ្ឌ មាត្រា ៥៨	

ឧបសម្ព័ន្ធ ៣ វាក្យសព្ទក្នុងដំណើរការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៣៦	ผู้คุม មន្ត្រីពន្ធនាគារ	Custodial officer (n.)	ភ្នាក់ងារមានសមត្ថកិច្ចដែលគ្រប់គ្រងអ្នកទោស	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៧៨៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៦១ ២. សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយ ការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ២០	
៣៧	ผู้ถูกคุมความประพฤติ ជនត្រូវគេគ្រប់គ្រងការប្រព្រឹត្តិ	Probationer (n.)	ជនជាប់ចោទ ចុងចោទ អ្នកទោស ឬបុគ្គលផ្សេងដែលតុលាការឬភ្នាក់ងារមានសមត្ថកិច្ច កំណត់ឲ្យប្រតិបត្តិតាមលក្ខខណ្ឌដែលច្បាប់បញ្ញត្តិក្រោមការគ្រប់គ្រងការប្រព្រឹត្តិរបស់ភ្នាក់ងារគ្រប់គ្រងការប្រព្រឹត្តិ	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> PROBATION ACT, B.E. 2559 (2016) Section 4	
៣៨	ผู้บัญชาการเรือนจำ ប្រធានពន្ធនាគារ	Superintendent (n.) Prison director (n.) Prison Governor (UK) (n.) Warden (US) (n.)	មេបញ្ជាការពន្ធនាការ ឬប្រធានពន្ធនាគារ	នីតិវិធីនាយកដ្ឋានរាជទណ្ឌស្តីអំពីការពន្យាពេលនិងបន្តយកម្រិតថ្នាក់អ្នកទោសស្តាពរ ព.ស. ២៥៥៦ ប្រការ ៥	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				<u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ១៧	
៣៩	ผู้อำนวยการสำนักงานคุมประพฤติ ប្រធានការិយាល័យគ្រប់គ្រងការប្រព្រឹត្តិ	Director of probation Office (n.)	ប្រធានដែលត្រូវបានតែងតាំងតាមព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩	នីតិវិធីក្រសួងយុត្តិធម៌ស្តីអំពីគោលការណ៍នីតិវិធី និងលក្ខខណ្ឌទាក់ទងនឹងការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៦០ ទំព័រ ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> PROBATION ACT, B.E. 2559 (2016) Section 38	
៤០	แผนการฟื้นฟูสมรรถภาพผู้ติดยาเสพติด ផែនការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន	Rehabilitation plan (n.)	ការកំណត់ទីតាំងនិងនីតិវិធីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនចែកជា ២ ករណី គឺករណីស្តារប្រភេទឃុំខ្លួននិងករណីស្តារប្រភេទមិនឃុំខ្លួន។	ព្រះរាជក្រឹត្យស្តីអំពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៥ <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
៤១	พนักงานคุมประพฤติ មន្ត្រីគ្រប់គ្រងការប្រព្រឹត្តិ	Probation Office (n.)	អ្នកដែលរដ្ឋមន្ត្រីតែងតាំងឲ្យមានអំណាចតួនាទីក្នុងការគ្រប់គ្រងការប្រព្រឹត្តិតាមព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៦០	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ៤	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				<u>វាក្យសព្ទភាសាអង់គ្លេស</u> PROBATION ACT, B.E. 2559 (2016) Section 4	
៤២	พระราชทานอภัยโทษ ព្រះរាជទានលើកលែងទោស	Royal Pardon grant (n.)	១. ការលើកលែងទោស ប្តូរទោសធ្ងន់ទៅជាទោសស្រាល ឬកាត់បន្ថយទោស ២. ការព្រះរាជទានលើកលែងទោសពីព្រះមហាក្សត្រដល់អ្នកទោសដែលសាលក្រមចេញសេចក្តីសម្រេចហើយ ឲ្យបានទទួលការដោះលែងឬកាត់បន្ថយទោសអាស្រ័យលើករណីដែលអាស្រ័យលើព្រះរាជវិនិច្ឆ័យរបស់ព្រះមហាក្សត្រ តាមព្រះរាជអំណាចដែលកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ	១. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ៥៩៦ ២. ផ្នែកការលើកលែងទោស នាយកដ្ឋានរាជទណ្ឌ <u>វាក្យសព្ទភាសាអង់គ្លេស</u> គេហទំព័រនាយកដ្ឋានរាជទណ្ឌ ប្រធានបទការលើកលែងទោស	
៤៣	พักการลงโทษ ការបញ្ឈប់ទោស	Parole (n.)	ការដោះលែងឲ្យអ្នកទោសស្តារពដែលត្រូវជាប់ពន្ធនាគារតាមសាលក្រមរបស់តុលាការហើយមិនតិចជាង ១ ភាគ ៣ នៃកំណត់ទោសតាមសាលក្រម និងកំលុងពេលជាប់ពន្ធនាគារមានការប្រព្រឹត្តិល្អ មានសេចក្តីឧស្សាហ៍ព្យាយាមលេចធ្លោក្នុងការសិក្សាអប់រំ ឬសាងគុណសម្បត្តិដល់រាជការជាពិសេសឲ្យចេញទៅនៅខាងក្រៅពន្ធនាគារមុនពេលគ្រប់កំណត់ទោសតាមសាលក្រម ដោយកំណត់លក្ខខណ្ឌឲ្យប្រតិបត្តិ។	និក្ខេបបទ ទស្សនៈរបស់អាជ្ញាធររាជទណ្ឌចំពោះការដោះលែងជនត្រូវឃុំខ្លួនមុនគ្រប់កំណត់ទោស ទំព័រ ៨, ៩, ២៦ ដោយ សរ ពង្ស សេដ្ឋសនិទ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៣៦	

ឧបសម្ព័ន្ធ ៣ ឧទាហរណ៍ពាក្យសព្ទក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៤៤	พัฒนาพฤตินิสัย ការស្តារនីតិសម្បទា	Rehabilitation (n.)	ការដោះស្រាយ បំបាត់ ស្តារ និងអភិវឌ្ឍជនជាប់ឃុំឃាំង ដើម្បីឲ្យក្លាយជាមនុស្សល្អ	នីតិវិធីនាយកដ្ឋានរាជទណ្ឌដែលទាក់ទងនឹងការអភិវឌ្ឍព្រឹត្តិនិស្ស័យជនត្រូវឃុំឃាំង ព.ស. ២៥៦១ ប្រការ ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ៨	
៤៥	เพิกถอนอำนาจปกครอง ការដកសិទ្ធិគ្រប់គ្រង	Revocation of governing authority (n.) Revocation of parenting authority (n.)	(មិនមានការឲ្យនិយមន័យការដកសិទ្ធិគ្រប់គ្រងដោយផ្ទាល់ក្នុងច្បាប់ មានតែករណីដែលតុលាការចេញបញ្ជាឲ្យដកសិទ្ធិការគ្រប់គ្រង) បើអ្នកប្រើសិទ្ធិគ្រប់គ្រងជាអ្នកអសមត្ថភាពឬពុំអាចបំពេញតួនាទីតាមសេចក្តីបញ្ជារបស់តុលាការក្តី ប្រើសិទ្ធិគ្រប់គ្រងលើអនីតិជនដោយពុំសុចរិតក្តី ប្រព្រឹត្តិអាក្រក់ក្តី ក្នុងករណីទាំងអស់នេះតុលាការនឹងចេញបញ្ជាដោយខ្លួនឯង ឬនឹងចេញបញ្ជាពេលសាច់ញាតិរបស់អនីតិជនឬអយ្យការស្នើសុំឲ្យដកសិទ្ធិគ្រប់គ្រងចេញខ្លះឬទាំងអស់ក៏បាន។	បណ្តុំច្បាប់រដ្ឋប្បវេណីនិងពាណិជ្ជកម្ម មាត្រា ១៥៨២	
៤៦	เพิ่มโทษฐานไม่เข็ดหลาบ បន្ថែមទោសទណ្ឌពីបទមិនរាងចាល	To increase the penalty due to recidivism / repeat offense (n.)	(ការបន្ថែមទោសដោយសារបានប្រព្រឹត្តិល្មើសម្តងទៀត) ជនណាត្រូវសាលក្រមសម្រេចឲ្យជាប់ពន្ធនាគារនិងប្រព្រឹត្តិបទល្មើសណាមួយក្នុងកំលុងពេលដែលកំពុងមានទោស ឬក្រោយពេលមានទោសប្រាំឆ្នាំគិតចាប់ពីថ្ងៃរួចទោស បើរឿងក្តីកើតឡើងក្រោយពេលសាលក្រមដាក់ទោសជាប់ពន្ធនាគារ	បណ្តុំច្បាប់ព្រហ្មទណ្ឌ មាត្រា ៩២-៩៣	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ត្រូវបន្ថែមទោសមួយភាគបីនៃទោសដែលតុលាការកំណត់សម្រាប់បទល្មើសលើកក្រោយ។		
៤៧	เรือนจำ ពន្ធនាគារ	Prison (n.) Correctional Institution (n.)	គុក ឬ កន្លែងដែលប្រើសម្រាប់ឃុំ ឃាំង ឬឃុំខ្លួនអ្នកត្រូវជាប់ឃុំឃាំង ជាទីកន្លែងដែលត្រូវប្រើជាបន្តបន្ទាប់ និងមានន័យរួមដល់ទីកន្លែងដទៃដែលរដ្ឋមន្ត្រីបានកំណត់និងប្រកាសក្នុងអនុក្រឹត្យកំណត់ព្រំដែនដោយច្បាស់លាស់។	ព្រះរាជក្រឹត្យស្តីអំពីរាជទណ្ឌ ព.ស. ២៥៦០ មាត្រា ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា នាយកដ្ឋានរាជទណ្ឌ ទំព័រ ១៧	
៤៨	ศูนย์ฟื้นฟูสมรรถภาพผู้ติดยาเสพติด មជ្ឈមណ្ឌលស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន	Drug Addicts Rehabilitation Center (n.)	កន្លែងស្ដារសមត្ថភាពនិងអប់រំកែប្រែអ្នកញៀនគ្រឿងញៀនក្នុងសង្កាត់នាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ ក្រសួងយុត្តិធម៌	នីតិវិធីគណៈកម្មការស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនស្តីអំពីការធ្វើតេស្ត ការស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការឃាត់ខ្លួន និងការអនុវត្តចំពោះអ្នកមកធ្វើតេស្តនិងអ្នកចូលមកទទួលការស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៦ ប្រការ ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៥០	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៤៩	สถานที่ เพื่อการตรวจพิสูจน์ កន្លែងពិសោធធ្វើតេស្ត	Facilities for identification (n.)	ទីកន្លែងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចេញសេចក្តីប្រកាសក្នុងអនុក្រឹត្យឲ្យក្លាយជាកន្លែងពិសោធធ្វើតេស្តតាមមាត្រា ១៨ នៃព្រះរាជក្រឹត្យស្តីអំពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៥	នីតិវិធីគណៈកម្មការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនស្តីអំពីការធ្វើតេស្ត ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការឃាត់ខ្លួន និងការអនុវត្តចំពោះអ្នកមកធ្វើតេស្តនិងអ្នកចូលមកទទួលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៦ ប្រការ ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
៥០	สถานที่ฟื้นฟูสมรรถภาพ ผู้ติดยาเสพติด មជ្ឈមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន	Localities for rehabilitation (n.)	ទីកន្លែងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្រកាសក្នុងអនុក្រឹត្យឲ្យក្លាយជាកន្លែងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន តាមមាត្រា ១៨ នៃព្រះរាជក្រឹត្យស្តីអំពីការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៥	នីតិវិធីគណៈកម្មការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនស្តីអំពីការធ្វើតេស្ត ការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ការឃាត់ខ្លួន និងការអនុវត្តចំពោះអ្នកមកធ្វើតេស្តនិងអ្នកចូលមកទទួលការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ព.ស. ២៥៤៦ ប្រការ ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	

ជំពូក ៣ ឧទាហរណ៍ក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥១	สถานพินิจ មណ្ឌលអប់រំកែប្រែ	Detention center (n.) Detention home (n.)	កន្លែងអប់រំកែប្រែនិងគ្រប់គ្រងកុមារនិងយុវជន	ព្រះរាជក្រឹត្យស្តីពីការគ្រប់គ្រងដោះស្រាយស្ថានីតិសម្បទាកុមារនិងយុវជនដែលប្រព្រឹត្តិល្មើស ព.ស. ២៥៦១ មាត្រា ៣ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់ រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៧៣៩	
៥២	สำนักงานคุมประพฤติ ការិយាល័យគ្រប់គ្រងការប្រព្រឹត្តិ	Probation office (n.)	ការិយាល័យគ្រប់គ្រងការប្រព្រឹត្តិក្នុងសង្កាត់នាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ៤ វាក្យសព្ទភាសាអង់គ្លេស 9. PROBATION ACT, B.E. 2559 (2016) Section 4 ២. បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
៥៣	สูทกรรม ផ្ទះបាយពន្ធនាគារ	Prison kitchen (n.)	ផ្ទះបាយ ឬទីកន្លែងចម្អិនអាហាររបស់អ្នកទោស	វាក្យសព្ទអធិប្បាយពីនាយកដ្ឋានរាជទណ្ឌ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ២០	

ឧបសម្ព័ន្ធ ៣ ឧបសម្ព័ន្ធ ៣ វាក្យសព្ទក្នុងដំណើរការការកាត់ក្តីដល់ទីបញ្ចប់ (៥៥ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥៤	អាសាសម័ក្រគុំប្រះពឤតិ អ្នកស្ម័គ្រចិត្តការងារគ្រប់គ្រងការប្រព្រឹត្តិ	Volunteer Probation Officer – VPO (n.)	អ្នកដែលប្រធានតែងតាំងឲ្យបំពេញតួនាទីជួយមន្ត្រីគ្រប់គ្រងការប្រព្រឹត្តិតាមព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រង់ការប្រព្រឹត្តិ ព.ស. ២៥៥៩	ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការប្រព្រឹត្តិ ព.ស. ២៥៥៩ មាត្រា ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពីនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ	
៥៥	อุปกรณ์อิเล็กทรอนิกส์ในการติดตามตัว ឧបករណ៍ត្រួតពិនិត្យ	Electronic Monitoring (n.)	ឧបករណ៍អេឡិចត្រូនិចសម្រាប់ទទួលនិងបញ្ជូនសញ្ញា រួមជាមួយឧបករណ៍ដែលពាក់ព័ន្ធ ដើម្បីប្រើក្នុងការតាមដានត្រួតពិនិត្យការប្រែប្រួលឬទីកន្លែងរបស់អ្នកត្រូវគេគ្រប់គ្រងការប្រព្រឹត្តិតាមលក្ខខណ្ឌដែលតុលាការឬភ្នាក់ងារមានសមត្ថកិច្ចបញ្ជា ដូចជា ការហាមចេញ ឬហាមចូលបរិវេណដែលកំណត់ដោយមានការកំណត់រយៈពេលដែរក៏បាន ដែលនឹងដំណើរការផ្គូបគ្នានឹងវិធានការការស្តារនីតិសម្បទា។	សៀវភៅចំណេះដឹងទូទៅទាក់ទងនឹងឧបករណ៍អេឡិចត្រូនិចដាក់តាមខ្លួនសម្រាប់ប្រជាជន ដោយនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ ក្រសួងយុត្តិធម៌ ទំព័រ ២ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅចំណេះដឹងទូទៅទាក់ទងនឹងឧបករណ៍អេឡិចត្រូនិចដាក់តាមខ្លួនសម្រាប់ប្រជាជន ដោយនាយកដ្ឋានគ្រប់គ្រងការប្រព្រឹត្តិ ក្រសួងយុត្តិធម៌ ទំព័រ ២	

ឧបសម្ព័ន្ធ ៤ វាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
១	กฎหมาย ច្បាប់	Law (n.) Legislation (n.)	បទបញ្ជាឬសេចក្តីបង្គាប់ដែលអ្នកមានអំណាចបានចែងឡើងដើម្បីកំណត់ឲ្យបុគ្គលត្រូវអនុវត្តឬមិនអនុវត្ត ឬដើម្បីធ្វើជាគោលក្នុងការគ្រប់គ្រងប្រទេស កំណត់របៀបនៃសង្គមឬទំនាក់ទំនងរវាងបុគ្គលនិងបុគ្គល។ ច្បាប់អាចកើតពីការចែងជាលាយលក្ខណ៍អក្សរ ឬកើតឡើងពីទំនៀមទម្លាប់ប្រពៃណីដែលត្រូវបានទទួលស្គាល់។	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣៧៦	
២	กฎหมายที่มีผลย้อนหลัง ច្បាប់ដែលមានផលត្រលប់ក្រោយ	Ex post facto law (n.) Retroactive legislation (n.) Retrospective legislation (n.)	ជាទូទៅច្បាប់នឹងមិនមានផលត្រលប់ក្រោយឡើយ។ ចំណែកការចង់ឲ្យច្បាប់មានផលត្រលប់ក្រោយបាននោះជារឿងករណីលើកលែងដែលអាចត្រូវប្រតិបត្តិតាមលក្ខខណ្ឌ ២ ប្រការ គឺ ប្រការទីមួយត្រូវកំណត់ឲ្យច្បាស់លាស់ក្នុងច្បាប់នោះថា ឲ្យច្បាប់មានផលត្រលប់ក្រោយ និងប្រការទីពីរ ការបញ្ញត្តិច្បាប់ឲ្យត្រឡប់ក្រោយនោះ ត្រូវមិនទាស់ឬផ្ទុយពីរដ្ឋធម្មនុញ្ញ ព្រោះរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ប្រទេសមិនថាច្បាប់ណាៗ ក៏ពុំអាចទាស់ឬផ្ទុយបានឡើយ បើច្បាប់ណាមួយទាស់ឬផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់នោះពុំអាចប្រើបង្គាប់បានឡើយ។	អត្ថបទច្បាប់-មូលដ្ឋានទិន្នន័យនយោបាយការគ្រប់គ្រងវិទ្យាស្ថានព្រះប៉ុកក្លៅ អ្នករៀបរៀង: រតិករ ចៀកវេន <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ១១៩	
៣	กฎหมายรัฐธรรมนูญ ច្បាប់រដ្ឋធម្មនុញ្ញ	Constitutional law (n.)	ច្បាប់មួយនៃច្បាប់មហាជនដែលមានគោលបំណងក្នុងការរៀបចំការគ្រប់គ្រងរដ្ឋលើផ្នែកនយោបាយដោយកំណត់ទម្រង់របស់រដ្ឋ របបគ្រប់គ្រង ការប្រើអំណាចអធិបតេយ្យនិងការ	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ដំណើរការរបស់ស្ថាប័នកំពូលរបស់រដ្ឋដែលប្រើអំណាចអធិបតេយ្យ	(វិសោធនកម្ម), ទំព័រ ៧ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣៨០	
៥	កម្មធនធានរ៍ប្រកันอิสรภาพ ការធានាសេរីភាព	Liberty Insurance Policy (n.)	ការធានាសេរីភាព ជាការធានារ៉ាប់រងដែលរៀបចំឡើងដោយបានគោលគំនិតពីការដែលតុលាការយុត្តិធម៌ចង់រៀបចំប្រព័ន្ធការពារជនជាប់ចោទឬចុងចោទ ដោយបន្ថែមជម្រើសឲ្យប្រជាជន អាចប្រើលិខិតធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ធ្វើជាគោលធានាជូនតុលាការ តុលាការយុត្តិធម៌ ការិយាល័យអយ្យការកំពូល ការិយាល័យនគរបាលជាតិ ក្រសួងពាណិជ្ជកម្ម ដោយនាយកដ្ឋានធានាសេរីភាពនិងសមាគមធានារ៉ាប់រងភ័យបានរួមគ្នាបង្កើតក្រុមហ៊ុនធានារ៉ាប់រងសេរីភាពឡើង។ ពេលប្រជាជនបានទិញធានារ៉ាប់រងសេរីភាពហើយ ក្រុមហ៊ុនធានារ៉ាប់រងនឹងចេញលិខិតធានាឲ្យអ្នកទិញរក្សាទុក។ បើអ្នកទិញធានារ៉ាប់រងបានប្រព្រឹត្តិបទល្មើសនិងធ្លាក់ខ្លួនជាជនជាប់ចោទឬចុងចោទក្នុងកំលុងពេលនៃការធានារ៉ាប់រង អ្នកទិញធានារ៉ាប់រងនឹងបានទទួលភាពងាយស្រួលជាពិសេសដោយអាចប្រើលិខិតធានារ៉ាប់រងនេះ ជូនទៅភ្នាក់ងារមានសមត្ថកិច្ចដើម្បីប្រើការពារខ្លួន ដោយពុំចាំបាច់យកទ្រព្យសម្បត្តិផ្សេងណាមកតម្កល់ឡើយ។	http://www.oic.or.th/th /consumer/ ការធានារ៉ាប់រងឥស្សរភាព	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥	กรรมสิทธิ์ កម្មសិទ្ធិ	Dominium (n.)	សិទ្ធិទាំងពួងដែលអ្នកជាម្ចាស់មានលើទ្រព្យសម្បត្តិ ដូចជាសិទ្ធិប្រើប្រាស់ លក់ដូរ ទទួលបានការប្រាក់ រួមទាំងសិទ្ធិតាមដាននិងយកមកវិញនូវទ្រព្យសម្បត្តិរបស់ខ្លួន និងសិទ្ធិជំទាស់មិនឲ្យជនដទៃចូលមកពាក់ព័ន្ធនឹងទ្រព្យសម្បត្តិនោះដោយទុច្ចរិតឬខុសច្បាប់។	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ១៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣៨៤	
៦	กระบวนการยุติธรรมเชิงสมานฉันท์ ในงานคุมประพฤติ នីតិវិធីយុត្តិធម៌ស្តារទំនាក់ទំនង	Restorative justice (n.)	១. នីតិវិធីយុត្តិធម៌ដែលមានគោលដៅស្តារទំនាក់ទំនងរបស់មនុស្សដែលបាត់បង់ទៅដោយសារអំពីឧក្រិដ្ឋកម្ម ឬការប្រព្រឹត្តិបទល្មើសដោយឲ្យជនរងគ្រោះបានថ្លែងពីអារម្មណ៍និងការខូចខាតដែលកើតឡើង និងបានទទួលសំណង / ប៉ះប៉ូវការខូចខាតដែលកើតឡើង រួមទាំងការខូចខាតខាងផ្លូវកាយ ផ្លូវចិត្ត អារម្មណ៍ ។ល។ ឲ្យជនប្រព្រឹត្តិល្មើស បានបង្ហាញទំនួលខុសត្រូវចំពោះទង្វើរបស់ខ្លួន តាមរយៈការផ្តល់សំណង / ប៉ះប៉ូវ ការខូចខាតទាំងនោះទៅជនរងគ្រោះដោយផ្ទាល់។ ២. នីតិវិធីទាំងឡាយណាដែលជនរងគ្រោះនិងជនល្មើស និងក្នុងករណីដែលសមស្របអាចមានបុគ្គលផ្សេង ឬសមាជិកដទៃក្នុងសហគមន៍ដែលបានទទួលផលប៉ះពាល់ដោយសារអំពើល្មើសនោះ បានចូលមករួមចំណែកយ៉ាងពិតប្រាកដក្នុងការដោះស្រាយបញ្ហាដែលកើតឡើងដោយសារអំពើល្មើសដោយជាទូទៅអាចមានការជួយពី "អ្នកសម្របសម្រួល"	វាក្យសព្ទអធិប្បាយពី កត.សប៉.យធ. <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពី កត.សប៉.យធ.	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ដំណើរការផ្សះផ្សារ អាចជា ការសម្រុះសម្រួល សម្របសម្រួលករណីវិវាទ ការប្រជុំក្រុម និងការពិភាក្សាដោយការប្រជុំតុមូល។		
៧	កលั่นแกล้ง ចោទប្រកាន់មិនពិត	To frame (v.) To persecute (v.) To do out malice (v.) To calumniate (v.) To falsely accuse (v.)	រករឿងក្តីមិនល្អទម្លាក់ឲ្យ, រកឧបាយកលទម្លាក់កំហុសដោយវិធីផ្សេង ។, រកវិធីទម្លាក់កំហុស	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៧៨ វាក្យសព្ទភាសាអង់គ្លេស ១. សៀវភៅវចនានុក្រមថៃ-អង់គ្លេស ដោយ រង្ស ឈ្ណាទនពិជេដ្ឋ ទំព័រ ២៩ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	
៨	ก่อให้เกิดเพลิงไหม้ បង្កអគ្គីភ័យ	Offenses of arson (n.) To cause fire (n.)	ការបង្កឲ្យកើតជាភ្លើងឆេះវត្ថុណាមួយ សូម្បីជារបស់ជនប្រព្រឹត្តិ រហូតអាចធ្វើឲ្យកើតគ្រោះថ្នាក់ដល់អ្នកដទៃឬទ្រព្យសម្បត្តិអ្នកដទៃ	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ២២០ វាក្យសព្ទភាសាអង់គ្លេស ១. សៀវភៅណែនាំការប្រើភាសាអង់គ្លេសក្នុងរាជការតុលាការ (ក្តីព្រហ្មទណ្ឌ) ភាគទី ១ បោះពុម្ពលើកទី ២, ក្រុមកិច្ចការការបរទេស ការិយាល័យសាលយុត្តិធម៌ ទំព័រ ៨៩ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៩	ก่อให้เกิดระเบิด ការបំផ្ទុះ	Offenses relating to the cause of explosion (n.) To cause explosion (n.)	ការធ្វើឲ្យផ្ទុះឡើងរហូតអាចកើតជាគ្រោះថ្នាក់ដល់អ្នកដទៃឬទ្រព្យសម្បត្តិអ្នកដទៃ	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ២២១ វាក្យសព្ទភាសាអង់គ្លេស ១. សៀវភៅណែនាំការប្រើភាសាអង់គ្លេសក្នុងរាជការតុលាការ (ក្តីព្រហ្មទណ្ឌ) ភាគទី ១ បោះពុម្ពលើកទី ២, ក្រុមកិច្ចការការបរទេស ការិយាល័យសាលយុត្តិធម៌ ទំព័រ ៨៩ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	
១០	การกระทำความผิดหลายกระทง ការប្រព្រឹត្តិបទល្មើសច្រើនករណី	Concurrence of offences (n.)	ការប្រព្រឹត្តិទង្វើតែមួយ តែជាបទល្មើសលើច្បាប់ច្រើនប្រភេទ	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង(វិសោធនកម្ម)ព.ស.២៥៦១,សាស្ត្រាចារ្យបណ្ឌិតទ្វីកិត្តិ មីន:កន្ទិដ្ឋ,មាត្រា ៩០ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា,បោះពុម្ពលើកទី ៨,ទំព័រ៦៨	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
១១	การกล่าวหมิ่นประมาท การบงการ	Slander (n.)	ការទម្លាក់កំហុសអ្នកដទៃចំពោះមុខជនទីបី ដោយប្រការដែលអាចធ្វើឲ្យអ្នកដទៃខូចកិត្តិយស ត្រូវគេមើលងាយ ឬត្រូវគេស្អប់	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣២៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅណែនាំការប្រើភាសាអង់គ្លេសក្នុងរាជការតុលាការ (ក្តីព្រហ្មទណ្ឌ) ភាគទី ១ បោះពុម្ពលើកទី ២, ក្រុមកិច្ចការការបរទេស ការិយាល័យសាលយុត្តិធម៌ ទំព័រ ៥៧	
១២	การกักตัว ឃាត់ខ្លួន	To detain (v.)	(មិនមាននិយមន័យនៃការឃាត់ខ្លួនដោយផ្ទាល់ក្នុងច្បាប់ មានតែក្នុងករណីដែលជនអន្តោប្រវេសន៍ត្រូវឃាត់ខ្លួន) ក្នុងការត្រួតពិនិត្យនិងពិចារណាថា ជនអន្តោប្រវេសន៍ណាម្នាក់ត្រូវហាមមិនឲ្យចូលមកក្នុងរាជាណាចក្រឬអត់ ភ្នាក់ងារមានសមត្ថកិច្ចអាចពិចារណាអនុញ្ញាតឲ្យជនអន្តោប្រវេសន៍នោះទៅស្នាក់អាស្រ័យនៅទីដែលយល់ថាសមគួរ ដោយផ្តល់ការធានាថាជនអន្តោប្រវេសន៍នោះនឹងមកជួបភ្នាក់ងារមានសមត្ថកិច្ចដើម្បីដឹងសេចក្តីបង្គាប់តាមកាលបរិច្ឆេទនិងទីកន្លែងដែលកំណត់ក៏បាន ឬបើភ្នាក់ងារមានសមត្ថកិច្ចយល់សមគួរថាត្រូវការការធានាឬថ្នូរ ឬទាមទារទាំងការធានានិងថ្នូរក៏បាន ឬភ្នាក់ងារមានសមត្ថកិច្ចដែលមានតួនាទីឃាត់ខ្លួនជននោះនៅកន្លែងណាមួយតាមដែលយល់ថាសមគួរដើម្បីដំណើរការតាមព្រះរាជ	ព្រះរាជក្រឹត្យស្តីអំពីជនអន្តោប្រវេសន៍ ព.ស. ២៥២២	

ឧបសម្ព័ន្ធ ៤ ឧទាហរណ៍ពាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ក្រឹត្យនេះក៏បានដើម្បីប្រយោជន៍នៃបទបញ្ញត្តិក្នុងប្រការមួយ ភ្នាក់ងារមានសមត្ថកិច្ច មានអំណាចកោះហៅបុគ្គលដែលមានហេតុដែលគួរជឿថាពាក្យសម្តីរបស់បុគ្គលនោះអាចជាប្រយោជន៍ដល់ករណីដែលសង្ស័យឲ្យមកស្បថឬប្រតិញ្ញានខ្លួននិងសន្យាចំពោះភ្នាក់ងារមានសមត្ថកិច្ចបាន បើមានហេតុដ៏គួរឲ្យសង្ស័យថាជនអន្តោប្រវេសន៍ណាម្នាក់ចូលមកក្នុងរាជាណាចក្រដើម្បីការដែលកំណត់ក្នុងមាត្រា ១២ (៨) ឬមានការជាប់ទាក់ទងនឹងការនោះ ឬស្ត្រីឬកុមារណាចូលមកដើម្បីការដូចដែលថានោះ ភ្នាក់ងារមានសមត្ថកិច្ចអាចអនុញ្ញាតឲ្យចូលមកក្នុងរាជាណាចក្របានបណ្តោះអាសន្ន ដោយបង្គាប់ឲ្យបុគ្គលនោះនិយាយបញ្ជាក់អត្តសញ្ញាណខ្លួន និងឆ្លើយសំណួររបស់ភ្នាក់ងារមានសមត្ថកិច្ច ឬនឹងបង្គាប់ឲ្យបង្ហាញខ្លួននិងឆ្លើយសំណួររបស់ភ្នាក់ងារមានសមត្ថកិច្ចនៅក្នុងប៉ុស្តិ៍នគរបាលតំបន់ដែលអ្នកនោះរស់នៅ តាមរយៈពេលដែលកំណត់ឲ្យបង្ហាញខ្លួននិងឆ្លើយសំណួរត្រូវឃ្លាតគ្នាមិនតិចជាងប្រាំពីរថ្ងៃម្តង។		
១៣	การขอไกล่เกลี่ยก่อนมีคดี (ก่อนฟ้อง) การสุ่มสรุ่ะสรุ่ะสรุ่มุ่นเรื่องตุลาการ (มุ่นการดักด่าคดีฟ้อง)	Pre-trial mediation (n.)	ការសម្រុះសម្រួលនិងសម្របសម្រួលករណីវិវាទមុនពេលការដាក់ពាក្យបណ្តឹងជាជម្រើសដំណោះស្រាយករណីវិវាទប្រភេទងាយស្រួល លឿន កាន់បន្តុយប្រាក់ចំណាយ និងជាការជួយឲ្យគូវិវាទអាចទទួលបានយុត្តិធម៌តាមរយៈការសម្រុះសម្រួលករណីវិវាទមុនការដាក់ពាក្យបណ្តឹង ដោយការជួយឲ្យគូវិវាទបានចរចារកដំណោះស្រាយនិងសម្របសម្រួលករណីវិវាទ	នីតិវិធីតុលាការខេត្តបទុមធានីស្តីអំពីនីតិវិធីអនុវត្តការងារសម្របសម្រួលវិវាទមុនដាក់ពាក្យបណ្តឹង ព.ស. ២៥៦២	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			រវាងគ្នាដោយពុំចាំបាច់យកករណីវិវាទឡើងទៅតុលាការដែលជាការរក្សាទំនាក់ទំនងរវាងគូវិវាទ បង្កើតឲ្យកើតជាសាមគ្គីភាពនិងមិត្តភាពនិងជាផ្នែកសំខាន់ក្នុងការដោះស្រាយករណីវិវាទជូនដល់ប្រជាជនយ៉ាងមានប្រសិទ្ធភាពនិងទូទៅ។		
១៤	ការข่าวกรอง ព័ត៌មានសម្ងាត់	Intelligence (n.)	ព័ត៌មានសម្ងាត់ មានន័យថា ការដំណើរការស៊ើបដើម្បីឲ្យបានដឹងនូវគោលបំណង កម្លាំងសមត្ថភាព និងការវិវត្តស្ថានការណ៍ រួមទាំងវិធីសាស្ត្ររបស់អន្តរជាតិឬអង្គការភារវកម្មដែលអាចបង្កហេតុដែលជាផលប៉ះពាល់នៃសន្តិសុខជាតិ។ ប្រការទាំងនេះ ធ្វើឡើងដើម្បីឲ្យរដ្ឋាភិបាលអាចយកមកពិចារណាក្នុងការកំណត់នយោបាយថ្នាក់ជាតិ។	១. ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងព័ត៌មានថ្នាក់ជាតិ ព.ស. ២៥២៨ មាត្រា ៣ ២. វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ១៩០ វាក្យសព្ទភាសាអង់គ្លេស ទទួលសណ្តាប់យោបល់ ៥ ភាគ	
១៥	การค้ามนุษย์ អំពើជួញដូរមនុស្ស	Human trafficking (n.) Trafficking in persons (n.)	ការរៀបចំស្វែងរក ការដឹកជញ្ជូន ការបញ្ជូនបន្ត ការរៀបចំឲ្យស្នាក់នៅឬការទទួលនូវបុគ្គលដោយវិធីគំរាម ឬដោយការប្រើកម្លាំង ឬដោយការគាបសង្កត់ក្នុងទម្រង់ណាមួយ ដោយការលួចលាក់នាំខ្លួន ដោយការបោកប្រាស់ ដោយការលួងបញ្ឆោត ដោយការប្រើអំណាចដោយទុច្ចរិត ឬដោយការប្រើស្ថានភាពប្រថុយប្រថានតាមរយៈការជួញដូរមនុស្សដោយទុច្ចរិត ឬមានការឲ្យឬទទួលប្រាក់ ឬផលប្រយោជន៍ដើម្បីឲ្យបានមកនូវការយល់ព្រមរបស់បុគ្គលមានអំណាច គ្រប់គ្រងបុគ្គលផ្សេង ដើម្បីគោលដៅនៃការស្វែងរកប្រយោជន៍ ការស្វែងរកប្រយោជន៍	វាក្យសព្ទអធិប្បាយពី កត.សប៉.យធ. (គេហទំព័រការិយាល័យក្តីជួញដូរមនុស្ស) វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពី កត.សប៉.យធ.	

ជំពូក ៤ ឧាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			យ៉ាងតិចបំផុត មានន័យរួមទាំងការស្វែងរកប្រយោជន៍តាមរយៈការលក់បវេណីរបស់បុគ្គលផ្សេងឬការស្វែងរកប្រយោជន៍ផ្លូវភេទក្នុងទម្រង់ផ្សេងៗ ការបង្ខាំប្រើកម្លាំងឬសេវាកម្ម ការយកមនុស្សធ្វើជាទាសករ ឬទង្វើផ្សេងដូចការយកមនុស្សធ្វើជាទាសករ ទង្វើឲ្យធ្លាក់នៅក្រោមការបង្ខាំបញ្ហា ឬការកាត់អវយវៈចេញពីរាងកាយ។		
១៦	การถอนคำร้องทุกข์ ការទម្លាក់ការបទចោទប្រកាន់	Withdrawal of complain petition (n.) Withdrawal of complaint (n.) To drop the charges (v.)	មិនមាននិយមន័យនៃពាក្យការទម្លាក់ការបទចោទប្រកាន់ដោយផ្ទាល់ក្នុងច្បាប់។ មានតែផលនៃការទម្លាក់ការបទចោទប្រកាន់ ជាហេតុឲ្យមានសិទ្ធិក្នុងការយករឿងក្តីព្រហ្មទណ្ឌមកប្តឹងដែលជាការរឹងាប់ករណីបទល្មើសចំពោះឯកជន។	បណ្តុំច្បាប់ពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ៣៩ (២) វាក្យសព្ទភាសាអង់គ្លេស ទទួលសណ្តាប់យោបល់ ៥ ភាគ	
១៧	การทอดทิ้งเด็ก คนเจ็บป่วย หรือคนชรา ការបោះបង់ចោលកុមារ អ្នកជំងឺ ឬជនជរា	Abandonment of children, sick persons / aged persons (n.)	ការបោះបង់កុមារអាយុមិនលើសពីប្រាំបួនឆ្នាំឲ្យនៅកន្លែងណាមួយ ដើម្បីឲ្យកុមារនោះផុតពីដៃខ្លួន ដោយប្រការដែលធ្វើឲ្យកុមារនោះប្រាសចាកការមើលថែ (បោះបង់ចោលកុមារ ម.៣០៦)។ ការបោះបង់ចោលនូវអ្នកដែលខ្លួនឯងពឹងពុំបានដោយប្រការដែលអាចបណ្តាលឲ្យកើតគ្រោះថ្នាក់ដល់អាយុជីវិត (ការបោះបង់ចោលអ្នកជំងឺឬជនជរា ម.៣០៧)។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣០៦-៣០៧ វាក្យសព្ទភាសាអង់គ្លេស ទទួលសណ្តាប់យោបល់ ៥ ភាគ	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
១៨	การบังคับใช้แรงงานหรือบริการ ការបង្ខំឲ្យប្រើកម្លាំងឬសេវាកម្ម	Enforced labor or servitude (n.)	ការគំរាមផ្លូវចិត្តឲ្យធ្វើការឬឲ្យផ្តល់សេវាកម្ម ដោយធ្វើឲ្យខ្លាចថានឹងកើតគ្រោះថ្នាក់ដល់ជីវិត រាងកាយ សុខភាព សេរីភាព កេរ្តិ៍ឈ្មោះ ឬទ្រព្យសម្បត្តិរបស់បុគ្គលនោះឬរបស់អ្នកដទៃ ដោយគំរាមដោយប្រការណាមួយ ដោយប្រើកម្លាំងប្រទូសរាយ ឬដោយធ្វើឲ្យបុគ្គលនោះនៅក្នុងសភាពដែលពុំអាចជំទាស់បាន។	ព្រះរាជក្រឹត្យស្តីអំពីការការពារនិងប្រឆាំងការជួញដូរមនុស្ស ព.ស. ២៥៥១	
១៩	การเพิกถอนการอนุญาต ការដកការអនុញ្ញាត	To revoke permission (n.)	ការដកការអនុញ្ញាតឲ្យអាស្រ័យនៅក្នុងរាជាណាចក្រជាបណ្តោះអាសន្ន និងការដកការអនុញ្ញាតឲ្យមានកន្លែងស្នាក់អាស្រ័យក្នុងរាជាណាចក្រ ១. ជនអន្តោប្រវេសន៍ដែលបានទទួលការអនុញ្ញាតឲ្យនៅក្នុងរាជាណាចក្រជាបណ្តោះអាសន្ន បើមានព្រឹត្តិការណ៍ដែលអាចដកការអនុញ្ញាតឲ្យនៅក្នុងរាជាណាចក្រតម្រូវឲ្យប្រធានឬគណៈកម្មការមានអំណាចដកការអនុញ្ញាតដែលបានអនុញ្ញាតនោះបានមិនថាប្រធានឬអ្នកដែលប្រធានប្រគល់ឲ្យជាអ្នកអនុញ្ញាត ក្នុងករណីដែលប្រធានចេញបញ្ជាឲ្យដកការអនុញ្ញាត ជនអន្តោប្រវេសន៍ដែលត្រូវបានដកការអនុញ្ញាតអាចប្តឹងឧទ្ធរណ៍ចំពោះគណៈកម្មការបាន បទបញ្ជារបស់គណៈកម្មការត្រូវដល់ទីបញ្ចប់ តែក្នុងករណីដែលគណៈកម្មការចេញបញ្ជាដកការអនុញ្ញាត បទបញ្ជារបស់គណៈកម្មការត្រូវដល់ទីបញ្ចប់។ ការសើរើបទបញ្ជារបស់ប្រធានតាមប្រការពីរ តម្រូវឲ្យប្តឹង	ព្រះរាជក្រឹត្យស្តីអំពីជនអន្តោប្រវេសន៍ ព.ស. ២៥២២ មាត្រា ៣៦ និង ៥៣	

ជំពូក ៤ ឃាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ចំពោះភ្នាក់ងារមានសមត្ថកិច្ចក្នុងរយៈពេលសែសិបប្រាំបីម៉ោង គិតចាប់ពីពេលដែលបានជ្រាបបទបញ្ជារបស់ប្រធាន និងតម្រូវឲ្យធ្វើតាមបែបបទនិងបង់ថ្លៃសេវាតាមដែលកំណត់ក្នុងច្បាប់ក្រសួង។ ពេលមានការដកការអនុញ្ញាតតាមប្រការមួយតម្រូវឲ្យធ្វើជាលិខិតជូនដំណឹងទៅជនអន្តោប្រវេសន៍។ ក្នុងករណីដែលពុំអាចជូនសេចក្តីជូនដំណឹងដូចដែលនិយាយនេះ ចំពោះជនអន្តោប្រវេសន៍បាន ពេលភ្នាក់ងារមានសមត្ថកិច្ចបានបិទទុកនៅទីស្នាក់នៅរបស់ជនអន្តោប្រវេសន៍ដែលបានជូនដំណឹងដល់ភ្នាក់ងារមានសមត្ថកិច្ចទុកគ្រប់កំណត់សែសិបប្រាំបីម៉ោង ត្រូវចាត់ទុកថាជនអន្តោប្រវេសន៍នោះបានជ្រាបបទបញ្ជាហើយ។ ២. ជនអន្តោប្រវេសន៍ដែលចូលមករស់នៅក្នុងរាជាណាចក្រហើយក្រោយមកប្រាកដថាជាបុគ្គលដែលមានព្រឹត្តិការណ៍យ៉ាងណាមួយតាមមាត្រា ១២ (៧) ឬ (៨) ឬជាបុគ្គលតាមមាត្រា ១២ (១០) ឬមិនអនុវត្តតាមវិធានដែលគណៈកម្មការកំណត់តាមមាត្រា ៤៣ ប្រការពីរ ឬជាអ្នកមានលក្ខណៈត្រូវហាមឃាត់តាមមាត្រា ៤៤ ឬមាត្រា ៦៤ តម្រូវឲ្យប្រធានស្នើរឿងទៅគណៈកម្មការ។ បើគណៈកម្មការយល់ឃើញថាគួរដកការអនុញ្ញាតឲ្យមានការរស់នៅក្នុងរាជាណាចក្រគឺតម្រូវឲ្យស្នើយោបល់ពីរដ្ឋមន្ត្រីដើម្បីចេញបញ្ជាដកការអនុញ្ញាតជាបន្ត។		

ជំពូក ៤ ឧទាហរណ៍ពាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
២០	การไฟฟ้านครหลวง អាជ្ញាធរអគ្គិសនីរាជធានី	Metropolitan Electricity Authority (n.)	ជារដ្ឋាករស្វយ័តរបស់ក្រសួងមហាផ្ទៃ ដោយចាត់តាំងឡើងតាមព្រះរាជក្រឹត្យស្តីអំពីកិច្ចការអគ្គិសនីរាជធានី ព.ស. ២៥០១ មាត្រា ៦ ដោយបញ្ញត្តិថា ត្រូវចាត់តាំងកិច្ចការអគ្គិសនីឡើងហៅថា "រដ្ឋាករស្វយ័តអគ្គិសនីរាជធានី" មានវត្ថុបំណងដូចខាងក្រោមនេះ៖ (១) ផលិតថាមពលអគ្គិសនីទៅជាបណ្តើរៗ ក្នុងកំលុងពេលដែលពុំទាន់មានការផ្ទេរមាត្រា ១៤ ប្រការមួយនៃព្រះរាជក្រឹត្យស្តីអំពីកិច្ចការអគ្គិសនីយ៉ានហ៊ី ព.ស. ២៥០០ (២) រៀបចំឲ្យទទួលបាននិងលក់ថាមពលអគ្គិសនី និង (៣) ដំណើរការទិញលក់ថាមពលអគ្គិសនីនិងផ្សេងៗ ដែលពាក់ព័ន្ធ ឬដែលជាប្រយោជន៍ដល់កិច្ចការអគ្គិសនីរាជធានី។	ព្រះរាជក្រឹត្យស្តីអំពីការអគ្គិសនីរាជធានី ព.ស. ២៥០១ មាត្រា ៦ វាក្យសព្ទភាសាអង់គ្លេស ១. www.mea.or.th/ (គេហទំព័ររបស់ក្រុមការងារខាងលើ) ២. សៀវភៅវចនានុក្រមថៃ-អង់គ្លេស ដោយ វង្ស វណ្ណទនពិជេដ្ឋ ទំព័រ ៩៥៩	
២១	การไฟฟ้าส่วนภูมิภาค អាជ្ញាធរអគ្គិសនីភូមិភាគ	Provincial Electricity Authority (n.)	ជារដ្ឋាករស្វយ័តរបស់ក្រសួងមហាផ្ទៃ ដោយចាត់តាំងឡើងតាមព្រះរាជក្រឹត្យស្តីអំពីកិច្ចការអគ្គិសនីភូមិភាគ ព.ស. ២៥០៣ មាត្រា ៦ ដោយបញ្ញត្តិថា ត្រូវចាត់តាំងកិច្ចការអគ្គិសនីឡើងហៅថា "រដ្ឋាករស្វ័យអគ្គិសនីភូមិភាគ" ហៅជាអក្សរកាត់ថា "រអភ" និងឲ្យប្រើជាភាសាអង់គ្លេសថា "PROVINCIAL ELECTRICITY AUTHORITY" ហៅជាអក្សរកាត់ថា "PEA" មានវត្ថុបំណងដូចខាងក្រោមនេះ៖ (១) ផលិត រៀបចំបង្កើត រៀបចំបញ្ជូន និងលក់ថាមពលអគ្គិសនី	ព្រះរាជក្រឹត្យស្តីអំពីការអគ្គិសនីភូមិភាគ ព.ស. ២៥០៣ មាត្រា ៦ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវចនានុក្រមថៃ-អង់គ្លេស ដោយ វង្ស វណ្ណទនពិជេដ្ឋ ទំព័រ ៩៥៩	

ជំពូក ៤ ឃាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			(២) ការដំណើរការទិញលក់ថាមពលអគ្គិសនីនិងផ្សេងៗ ដែលពាក់ព័ន្ធឬដែលជាប្រយោជន៍ចំពោះកិច្ចការអគ្គិសនីភូមិភាគ។		
២២	ការយ៉ាមរៃកល់ជិត ការសួរសុខទុក្ខ ស្និទ្ធស្នាល	Contact visit (n.)	ជនជាប់ឃុំឃាំងដែលមានការប្រព្រឹត្តិល្អ និងមានគុណសម្បត្តិតាមដែលនាយកដ្ឋានរាជទណ្ឌកំណត់ត្រូវបានទទួលការសួរសុខទុក្ខស្និទ្ធស្នាល ដែលជាការសួរសុខទុក្ខជនជាប់ឃុំឃាំងផ្ទាល់ក្នុងពន្ធនាគារដោយពុំមានអ្វីបិទបាំងក្នុងការសន្ទនា មានការទទួលទានអាហាររួមគ្នា ដែលអាចជួយបង្កើនភាពស្និទ្ធស្នាលក្នុងគ្រួសារ និងជាឧបករណ៍ទាក់ទាញចិត្តឲ្យជនជាប់ឃុំឃាំងប្រព្រឹត្តិខ្លួនជាមនុស្សល្អ អនុវត្តត្រូវតាមរបៀបវិន័យនៃពន្ធនាគារ។	សៀវភៅណែនាំស្តីអំពីការរស់នៅក្នុងមន្ទីរឃុំឃាំង <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៥៦	
២៣	ការយ៉ាមរៃបែបប្រើជីវិតគូ ការសួរសុខទុក្ខគូជីវិត	Conjugal Visit (n.)	ការសួរសុខទុក្ខគូជីវិត ជាការដែលបើកឱកាសឲ្យគូស្វាមីឬភរិយាដែលស្របច្បាប់របស់ជនជាប់ឃុំឃាំងអាចចូលសួរសុខទុក្ខបានដោយស្និទ្ធស្នាល នៅក្នុងទីកន្លែងដែលបានរៀបចំទុកដោយផ្ទាល់ខ្លួន ដោយបើកឱកាសឲ្យជនជាប់ឃុំឃាំងនិងគូជីវិតអាចរួមបវេណីគ្នាបាន ក្រោមការគ្រប់គ្រងរបស់ពន្ធនាគារ ដើម្បីបង្ការបញ្ហាដែលអាចកើតឡើងនៅពេលក្រោយ ដូចជាការពន្យាកំណើត ការពិនិត្យជំងឺរបស់អ្នកដែលចូលសួរសុខទុក្ខ ជាដើម ដោយផ្តល់រយៈពេលសមគួរ ដើម្បីឲ្យជនជាប់ឃុំឃាំងអាចរស់នៅជាមួយគូជីវិតបានដោយប្រាសចាកការគ្រប់គ្រង ឬសម្ភារពន្ធនាគារផ្សេងៗ។	នីតិវិធីការសួរសុខទុកជនជាប់ឃុំឃាំងដើម្បីលើកស្ទួយជីវិតសហព័ន្ធនិងគ្រួសារ (ទ្រង់វុឌ្ឍិ ននុបុរម្យ និងសាស្ត្រាចារ្យបណ្ឌិត ធានី វរភ័ទ្រ សាកលវិទ្យាល័យធុរកិច្ចបណ្ឌិត្យ) <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌ ទំព័រ ៥៩	

ជំពូក ៤ ឃាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
២៥	การส่งตัวต่างด้าวกลับออกไปนอกราชอาณาจักร ការបញ្ជូនជនអន្តោប្រវេសន៍ចេញក្រៅរាជាណាចក្រ	To Deport (v.) Deportation (n.)	១. ក្នុងករណីដែលភ្នាក់ងារមានសមត្ថកិច្ចរកឃើញថាជនអន្តោប្រវេសន៍ដែលមានលក្ខណៈត្រូវហាមមិនឲ្យចូលមកក្នុងរាជាណាចក្រតាមមាត្រា ១៣ ចូលមកក្នុងរាជាណាចក្រ តម្រូវឲ្យភ្នាក់ងារមានសមត្ថកិច្ចមានអំណាចបញ្ជាឲ្យជនអន្តោប្រវេសន៍នោះត្រលប់ចេញទៅក្រៅរាជាណាចក្របាន ដោយចេញបញ្ជាជាលិខិត បើជនអន្តោប្រវេសន៍នោះពុំពេញចិត្តលើបទបញ្ជាអាចប្តឹងសើរើចំពោះរដ្ឋមន្ត្រីបាន លើកលែងតែករណីតាមមាត្រា ១២ (១) ឬ (១០) ហាមមិនឲ្យសើរើបទបញ្ជារបស់រដ្ឋមន្ត្រី តែបើរដ្ឋមន្ត្រីពុំបានចេញបញ្ជាក្នុងរយៈពេលប្រាំពីរថ្ងៃគិតចាប់ពីថ្ងៃប្តឹងឧទ្ធរណ៍ ត្រូវចាត់ទុករដ្ឋមន្ត្រីមានបទបញ្ជាថាជនអន្តោប្រវេសន៍នោះពុំមែនជាអ្នកត្រូវហាមពុំឲ្យចូលមកក្នុងរាជាណាចក្រតាមមាត្រា ១២ ២. ពេលភ្នាក់ងារមានសមត្ថកិច្ចរកឃើញថាជនអន្តោប្រវេសន៍ណាម្នាក់មានលក្ខណៈត្រូវហាមមិនឲ្យចូលមកក្នុងរាជាណាចក្រ ឬមានហេតុដែលគួរសង្ស័យថាជាអ្នកមានលក្ខណៈត្រូវហាមមិនឲ្យចូលមកក្នុងរាជាណាចក្រ ភ្នាក់ងារមានសមត្ថកិច្ចមានអំណាចបញ្ជាឲ្យម្ចាស់របស់យានជំនិះឬអ្នកគ្រប់គ្រងយានជំនិះរៀបចំគ្រប់គ្រងជនអន្តោប្រវេសន៍នោះនៅក្នុងយានជំនិះ ឬតម្រូវឲ្យបញ្ជូនខ្លួនទៅទីកន្លែងណាមួយដើម្បីឲ្យភ្នាក់ងារមានសមត្ថកិច្ចអាចបានគ្រប់គ្រង ត្រួតពិនិត្យ ឬឲ្យបញ្ជូនខ្លួនត្រលប់ចេញទៅក្រៅរាជាណាចក្រ។ ៣. ជនអន្តោប្រវេសន៍ណាចូលមកឬរស់នៅក្នុងរាជាណាចក្រ	ព្រះរាជក្រឹត្យស្តីអំពីជនអន្តោប្រវេសន៍ ព.ស. ២៥, ២២ មាត្រា ២២ ២៩ និង ៥៥	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ដោយមិនបានទទួលការអនុញ្ញាតឬការអនុញ្ញាតនោះផុតកំណត់ឬត្រូវដកចេញរួចហើយ ភ្នាក់ងារមានសមត្ថកិច្ចអាចបញ្ជូនខ្លួនជនអន្តោប្រវេសន៍នោះត្រលប់ចេញទៅក្រៅរាជាណាចក្រក៏បាន។		
២៥	การสอบสวน ការសាកសួរ	Inquiry (n.)	ការប្រមូលសាក្សីភស្តុតាងនិងការដំណើរការទាំងឡាយតាមបទបញ្ញត្តិនៃបណ្តុំច្បាប់នេះ ដែលភ្នាក់ងារសាកសួរបានសាកសួរហើយពាក់ព័ន្ធបទល្មើសដែលចោទប្រកាន់ ដើម្បីជ្រាបការពិតឬពិសោធបទល្មើសនិងដើម្បីអាចនាំខ្លួនជនល្មើសទៅប្តឹងដើម្បីដាក់ទោស។	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិ វឌ្ឍនកុល, មាត្រា ២ (១១) <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ១៥៩ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
២៦	การอายัดตัว ការទប់ស្កាត់ការដោះលែង	To withhold release (v.)	ពុំមាននិយមន័យនៃពាក្យការទប់ស្កាត់ការដោះលែងដោយផ្ទាល់ក្នុងច្បាប់ឡើយ មានតែក្នុងករណីដែលអាចទប់ស្កាត់ការដោះលែង។ ជនត្រូវឃុំខ្លួនដែលមានការទប់ស្កាត់ការដោះលែង មានដីកាចាប់ខ្លួន ឬរដ្ឋាភិបាលបរទេសត្រូវការចាប់ខ្លួន ឬជា ជនជាប់ចោទក្នុងរឿងក្តីសំខាន់ តម្រូវឲ្យមន្ត្រីសន្តិសុខរាយការណ៍ជូនមេបញ្ជាការតាមលំដាប់ថ្នាក់ឲ្យជ្រាបជាបន្ទាន់។	បទបញ្ជា កិច្ចការ ៣ ក្រុមអង្កេតការណ៍ ៥ ក្រុមបញ្ជាការជំនួយការការិយាល័យត្រួតពិនិត្យជនអន្តោប្រវេសន៍ទី ២១/២៥៤៥ ស្តីអំពីនីតិវិធីនិងវិធានអនុវត្តក្នុងការទទួលជនជាប់ចោទឬជនអន្តោប្រវេសន៍ត្រូវជាប់ឃុំ	
២៧	การุณยฆาต ការសម្លាប់ដោយសូប / ករុណាឃាត	Mercy killing (n.) Euthanasia (n.)	១. ការសម្លាប់ឬធ្វើឲ្យស្លាប់យ៉ាងសូប់ឬមិនឈឺចាប់ មានអត្ថន័យដូចគ្នានឹង៣ក្យ Euthanasia ២. ការធ្វើឲ្យបុគ្គលផ្សេងដែលស្ថិតនៅក្នុងដំណាក់កាលចុងក្រោយនៃការមានជីវិតស្លាប់យ៉ាងទុក្ខវេទនា។	១. សៀវភៅ Law dictionary វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស, អង់គ្លេស-ថៃ ធង វិទ្យាវឌ្ឍន ទំព័រ ៧២ ២. វាក្យសព្ទអធិប្បាយពី កសន. <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅ Law dictionary វចនានុក្រមវាក្យសព្ទនិងសំនួនច្បាប់ ថៃ-អង់គ្លេស, អង់គ្លេស-ថៃ ធង វិទ្យាវឌ្ឍន ទំព័រ ៧២	
២៨	กำนัน មេឃុំ / ចៅសង្កាត់	Chief administrative official of a ... (subdistrict) (n.)	តំណែងមន្ត្រីគ្រប់គ្រង ដែលមានអំណាចតួនាទីគ្រប់គ្រងប្រជាជនថ្នាក់ឃុំឬសង្កាត់	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ៦៧ <u>វាក្យសព្ទភាសាអង់គ្លេស</u>	

ជំពូក ៤ ឃាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				សៀវភៅវចនានុក្រម ថៃ-អង់គ្លេស ដោយ វង្ស វណ្ណធនពេជដ្ឋ ទំព័រ ៤៩	
២៩	ข้อบังคับ បទបញ្ញត្តិ	Regulation (n.) Rule (n.)	១. លក្ខខណ្ឌលម្អិតដែលកំណត់ឲ្យអ្នកជាប់ពាក់ព័ន្ធត្រូវអនុវត្ត ២. បណ្តាបទបញ្ញាតិនិងច្បាប់ផ្សេងៗ ដែលកំណត់ឲ្យប្រើជាប្រចាំ ដែលមេបញ្ជាការទាហានអ្នកដែលមានអំណាចដ៏សមគួរបានកំណត់ទុកដោយសមគួរតាមសម័យកាលនិងយុត្តិធម៌ ដោយព្រះរាជក្រឹត្យ (បណ្តុំច្បាប់ព្រហ្មទណ្ឌយោធា មាត្រា ៥)	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ៨២-៨៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥២០ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	
៣០	ข้อพิพาทด้านครอบครัว វិវាទគ្រួសារ	Family dispute (n.)	រឿងក្តីវិវាទដែលប្តឹងឬតវ៉ាចំពោះតុលាការ ឬទង្វើណាៗ ខាងផ្លូវតុលាការពាក់ព័ន្ធនឹងកុមារឬគ្រួសារ ដែលត្រូវអនុវត្តតាមបណ្តុំច្បាប់រដ្ឋប្បវេណីនិងពាណិជ្ជកម្ម ច្បាប់ស្តីអំពីការចុះបញ្ជីគ្រួសារ ឬច្បាប់ផ្សេងៗ ដែលពាក់ព័ន្ធនឹងវិវាទគ្រួសារ ដូចជារឿងក្តីដែលពាក់ព័ន្ធនឹងការប្តឹងសុំលែងលះ ការបែងចែកទ្រព្យសម្បត្តិគ្រួសារ ការទាមទារសំណងចិញ្ចឹមបីបាច់ អំណាចគ្រប់គ្រងបុត្រ ឬរឿងក្តីពាក់ព័ន្ធនឹងស្ថានភាពនិងសមត្ថភាពរបស់បុគ្គលដែលពាក់ព័ន្ធក្នុងគ្រួសារ ឬផលប្រយោជន៍របស់កុមារ។	បទសរុបការប្រជុំជំនាញឯកទេស ស្តីអំពី "វិធានសមស្របក្នុងការសម្របសម្រួលវិវាទ ផ្នែកគ្រួសារនិងកេរមរតកក្នុងប្រទេសថៃនិងហុងកុង" លោកស្រីផ្លើនតា តាន់រុំងសាន់ នីតិករ ការិយាល័យច្បាប់ព្រឹត្តិបត្រចុលនីតិ	

ឧបសម្ព័ន្ធ ៤ វាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៣១	ข่าวกรอง ព័ត៌មានបានការ	Intelligence (n.)	ព័ត៌មានដែលបានត្រួតពិនិត្យតស្ដុតាងហើយថាជាព័ត៌មានដែលជឿទុកចិត្តបាន	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> National Intelligence Act, B.E. 2528 (1985) Section 3	
៣២	คดี រឿងក្តី	Case (n.) Suit (n.)	១. នីតិវិធីការពិចារណាវិវាទដោយគិតចាប់ពីការដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីសុំឲ្យទទួលស្គាល់ គ្រប់គ្រប់បង្ហាតាមឬដើម្បីការប្រើនូវសិទ្ធិឬតួនាទី ២. រឿងឬក្តីដែលប្តឹងឬចោទប្រកាន់តាមផ្លូវច្បាប់ ដែលត្រូវដំណើរការតាមនីតិវិធីការពិចារណាក្តីតាមដែលច្បាប់កំណត់ ដូចជា រឿងក្តីរដ្ឋប្បវេណី រឿងក្តីព្រហ្មទណ្ឌ រឿងក្តីគ្រប់គ្រង ជាដើម។	- បណ្តុំច្បាប់វិធីពិចារណាក្តីរដ្ឋប្បវេណី វិសោធនកម្ម ព.ស. ២៥៥៩ មាត្រា ២ - វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ១០៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៣០	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៣៣	គតីរ៉ែងកើ៉ยวเนื่องกับคดีอาญา រឿងក្តីរដ្ឋប្បវេណីជាប់ពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ	Civil and penal actions (n.) Civil case relating to criminal case (n.)	រឿងក្តីរដ្ឋប្បវេណីដែលមានបុរសគល់ឬហេតុមកពីការប្រព្រឹត្តិល្មើសព្រហ្មទណ្ឌដែលតែងតែបង្កឲ្យកើតបុរសគល់ក្តីផ្នែករដ្ឋប្បវេណីក្នុងលក្ខណៈល្មើសដែរ។	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ៤០-៥១ វាក្យសព្ទភាសាអង់គ្លេស ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៣១ ២. ទទួលសណ្តាប់យោបល់ ៤ ភាគ	
៣៤	คนเร่ร่อน / คนจรจัด ជនអនាថា	Tramp (n.) Vagabond (n.) Vagrant (n.) Homeless (n.)	អនាថា គឺ ១. ពុំមានកន្លែងជ្រកជាក់លាក់ ដូចជា ឪពុកម្តាយស្លាប់ជននោះត្រូវដើរអនាថារកទីជម្រកនៅពុំជាក់លាក់ ២. កន្លែងរស់នៅពុំជាក់លាក់ ដូចជា ជនអនាថា ជនខ្វាត់ព្រាត់	វាក្យសព្ទភាសាអង់គ្លេស ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៣២ ២. ទទួលសណ្តាប់យោបល់ ៤ ភាគ	
៣៥	คนไร้ความสามารถ ជនអសមត្ថភាព	Incapacitated person (n.)	១. បុគ្គលវិកលចរិតណាម្នាក់ បើជាគូសហាព័ន្ធក្តី បុព្វការីជនក្តី ពោលគឺ មាតា បិតា តា យាយ តាទួត យាយទួតក្តី អ្នកបន្តវង្សត្រកូល ពោលគឺ កូន ចៅ ចៅទួត ចៅលួតក្តី អ្នកគ្រប់គ្រងឬអ្នកអាណាព្យាបាលក្តី អ្នកដែលគ្រប់គ្រងមើលថែបុគ្គលនោះក្តី ឬភ្នាក់ងារអយ្យការក្តី ទាមទារឬស្នើសុំចំពោះតុលាការឲ្យចេញ	១. បណ្តុំច្បាប់រដ្ឋប្បវេណីនិងពាណិជ្ជកម្ម ច្បាប់វិសោធនកម្មចុងក្រោយ ព.ស. ២៥៥៩ មាត្រា ២៨ ២. រចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ២២៧	

ឧបសម្ព័ន្ធ ៤ ឧទាហរណ៍ពាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			សេចក្តីបញ្ជាក់ឲ្យបុគ្គលវិកលចរិតនោះជាជនអសមត្ថភាព តុលាការនឹងចេញសេចក្តីបញ្ជាក់ឲ្យបុគ្គលវិកលចរិតនោះជាមជនអសមត្ថភាពក៏បាន។ ២. បុគ្គលវិកលចរិតដែលតុលាការចេញសេចក្តីបញ្ជាក់ថាជាមជនអសមត្ថភាព។	<u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៣២	
៣៦	คนเสมือนไร้ความสามารถ ជនប្រៀបបាននឹងអសមត្ថភាព	Person under disability (n.) Quasi disability (n.) Incompetent person (n.)	បុគ្គលដែលពុំអាចចាត់ចែងការងារដោយផ្ទាល់ដោយខ្លួនឯង ឬចាត់ចែងការងារឆ្ពោះទៅរកភាពហិនហោចនៃទ្រព្យសម្បត្តិរបស់ខ្លួនឯងឬគ្រួសារ ដោយសារពិការភាព ចិត្តរពឹរវាយ មិនសមប្រកប ប្រព្រឹត្តិអំពើខ្ជះខ្ជាយប៉ោឡែជាអចិន្ត្រៃយ៍ ឬញៀនស្រាញៀនថ្នាំ ឬហេតុផលផ្សេងណាក្នុងទំនោរដូចគ្នានេះ និងតុលាការបានចេញសេចក្តីបញ្ជាក់ថាជាជនប្រៀបបាននឹងអសមត្ថភាព។	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ២២៧ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៣៣ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	
៣៧	ความคุ้มครอง អាណាព្យាបាល	Protection (n.)	អាណាព្យាបាល គឺ ការពារ ថែរក្សា មើលថែ បីបាច់។	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ២៦៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ២៦៨	

ជំពូក ៤ វាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៣៨	ความตกลง ការព្រមព្រៀង	Agreement (n.)	ព្រមព្រៀង គឺ ស្រុះស្រួលចិត្តគ្នា យល់ព្រមនឹងគ្នា។	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៤៥១ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៣៦	
៣៩	ความประมาททางอาญา បទព្រហ្មទណ្ឌធ្វេសប្រហែស	Criminal negligence (n.)	ការប្រព្រឹត្តិបទល្មើសដែលពុំមែនជាចេតនា តែប្រព្រឹត្តិឡើងដោយប្រាសចាកការប្រុងប្រយ័ត្នដែលបុគ្គលក្នុងសភាពបែបនេះត្រូវមានទូរវិស័យនិងព្រឹត្តិការណ៍ និងជនប្រព្រឹត្តិអាចប្រើបម្រុងប្រយ័ត្នដូចដែលនិយាយនេះបាន តែពុំបានប្រើឲ្យពេញលេញ	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៥៩ ប្រការ ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៣៧	
៤០	ความเป็นธรรม យុត្តិធម៌	Fairness (n.)	យុត្តិធម៌ គឺ ភាពត្រឹមត្រូវ។	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៧៥៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> ទទួលសណ្តាប់យោបល់ ៤ ភាគ	

ជំពូក ៤ ឧាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៤១	ความผิดฐานโกงเจ้าหนี้ បទល្មើសកេងប្រវ័ញ្ចម្ចាស់ទ្រព្យ	Offences of cheating against creditors (n.)	១. ជនណាយកទៅ ធ្វើឲ្យខូចខាត បំផ្លាញ ធ្វើឲ្យបាត់បង់តម្លៃ ឬធ្វើឲ្យគ្មានប្រយោជន៍នូវទ្រព្យដែលខ្លួនបញ្ចាំទុកនៅនឹងអ្នកដទៃ ប្រសិនបើបានធ្វើដើម្បីឲ្យកើតការខូចបង់ដល់អ្នកទទួលបញ្ចាំត្រូវទទួលទោស។ ២. ជនណាធ្វើដើម្បីមិនឲ្យម្ចាស់បំណុលរបស់ខ្លួនឬរបស់អ្នកដទៃបានទទួលការសងបំណុលទាំងអស់ឬមួយភាគ ដែលបានប្រើឬនឹងប្រើសិទ្ធិប្តឹងទាមទារទៅតុលាការឲ្យសងបំណុលផ្លាស់ប្តូរ បង្កប់ ឬផ្ទេរទៅឲ្យជនដទៃនូវទ្រព្យសម្បត្តិណាក្តី ក្លែងឲ្យខ្លួនឯងជាប់បំណុលចំនួនណាមួយដែលពុំមែនជាការពិតក្តី ត្រូវទទួលទោស។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣៤៩, ៣៥០ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៣២	
៤២	ความผิดฐานขัดคำสั่งเจ้าพนักงาน បទល្មើសប្រឆាំងអាជ្ញាធរមានសមត្ថកិច្ច	Being in violation of a police order (n.)	ជាបទល្មើសទោសលហុមួយសណ្ឋាន ពុំមាននិយមន័យដោយផ្ទាល់ក្នុងច្បាប់។ ជនណាដឹងនូវបទបញ្ជារបស់ភ្នាក់ងារមានសមត្ថកិច្ចដែលបញ្ជាតាមអំណាចដែលមានច្បាប់កំណត់ពុំអនុវត្តតាមបទបញ្ជានោះ ដោយពុំមានហេតុឬការដោះសារដែលសមរម្យ ត្រូវទទួលទោសជាប់គុកមិនលើសដប់ថ្ងៃឬពិន័យមិនលើសប្រាំពាន់បាត ឬទាំងជាប់គុកទាំងពិន័យ។ ប្រសិនបើបទបញ្ជាដូចដែលនិយាយនោះ ជាបទបញ្ជាឲ្យជួយធ្វើកិច្ចការក្នុងតួនាទីរបស់ភ្នាក់ងារមានសមត្ថកិច្ចដែលច្បាប់កំណត់ឲ្យបញ្ជាឲ្យជួយបាន ត្រូវដាក់ទោសជាប់គុកមិនលើសមួយខែ ឬពិន័យមិនលើសមួយម៉ឺនបាត ឬទាំងជាប់គុកទាំងពិន័យ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ មាត្រា ៣៦៨	

ជំពូក ៤ ឃាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៤៣	ความผิดฐานฉ้อโกง បទល្មើសឆបោក	Offences of cheating and fraud (n.)	ការប្រព្រឹត្តិដោយទុច្ចរិត ការបោកប្រាស់ជនដទៃដោយប្រើសារដែលមិនពិតឬដោយការបិទបាំងសេចក្តីពិតដែលគួរប្រាប់ឲ្យដឹងច្បាស់ និងដោយការបោកបញ្ឆោតដូចដែលនិយាយនេះ ជាហេតុឲ្យទទួលបានទ្រព្យសម្បត្តិពីអ្នកដែលត្រូវគេបោកប្រាស់ឬបុគ្គលទីបី ឬធ្វើឲ្យអ្នកត្រូវគេបោកប្រាស់ឬបុគ្គលទីបីធ្វើ ដក ឬបំផ្លាញឯកសារកម្មសិទ្ធិ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣៤១ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៣២	
៤៤	ความผิดฐานชิงทรัพย์ បទល្មើសឆក់ទ្រព្យសម្បត្តិ	Offenses of robbery (n.)	ជនលួចទ្រព្យសម្បត្តិដោយប្រើកម្លាំងប្រទូសរាយ ឬគំរាមថាក្នុងពេលនោះនឹងប្រើកម្លាំងប្រទូសរាយ ដើម្បី៖ (១) បង្កភាពងាយស្រួលក្នុងការលួចទ្រព្យសម្បត្តិឬការយកទ្រព្យសម្បត្តិនោះទៅ (២) ឲ្យប្រគល់ឲ្យនូវទ្រព្យសម្បត្តិនោះ (៣) យកទ្រព្យសម្បត្តិនោះទៅ (៤) បិទបាំងការប្រព្រឹត្តិបទល្មើសនោះ ឬ (៥) ឲ្យរួចផុតពីការចាប់ខ្លួន។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣៣៩ វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៣២	

ជំពូក ៤ ឧាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៤៥	ความผิดฐานทำให้เสียทรัพย์ បទល្មើសបង្កការខូចខាតទ្រព្យសម្បត្តិ	Offences of mischief (n.)	ការធ្វើឲ្យខូចខាត បំផ្លាញ ធ្វើឲ្យបាត់បង់តម្លៃ ឬធ្វើឲ្យគ្មានប្រយោជន៍នូវទ្រព្យរបស់អ្នកដទៃឬដែលអ្នកដទៃជាម្ចាស់ទ្រព្យសម្បត្តិនោះរួមជាមួយ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣៥៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៣២	
៤៦	ความผิดฐานบุกรุก បទល្មើសរុករាន	Offences of trespass (n.)	ការចូលទៅក្នុងអចលនទ្រព្យរបស់អ្នកដទៃដើម្បីប្រកាន់យកនូវការគ្រប់គ្រងទាំងអស់ ឬផ្នែកខ្លះ ឬចូលទៅប្រព្រឹត្តិទង្វើផ្សេងណាដែលជាការរំខានដល់ការគ្រប់គ្រងអចលនទ្រព្យរបស់គេដោយប្រក្រតីសុខ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣៦២ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៣២	
៤៧	ความผิดฐานรับของโจร បទល្មើសទទួលផលចោរកម្ម	Offences of receiving stolen property (n.)	អ្នកជួយលាក់បាំង ជួយលក់ ជួយយកទៅ ទិញ ទទួល បញ្ចាំ ឬទទួលយក ដោយប្រការណាមួយនូវទ្រព្យសម្បត្តិដែលបានមកដោយការប្រព្រឹត្តិល្មើស បើបទល្មើសនោះចូលក្នុងលក្ខណៈជាការលួច ឆក់ ជំរិត ដណ្តើម ប្លន់ ឆបោក បោក	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣៥៧ <u>វាក្យសព្ទភាសាអង់គ្លេស</u>	

ឧបសម្ព័ន្ធ ៤ វាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ប្រាស់ ឬអាជ្ញាធរលូចទ្រព្យសម្បត្តិ។	សៀវភៅវាក្យសព្ទភាសាអង់គ្លេសដែលទាក់ទងនឹងការងាររាជទណ្ឌដោយការិយាល័យទណ្ឌវិទ្យា ទំព័រ ៣២	
៥៨	ความมั่นคง សន្តិសុខ	Security (n.)	សន្តិសុខ គឺ ស្ថិរភាព គង់វង្ស។	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨៩៩ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៤៣	
៥៩	ความยุติธรรมช่วงเปลี่ยนผ่าน យុត្តិធម៌កំលុងពេលផ្លាស់ប្តូរ	Transitional Justice (n.)	យុត្តិធម៌ក្នុងកំលុងពេលផ្លាស់ប្តូរ (Transitional Justice) ជាការបញ្ចូលគោលគំនិតពីរប្រភេទចូលគ្នាគឺ "ការផ្លាស់ប្តូរ" (Transitional) និង "យុត្តិធម៌" (Justice) ដោយការផ្លាស់ប្តូរ គឺសភាពដែលសង្គមបានមានការផ្លាស់ប្តូររបបនយោបាយ (political transformation/ regime change) ពីទម្រង់មួយទៅទម្រង់ថ្មីមួយទៀតយ៉ាងមានអត្ថន័យសំខាន់ ឬប្រើក្នុងអត្ថន័យនៃការផ្លាស់ប្តូរពីបញ្ហាដែលជាទំនាស់របស់មនុស្សក្នុងសង្គមឆ្ពោះទៅរកសន្តិភាពនិងស្ថិរភាព។ យុត្តិធម៌ក្នុងកំលុងពេលផ្លាស់ប្តូរ មានន័យរួមទៅដល់ នីតិវិធីដែលរដ្ឋាភិបាល ឬអង្គការដែលរដ្ឋផ្តល់ការគាំទ្រឲ្យប្រើកម្លាំងទៅកម្ទេចចោល ឬបង្កវិនាសកម្មដល់ប្រជាពលរដ្ឋរបស់ខ្លួន មិនថាក្នុងរូបភាពនៃការ	វាក្យសព្ទអធិប្បាយពី កត.សប៊.យធ. <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពី កត.សប៊.យធ.	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ប្រល័យពូជសាសន៍ ការប្រល័យជាក្រុម ការធ្វើទារុណកម្ម ការចាប់ពង្រត់។		
៥០	ความสัมพันธ์ระหว่างประเทศ ទំនាក់ទំនងការបរទេស	International Relations (n.)	១. ការផ្លាស់ប្តូរនិងចំណងមិត្តភាពដែលកើតឡើងឆ្លងព្រំដែនរបស់រដ្ឋ ដែលជះឥទ្ធិពលដល់កិច្ចសហប្រតិបត្តិការឬទំនាស់រវាងប្រទេសផ្សេងៗ ក្នុងពិភពលោក ជាផ្នែកមួយនៃមុខវិជ្ជារដ្ឋសាស្ត្រ ជាគោលប្រតិបត្តិនិងការសិក្សាអំពីទំនាក់ទំនងការបរទេសរវាងរដ្ឋនិងរដ្ឋ ពាក់ព័ន្ធដោយផ្ទាល់ជាមួយការរៀបចំគោនយោបាយការបរទេស ដែលគ្របដណ្តប់ទាំងផ្នែកនយោបាយនិងសេដ្ឋកិច្ច។ ២. ការផ្លាស់ប្តូរនិងចំណងមិត្តភាពដែលកើតឡើងឆ្លងព្រំដែនរបស់រដ្ឋក្នុងកំលុងពេលវេលាណាមួយដោយរដ្ឋាភិបាលឬតួអង្គផ្សេងណាដែលពុំមែនជារដ្ឋាភិបាលក្នុងទម្រង់ដែលជាផ្លូវការឬមិនផ្លូវការដើម្បីគោលបំណងផ្នែកនយោបាយឬគោលបំណងផ្សេង ដោយជាកិច្ចសហប្រតិបត្តិការណ្ឌនឹងគ្នាឬកិច្ចសហប្រតិបត្តិការក្នុងលក្ខណៈជំទាស់គ្នាក្នុងវិស័យនយោបាយសេដ្ឋកិច្ច យោធា និងវប្បធម៌។	វាក្យសព្ទអធិប្បាយពី កត.សប៊.យធ. វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពី កត.សប៊.យធ.	
៥១	ความสำคัญผิดในข้อเท็จจริง ការវាយតម្លៃព័ត៌មានខុស	Mistake of fact (n.)	ការដែលការពិតណាមួយបើមានពិតស្រាប់ នឹងអាចធ្វើឲ្យការប្រព្រឹត្តិពុំកើតជាបទល្មើស ឬអ្នកប្រព្រឹត្តិមិនត្រូវទទួលទោស ឬបានទទួលទោសកម្រិតស្រាល ទោះបីជាព័ត៌មាននោះពុំមានពិតតែអ្នកប្រព្រឹត្តិយល់ខុសថាវាមានពិត អ្នកប្រព្រឹត្តិនឹងពុំមានទោសកំហុស ឬបានទទួលការលើកលែងទោស ឬបានទទួល	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៦២ វាក្យសព្ទភាសាអង់គ្លេស	

ឧបសម្ព័ន្ធ ៤ វាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ទោសកម្រិតស្រាល អាស្រ័យលើករណី។	សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៤៨	
៥២	ค่าจ้าง ថ្លៃឈ្នួល	Wage (n.) Pay (n.)	ប្រាក់គ្រប់ប្រភេទដែលមេឈ្នួលជូលឲ្យកូនឈ្នួលជាថ្លៃតបស្នងការធ្វើការក្នុងថ្ងៃនិងពេលធ្វើការប្រក្រតី មិនថាជាការគណនាតាមរយៈពេលឬគណនាតាមលទ្ធផលការងារដែលកូនឈ្នួលធ្វើបាន និងមានអត្ថន័យរួមដល់ប្រាក់ដែលមេឈ្នួលបង់ឲ្យក្នុងថ្ងៃឈប់សម្រាកនិងថ្ងៃសុំច្បាប់ការងារដែលកូនឈ្នួលពុំបានធ្វើការដែរ ទាំងអស់នេះមិនថាជាការកំណត់គណនា ឬការចាយក្នុងលក្ខណៈណាឬដោយវិធីណា និងមិនថាជាការហៅឈ្មោះថាដូចម្តេច (ព្រះរាជក្រឹត្យស្តីអំពីការធានារ៉ាប់រងសង្គម ព.ស. ២៥៣៣ មាត្រា ៥ និងព្រះរាជក្រឹត្យស្តីអំពីប្រាក់សំណង ព.ស. ២៥៣៧ មាត្រា ៥)	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ១៣២-១៣៣ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៥២	
៥៣	ค่าตอบแทน ប្រាក់សំណងប៉ះប៉ូវ	Remuneration (n.)	ប្រាក់ ទ្រព្យសម្បត្តិ ឬប្រយោជន៍ផ្សេងណាដែលបុគ្គលម្នាក់បានផ្តល់ឲ្យដល់បុគ្គលមួយទៀតដើម្បីជាការតបស្នងដែលបុគ្គលនោះបានធ្វើឬពុំបានធ្វើទង្វើរបស់ខ្លួនដើម្បីប្រយោជន៍ដល់ខ្លួនឬអ្នកដទៃ ប្រាក់ ទ្រព្យសម្បត្តិ ឬប្រយោជន៍ផ្សេងណាដែលជនរងគ្រោះមានសិទ្ធិទទួល ដើម្បីសងប៉ះប៉ូវការខូចខាតដែលកើតឡើង ឬដោយសារមានការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌរបស់	១. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ១៣៥ ២. ព្រះរាជក្រឹត្យស្តីអំពីសំណងខូចខាតដល់ជនរងគ្រោះនិងថ្លៃចំណាយលើជនជាប់ចោទក្នុងរឿងក្តីព្រហ្មទណ្ឌ <u>វាក្យសព្ទភាសាអង់គ្លេស</u>	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			អ្នកផ្សេង	សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៥៣	
៥៤	គំរាំងទុក្ខ ពាក្យបណ្តឹង	Complaint (n.)	ការដែលជនរងគ្រោះបានប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ចតាមបញ្ញត្តិនៃបណ្តុំច្បាប់ ថាមានជនប្រព្រឹត្តិបទល្មើស អាចជាការស្គាល់ជនប្រព្រឹត្តិបទល្មើសឬមិនស្គាល់ក្តីដែលធ្វើឲ្យកើតការខូចខាតដល់ជនរងគ្រោះ និងការប្តឹងនោះបានធ្វើឡើងដោយចេតនាចង់ឲ្យអ្នកប្រព្រឹត្តិល្មើសទទួលទោស។	បណ្តុំច្បាប់វិធីពិចារណាក្តីព្រហ្មទណ្ឌ ច្បាប់យោង (វិសោធកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យបណ្ឌិត សុរសក្តិ លិខសិទ្ធិវឌ្ឍនកុល, មាត្រា ២ (៧) វាក្យសព្ទភាសាអង់គ្លេស សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៦៣	
៥៥	គុំ្មរគ្រងពយាន ការគ្រប់គ្រងនិងការពារសាក្សី	Witness protection (n.)	១. ការអនុវត្តតាមនីតិវិធីមាត្រា ៦ នៃព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងនិងការពារសាក្សីតស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ ព.ស. ២៥៤៦ មានដូចខាងក្រោមនេះ៖ ក្នុងករណីដែលសាក្សីអាចមិនទទួលបាននូវសុវត្ថិភាព ភ្នាក់ងារមានសមត្ថកិច្ចស៊ើបសួរក្តីព្រហ្មទណ្ឌ ភ្នាក់ងារមានសមត្ថកិច្ចសាកសួរក្តីព្រហ្មទណ្ឌ ភ្នាក់ងារមានសមត្ថកិច្ចប្តឹងក្តីព្រហ្មទណ្ឌ តុលាការ ឬការិយាល័យគ្រប់គ្រងនិងការពារសាក្សីអាស្រ័យលើករណី អាចរៀបចំឲ្យសាក្សីស្ថិតនៅក្រោមការគ្រប់គ្រងនិងការពារតាមការយល់ឃើញជាក់ស្តែង ឬតាម	១. ព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងការពារសាក្សីក្នុងរឿងក្តីព្រហ្មទណ្ឌ ព.ស. ២៥៤៦ មាត្រា ៦ ២. នីតិវិធីក្រសួងមហាផ្ទៃស្តីអំពីការគ្រប់គ្រងការពារសាក្សីក្នុងរឿងក្តីព្រហ្មទណ្ឌ ព.ស. ២៥៥១ ប្រការ ៣ វាក្យសព្ទភាសាអង់គ្លេស បំណកប្រែពី កត.សប៉.ឃធ.	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ដែលសាក្សីឬបុគ្គលផ្សេងណា ដែលមានប្រយោជន៍ពាក់ព័ន្ធបានស្នើសុំនិងក្នុងករណីចាំបាច់បុគ្គលនោះត្រូវសុំឲ្យអាជ្ញាធរមានសមត្ថកិច្ចឬភ្នាក់ងារផ្សេងជួយផ្តល់ការគ្រប់គ្រងនិងការពារសាក្សីបានតាមភាពចាំបាច់ ទាំងអស់នេះត្រូវទទួលបានការអនុញ្ញាតពីសាក្សីដែរ។ ២. ការគ្រប់គ្រងនិងការពារសុវត្ថិភាពសាក្សីមិនឲ្យកើតគ្រោះថ្នាក់ដល់ជីវិត រាងកាយ អនាម័យ សេរីភាព កេរ្តិ៍ឈ្មោះ ទ្រព្យសម្បត្តិ ឬសិទ្ធិណាមួយរបស់សាក្សី រួមទាំងបុគ្គលតាមមាត្រា ៧ នៃព្រះរាជក្រឹត្យស្តីអំពីការគ្រប់គ្រងសាក្សីក្នុងរឿងក្តីព្រហ្មទណ្ឌ ព.ស. ២៥៤៦។		
៥៦	เจตนาฆ่าผู้อื่นโดยไตร่ตรองไว้ก่อน เจตนามนุษฆาตคิดทุกชั่วมุน	Premediated design (n.)	ការសម្លាប់មនុស្សដោយជនប្រព្រឹត្តិបានមានឱកាសគិតពិចារណាល្អិតល្អន់ហើយទើបសម្រេចចិត្តក្នុងការប្រព្រឹត្តិបទល្មើស ពុំមែនជាការប្រព្រឹត្តិទៅដោយបច្ចុប្បន្នទាន់ហាន់ព្រោះស្រវឹងស្រាឬបណ្តាលទោស:។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ២៨៩ (៥) <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ២៥៩	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៥៧	เจตนาทางอาญา ចេតនាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ	Criminal intent (n.) Intent (n.)	ការប្រព្រឹត្តដោយដឹងនូវអ្វីដែលប្រព្រឹត្តិនិងក្នុងពេលជាមួយគ្នានោះជនប្រព្រឹត្តិចង់បានផលប្រយោជន៍ឬសង្ឃឹងឃើញផលប្រយោជន៍នៃការប្រព្រឹត្តិនោះ។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ២៨៩ ប្រការ ២ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៨១	
៥៨	ฉ้อโกง ឆបោក	Defraud (v.)	ជនណាទុច្ចរិត បោកបញ្ឆោតជនដទៃដោយការបង្ហាញទិន្នន័យមិនពិត ឬបិទបាំងទិន្នន័យពិតដែលគួរប្រាប់ឲ្យដឹងច្បាស់និងដោយការបោកបញ្ឆោតដូចដែលនិយាយនេះដើម្បីទទួលបាននូវទ្រព្យសម្បត្តិពីជនរងគ្រោះឬបុគ្គលទីបី ឬធ្វើឲ្យជនរងគ្រោះឬបុគ្គលទីបី ធ្វើ ដក ឬបំផ្លាញឯកសារកម្មសិទ្ធិ ជននោះប្រព្រឹត្តិល្មើសច្បាប់ឆបោក។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៣៤១ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៥៨៤	
៥៩	เดินเผชิญสืบ ដើរស៊ើបអង្កេត	To view the scene (v.)	ស៊ើបសាក្សីក្រៅសាលតុលាការ ដូចជា ការទៅត្រួតពិនិត្យទីកន្លែងដែលពាក់ព័ន្ធនឹងរឿងក្តី ការស៊ើបរកសាក្សីនៅកន្លែងដទៃដែលពុំមែនជាកន្លែងធ្វើការរបស់តុលាការ (មើល ប៉.រ.	១. វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៥ (វិសោធនកម្ម), ទំព័រ ២២១	

ឧបសម្ព័ន្ធ ៤ ឃ្លាសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ឃ្លា)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ព្រហ្មទណ្ឌ មាត្រា ២៣០ និង ប៉.រ. រដ្ឋប្បវេណី ម.១០៧) បណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ២៣០ ពេលគូវិវាទដែលពាក់ព័ន្ធស្នើសុំឬពេលតុលាការយល់ឃើញថាសមស្រប តុលាការអាចធ្វើការស៊ើបរកសាក្សីតស្តុតាងឬពេលមានហេតុការណ៍ចាំបាច់ពុំអាចយកសាក្សីតស្តុតាងមកសាកសួរក្នុងសាលាក្តីបានទេនោះ និងការស៊ើបសួររកសាក្សីតស្តុតាងដោយវិធីផ្សេងពុំអាចធ្វើបាន តុលាការមានអំណាចបញ្ជូនចំណុចនោះឲ្យតុលាការផ្សេងស៊ើបសួររកសាក្សីតស្តុតាងជំនួស ឲ្យតុលាការដែលទទួលចំណុចនោះមានអំណាចនិងតួនាទីដូចតុលាការដើម រួមទាំងមានអំណាចបញ្ជូនចំណុចនោះបន្តទៅឯតុលាការដទៃទៀតបាន បណ្តុំច្បាប់ស្តីអំពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ១០៧ បើតុលាការយល់ឃើញថាក្នុងការស៊ើបសួររកការពិតចាំបាច់ត្រូវទៅស៊ើបរកសាក្សីនៅទីកន្លែងដែលរឿងកើតឡើង ដែលតុលាការចង់ឲ្យសាក្សីឆ្លើយសំណួរនោះ តម្រូវឲ្យតុលាការឬអ្នកកាត់សេចក្តី ឬតុលាការដែលបានទទួលការតែងតាំងដើម្បីធ្វើកិច្ចការនោះបញ្ជូនដីកាកោះហៅទៅឯសាក្សីដោយកំណត់ទីកន្លែងនិងកាលបរិច្ឆេទដែលនឹងត្រូវស៊ើបសួររកសាក្សីហើយស៊ើបរកសាក្សីទៅតាមដំណើរនោះ។	២. បណ្តុំច្បាប់ស្តីអំពីវិធីពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ២៣០ ៣. បណ្តុំច្បាប់ស្តីអំពីវិធីពិចារណាក្តីរដ្ឋប្បវេណី មាត្រា ១០៧ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅណែនាំការប្រើភាសាអង់គ្លេសក្នុងរាជការតុលាការ (ក្តីព្រហ្មទណ្ឌ) ភាគទី ១ បោះពុម្ពលើកទី ២, ក្រុមកិច្ចការការបរទេស ការិយាល័យសាលយុត្តិធម៌ ទំព័រ ៥៨	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៦០	ព័ទ្យបាន សេចក្តីថ្លែង	Statement (n.)	សេចក្តីចង្អុលបង្ហាញ សេចក្តីប្រកាស សេចក្តីអធិប្បាយជាផ្លូវការ។	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៦២៨ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវចនានុក្រមថៃ-អង់គ្លេសដោយ រង្សៀ វណ្ណធនពិជេដ្ឋ ទំព័រ ៣៣៨	
៦១	แถลงการณ์ សេចក្តីថ្លែងការណ៍	Argument (n.)	សេចក្តីថ្លែងដោយវាចាឬជាលិខិត ដែលគូវិវាទភាគីម្ខាងធ្វើឬជូនចំពោះតុលាការ ដោយមានគោលបំណងចង់ស្នើយោបល់ចំពោះតុលាការនូវខ្លឹមសារនៃចំណុចដែលបានលើកឡើងអះអាងក្នុងពាក្យរបស់គូវិវាទឬក្នុងបញ្ហាចំណុចណាមួយដែលតុលាការទើបតែចេញបញ្ហាឬសាលក្រម ដែលក្នុងចំណុចនោះគូវិវាទភាគីម្ខាងគ្រាន់តែបង្ហាញ ឬនិយាយរំលឹក ឬអះអាង ឬអធិប្បាយខ្លឹមសារនៃពាក្យសាក្សី ភស្តុតាង និងបញ្ហាចំណុចច្បាប់និងសេចក្តីពិតទាំងពួង។ សេចក្តីថ្លែងការណ៍អាចមានន័យរួមក្នុងពាក្យរបស់គូវិវាទ។	១. បណ្តុំច្បាប់ស្តីអំពីវិធីពិចារណាក្តីរដ្ឋប្បវេណី មាត្រា ១ (៦) <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ២១	
៦២	ทะเบียนบ้าน ការចុះបញ្ជីផ្ទះ	House registration (n.)	ផ្ទះនីមួយៗ ដែលចុះបញ្ជីលេខផ្ទះនិងចំនួនមនុស្សដែលរស់នៅក្នុងផ្ទះ។	ព្រះរាជក្រឹត្យស្តីអំពីការចុះអត្រានុគោលដ្ឋានប្រជាជន ព.ស. ២៥៣៤ មាត្រា ៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅ Law dictionary វចនានុក្រម	

ឧបសម្ព័ន្ធ ៤ ឧទាហរណ៍វាក្យសព្ទក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
				វាក្យសព្ទសំនួនច្បាប់ ថៃ-អង់គ្លេស, អង់គ្លេស-ថៃ ដោយ ធង វិទ័យវឌ្ឍន, ទំព័រ ១៩៨	
៦៣	ที่พักพิง កន្លែងស្នាក់អាស្រ័យ	Safe haven (n.) Shelter (n.)	កន្លែងស្នាក់អាស្រ័យបណ្តោះអាសន្ន	វចនានុក្រមច្បាប់រាជបណ្ឌិត្យសភា ព.ស. ២៥៥៤ ទំព័រ ៨២៦ <u>វាក្យសព្ទភាសាអង់គ្លេស</u> ១. សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦២៤ ២. ទទួលសណ្តាប់យោបល់ ៥ ភាគ	
៦៤	เทศบาลนคร រដ្ឋបាលរាជធានី	City administration (n.)	រដ្ឋបាលរាជធានី សំដៅលើ រដ្ឋបាលតំបន់ទីប្រជុំជនដែលមានប្រជាជនចាប់ពីប្រាំម៉ឺននាក់ឡើងទៅ ថែមទាំងមានចំណូលសមគួរក្នុងការអនុវត្តតួនាទីដែលត្រូវធ្វើតាមព្រះរាជក្រឹត្យនេះ និងដែលមានប្រកាសរបស់ក្រសួងមហាផ្ទៃឲ្យចុះបញ្ជីនិងព្រំដែនរបស់ក្រុងនោះដែរ។	ព្រះរាជក្រឹត្យស្តីអំពីប្រព័ន្ធរដ្ឋបាលគ្រប់គ្រង ព.ស. ២៤៩៦ មាត្រា ១១ <u>វាក្យសព្ទភាសាអង់គ្លេស</u> - សៀវភៅវចនានុក្រមថៃ-អង់គ្លេសដោយ រង្សៃ វណ្ណធនពិជេដ្ឋ ទំព័រ ៣៣៨ - សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦២៧	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៦៥	เทศบาลเมือง រដ្ឋបាលក្រុង	Town administration (n.)	រដ្ឋបាលក្រុង សំដៅលើ រដ្ឋបាលតំបន់ដែលជាទីតាំងសាលាខេត្តឬតំបន់ទីប្រជុំជនដែលមានប្រជាជនចាប់ពីមួយម៉ឺននាក់ឡើងទៅ ថែមទាំងមានចំណូលសមគួរក្នុងការអនុវត្តតួនាទីដែលត្រូវធ្វើតាមព្រះរាជក្រឹត្យនេះ និងដែលមានប្រកាសរបស់ក្រសួងមហាផ្ទៃលើកស្ថាន:ជារដ្ឋបាលក្រុង ប្រកាសរបស់ក្រសួងមហាផ្ទៃឲ្យចុះបញ្ជីឈ្មោះនិងព្រំដែនរបស់ខេត្តនោះដែរ។	ព្រះរាជក្រឹត្យស្តីអំពីប្រព័ន្ធរដ្ឋបាលគ្រប់គ្រង ព.ស. ២៤៩៦ មាត្រា ១០ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវចនានុក្រមថៃ-អង់គ្លេសដោយ រង្ស៊ី វណ្ណធនពិជេដ្ឋ ទំព័រ ៣៨៥	
៦៦	ธรรมาภิบาล ធម្មាភិបាល	Good Governance (n.)	គោលការណ៍ក្នុងការគ្រប់គ្រង ការបម្រើ ការរៀបចំ ការការពារ សកម្មភាពផ្សេងៗ ឲ្យដំណើរការទៅតាមគន្លងធម៌ ប្រកបដោយគោលការណ៍ ១០ ប្រការ គឺ គោលការណ៍ប្រសិទ្ធផល គោលការណ៍ប្រសិទ្ធភាព គោលការណ៍ឆ្លើយតប គោលការណ៍ទទួលខុសត្រូវ គោលការណ៍តម្លាភាព គោលការណ៍មានការរួមចំណែក គោលការណ៍ការពង្រីកអំណាច គោលការណ៍នីតិធម៌ គោលការណ៍សមភាព និងគោលការណ៍ឆន្ទៈមតិ	១. វាក្យសព្ទអធិប្បាយពី កត.សប៉.យធ. ២. សៀវភៅណែនាំស្តីអំពីការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងអង្គភាពរដ្ឋតាមគោលការណ៍ធម្មាភិបាលរបស់អាជ្ញាធរកិច្ចការភូមិឃុំសុវត្ថិភាព (Good Governance Rating) ដោយការិយាល័យ ក.ព.រ. <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពី កត.សប៉.យធ.	
៦៧	นับโทษต่อ ការរាប់ទោសបន្ត	Consecutive sentence (n.)	ពុំមាននិយមន័យនៃការរាប់ទោសបន្តដោយផ្ទាល់ក្នុងច្បាប់ មានតែមាត្រាដែលតុលាការកែសម្រួលសម្រាប់ប្រើក្នុងការរាប់ទោសបន្ត។ ទោសជាប់ពន្ធនាគារ ត្រូវចាប់ផ្តើមពីថ្ងៃដែលចេញសាលក្រម តែបើអ្នកជាប់សាលក្រមបានជាប់ពន្ធនាគារមុនតុលាការចេញសាលក្រម គម្រូវឲ្យដកចំនួនថ្ងៃដែលត្រូវ	បណ្តុំច្បាប់ព្រហ្មទណ្ឌមាត្រា ២២	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
			ជាប់ពន្ធនាគារចេញពីរយៈពេលជាប់ពន្ធនាគារតាមសាលក្រមលើកលែងតែសាលក្រមនោះកំណត់តាមបែបផ្សេង។ ក្នុងករណីដែលសាលក្រមកំណត់តាមបែបផ្សេង ទោសជាប់ពន្ធនាគារតាមសាលក្រម ពេលបូកបញ្ចូលរួមចំនួនថ្ងៃដែលត្រូវជាប់ពន្ធនាគារមុនសាលក្រមក្នុងរឿងក្តីរឿងនោះជាមួយគ្នាហើយ ត្រូវមិនលើសអត្រាទោសកម្រិតខ្ពស់នៃច្បាប់ដែលបានបញ្ញត្តិចំពោះបទល្មើសដែលបានប្រព្រឹត្តិនោះ។ ប្រការទាំងអស់នេះមិនត្រូវប៉ះពាល់បទបញ្ញត្តិក្នុងមាត្រា ៩១ ។		
៦៨	នាយประกันผิดสัญญา អ្នកធានាមិនគោរពកិច្ចសន្យា	Bail bondsman in breach of contract (n.)	ក្នុងករណីខុសកិច្ចសន្យាចំពោះតុលាការ តុលាការមានអំណាចចេញបង្ហាយោងតាមកិច្ចសន្យាធានាឬតាមដែលតុលាការយល់ឃើញថាសមស្របដោយមិនត្រូវប្តឹង។ ប្រការទាំងអស់នេះ តុលាការអាចចេញបង្ហាបង្ខំបទបញ្ជាតាមកិច្ចសន្យាធានាឬបន្តយចំនួនទឹកប្រាក់ដែលត្រូវប្រើតាមកិច្ចសន្យាធានាក៏បាន ដោយអនុលោមតាមសេចក្តីព្យាយាមរបស់អ្នកធានាក្នុងការតាមរកជនជាប់ចោទឬចុងចោទដែលរត់គេចខ្លួនរួមទាំងការខូចខាតដែលកើតឡើងថាមានតិចឬច្រើនកម្រិតណាផ្សំជាមួយដៃរនិងពេលតុលាការចេញបញ្ជាប្រការណាមួយហើយភាគីអ្នកត្រូវបង្គាប់បញ្ជាតាមកិច្ចសន្យាធានាឬភ្នាក់ងារអយ្យការមានអំណាចសើរើបាន។ ការវិនិច្ឆ័យក្តីរបស់សាលាឧទ្ធរណ៍ត្រូវកំណត់ជាសាលក្រមចុងក្រោយ។	បណ្តុំច្បាប់ស្តីពីនីតិវិធីពិចារណាក្តីព្រហ្មទណ្ឌ មាត្រា ១១៩	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៦៩	นายอำเภอ ចៅហ្វាយស្រុក	Chief district officer (n.)	តំណែងប្រធានអាជ្ញាធរគ្រប់គ្រងតំបន់ ដែលជាប្រធានគ្រប់គ្រងរាជការថ្នាក់ស្រុក និងទទួលខុសត្រូវក្នុងការបម្រើរាជការថ្នាក់ស្រុក។	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ២៩៤ <u>វាក្យសព្ទភាសាអង់គ្លេស</u> ទទួលសណ្តាប់ធ្នាប់ ៤ ភាគ	
៧០	นิติธรรม នីតិធម៌	Rule of Law (n.)	គោលមូលដ្ឋាននៃច្បាប់ដែលបុគ្គលគ្រប់គ្នាត្រូវនៅក្រោមច្បាប់ដោយស្មើភាពគ្នា។	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ៣០០ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣០០	
៧១	นิรโทษกรรม និរទោសកម្ម	Amnesty (n.)	ច្បាប់ដែលបញ្ឈប់ឲ្យជនប្រព្រឹត្តិដែលច្បាប់កំណត់ថាជាបទល្មើស រួចផុតពីកំហុសឬការទទួលខុសត្រូវទាំងពួង។	វចនានុក្រមវាក្យសព្ទច្បាប់ថៃ ច្បាប់រាជបណ្ឌិត្យសភា បោះពុម្ពលើកទី ៤ (វិសោធនកម្ម), ទំព័រ ៥ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៦៣៤	

ជំពូក ៤ ឧទាហរណ៍ក្នុងដំណើរការផ្សេងៗ (១០៤ ពាក្យ)

ល.រ	វាក្យសព្ទភាសាខ្មែរនិងភាសាថៃ	វាក្យសព្ទភាសាអង់គ្លេស (នាម កិរិយា)	ការអធិប្បាយវាក្យសព្ទ	ប្រភពវាក្យសព្ទ	កំណត់សម្គាល់
៧២	បันทึกความเข้าใจ កំណត់ត្រាលិខិតយល់ស្របគ្នា	Memorandum of Understanding (n.)	ការរៀបចំធ្វើលិខិត ដោយភាគីមួយបង្ហាញការស្ម័គ្រចិត្តចង់អនុវត្តប្រការណាមួយ និងតាមលក្ខខណ្ឌដែលមានក្នុងលិខិតនោះជាមួយភាគីម្ខាងទៀត ដោយដែលលិខិតនោះមិនត្រូវបានចាត់ទុកថាជាកិច្ចសន្យាចំណងភ្ជាប់ តែជាការបង្ហាញតម្រូវការដ៏ជាក់លាក់របស់អ្នកស្ម័គ្រចិត្តថានឹងអនុវត្តតាមដូចការដែលបានកំណត់ទុក និងភាគីមួយទៀតក៏យល់ដូចគ្នាដែរ។	វាក្យសព្ទអធិប្បាយពី កត.សប៉.យធ. (http://www.sc.mahidol.ac.th/IC/info/MOU-MOA.pdf) <u>វាក្យសព្ទភាសាអង់គ្លេស</u> បំណកប្រែពី កត.សប៉.យធ.	
៧៣	บันดาลโทสะ ការបណ្តាលទោស:	Sudden heat of passion (n.)	ការប្រព្រឹត្តិដោយឆេវឆាវលឿនមួយរំពេចព្រោះត្រូវគេគំរាមយ៉ាងធ្ងន់ធ្ងរដោយហេតុដែលពុំមែនជាធម្មដោយពិចារណាប្រៀបធៀបនឹងអារម្មណ៍របស់វិញ្ញូជន រកឃើញថាពុំមែនជាអារម្មណ៍របស់អ្នកប្រព្រឹត្តិល្មើស។ ក្រៅពីនេះការបណ្តាលទោស:អាចកើតពីការប្រព្រឹត្តិចំពោះបុគ្គលជិតស្និទ្ធលើអ្នកប្រព្រឹត្តិបទល្មើសក៏ថាបាន។	បណ្តុំច្បាប់ព្រហ្មទណ្ឌ ច្បាប់យោង (វិសោធនកម្ម) ព.ស. ២៥៦១, សាស្ត្រាចារ្យ បណ្ឌិត ទ្វីកិត្តិ មីន:កន្ទិដ្ឋ, មាត្រា ៧២ <u>វាក្យសព្ទភាសាអង់គ្លេស</u> សៀវភៅវាក្យសព្ទនីតិសាស្ត្រ ច្បាប់រាជបណ្ឌិត្យសភា, បោះពុម្ពលើកទី ៨, ទំព័រ ៣២៣	
